**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការការពារតតិយជនក្រោយលុបចោលកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះកញ្ញា **ជា ប៉ឡៀង**

លោក **ជា សុផារ៉ា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការការពារតតិយជនក្រោយលុបចោលកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ជា ប៉ទៀង**
លោក **ជា សុផារ៉ា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ជា ប៉ទៀង** និង **ជា សុផារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រុម$L_4A_{10}$ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំទាំងពីរនាក់សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

អ្នកម្តាយ **សោម ណារ៉េត** លោកយាយ **សោម ចន្ថា** លោកឪពុក **ជា សៃ** និងអ្នកម្តាយ **សៀន សាទី** ដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ ថែរក្សាថ្នាក់ថ្នមរូបយើងខ្ញុំតាំងពីពេលចាប់កំណើត មកដល់សព្វថ្ងៃនេះដោយក្តីស្រលាញ់ និងការសណ្តោសប្រណីដោយព្រហ្មវិហារធម៌ ជាពិសេសគឺជាគ្រូ ដែលបានផ្តល់នូវការអប់រំ ទូន្មានដំបូងបំផុតក្នុងជីវិតរបស់យើងខ្ញុំទាំងពីរ លើសពីនេះទៅទៀតលោកទាំងពីរតែងតែជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាង ទាំងស្មារតីនិងសម្ភារៈ សម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់យើងខ្ញុំតាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនាពេលនេះ ដោយពុំដែលត្អូញត្អែរពីភាពនឿយហត់បន្តិចណាសោះឡើយដែលទាំងនេះគឺកម្លាំងជំរុញដ៏អស្ចារ្យឱ្យខ្ញុំតស៊ូដើម្បីមកដល់ភាពជោគជ័យរបស់យើងខ្ញុំទាំងពីរនាពេលបច្ចុប្បន្ននេះ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោកសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានយកចិត្តទុកដាក់ចំណាយពេលវេលា និងកម្លាំងញើសឈាមដ៏មានតម្លៃរបស់អស់លោក ដើម្បីបណ្តុះបណ្តាល និងបំពេញបន្ថែមនូវពុទ្ធិដល់រូបយើងខ្ញុំក៏ដូចជាមិត្តនិស្សិតទាំងអស់ដែលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ គ្រប់មុខវិជ្ជាតាំងពិថ្នាក់សិក្សាឆ្នាំមូលដ្ឋាន រហូតដល់បញ្ចប់ការសិក្សា។

យើងខ្ញុំក៏សូមថ្លែងអំណរគុយយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកសាស្ត្រាចារ្យ **ទេព សុខ** ដែលលោកសាស្ត្រាចារ្យ បានទទួលយកនូវការដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការបណ្តុះបណ្តាល និងពន្យល់ណែនាំផ្តល់ជាចង្កៀងដើម្បីបំភ្លឺគំនិតដល់យើងខ្ញុំ ក្នុងរយៈពេលកន្លងមកនេះ រហូតយើងខ្ញុំបានចងក្រងនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះឡើងដោយភាពជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ និងសិស្សនិស្សិត** ទាំងអស់ ឱ្យសូមជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាក់ខានឡើយ ។

# អារម្ភកថា

សារណាមួយក្បាលនេះ គឺជាសមិទ្ធិផលមួយដែលកើតឡើងពីការខិតខំប្រឹងប្រែង ការតស៊ូព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រននីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលបួនឆ្នាំកន្លងមកនេះ ដើម្បីបន្សល់ទុកជាស្នាដៃមួយ សម្រាប់ជាគុណប្រយោជន៍ ទៅដល់សិស្សនិស្សិតជំនាន់ក្រោយៗក្នុងការសិក្សាស្រាវជ្រាវបន្ត។

ការសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមកនេះ គ្រប់មុខវិជ្ជាដែលយើងខ្ញុំបានសិក្សា គឺសុទ្ធតែមានសារៈសំខាន់ៗសម្រាប់អនុវត្តក្នុងសង្គមយើងនាពេលបច្ចុប្បន្ននេះ ហើយសម្រាប់យើងខ្ញុំផ្ទាល់ដោយឃើញថាប្រទេសកម្ពុជាសព្វថ្ងៃជាប្រទេសដែលកំពុងតែអភិវឌ្ឍន៍ ទើបបណ្តាលឱ្យយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជារដ្ឋប្បវេណី ដែលជាមុខវិជ្ជាគ្រឹះមួយសម្រាប់ការអភិវឌ្ឍទៅលើវិស័យយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជាប្រសើរឡើង និងមានយុត្តិធម៌នៅក្នុងសង្គម។ ជាក់ស្តែងនាពេលបច្ចុប្បន្នវិស័យយុត្តិធម៌នេះ គឺជាអំណាចមួយក្នុងចំណោមអំណាចធំៗ ទាំងបី នៅកម្ពុជាដែលជាចំណុចចម្បងមួយត្រូវពង្រឹង និងកំពុងតែពេញនិយម ដែលជាហេតុផលធ្វើឱ្យយើងខ្ញុំបានជ្រើសរើសយកការស្រាវជ្រាវសារណាមួយនេះឡើង ក្រោមប្រធានបទស្តីអំពី “**ការការពារតតិយជនក្រោយលុបចោលកិច្ចសន្យា**”។

តាមរយៈស្នាដៃស្រាវជ្រាវមួយនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាវានឹងអាចជួយបន្ថែមនូវចំណេះដឹងថ្មីៗ និងផ្តល់ជាអត្ថប្រយោជន៍ជាច្រើនទៅដល់អ្នកអានគ្រប់រូប ពិសេសនិស្សិតជំនាន់ក្រោយឱ្យបានយល់កាន់តែស៊ីជម្រៅ ជាពិសេសជួយសម្រួលឱ្យមានភាពងាយស្រួលក្នុងការស្វែងយល់អំពីនីតិវិធីនៃការការពារតតិយជនក្រោយលុបចោលកិច្ចសន្យាអោយស្របតាមច្បាប់នៃព្រះរាជណាចក្រកម្ពុជា។

ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំក៏សូមធ្វើការខន្តី អភ័យទោសនូវរាល់ចំណុចខ្វះខាតដូចជាការប្រើប្រាស់ពាក្យពេចន៍ អន្តន័យ ឬកំហុសឆ្គងដោយអចេតនាណាមួយដែលមាននៅក្នុងសារណា មួយនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថា ពិតជាគ្មានអ្វីដែលល្អឥតខ្ចោះនោះឡើយ ដូចនេះ យើងខ្ញុំត្រូវតែទទួលស្គាល់នូវកំហុសទាំងឡាយរបស់យើងខ្ញុំ និងទទួលយកនូវការកែតម្រូវរបស់លោកអ្នកអានតាមរយៈការផ្តល់ជាមតិយោបល់ រិះគន់ដើម្បីភាពស្ថាបនារបស់មិត្តៗនិស្សិត លោក លោកស្រី ទាំងអស់ ដើម្បីឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម ........ ១**


## ជំពូកទី១

## សញ្ញាណគតិយុត្តនៃការលុបចោលកិច្ចសន្យា


**១.១.លក្ខខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការលុបចោលកិច្ចសន្យា ........ ៣**

**១.១.១.សកម្មភាពដែលអាចលុបចោល ........ ៤**

**១.១.២.អ្នកមានសិទ្ធិលុបចោល ........ ៥**

**១.១.៣. វិធីនៃការលុបចោល ឬការផ្តល់សច្ចានុមតិ ........ ៧**

**១.១.៤.អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និងលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ ........ ៨**

**១.១.៥.សច្ចានុមតិដែលច្បាប់បានកំណត់ ........ ៩**

**១.១.៦.អាជ្ញាយុកាលនៃការរំលត់សិទ្ធិ លុបចោល ........ ១០**

**១.២.ប្រភេទផ្សេងៗនៃកិច្ចសន្យាដែលអាចលុបចោល ........ ១១**

**១.២.១.ការភាន់ច្រឡំ ........ ១២**

**១.២.២.ការឆបោក ........ ១៦**

**១.២.៣.ព័ត៌មានមិនពិត ........ ១៧**

**១.២.៤.ការរំលោភលើស្ថានភាព ........ ១៨**

**១.២.៥.ការគំរាមកំហែង ........ ១៩**

**១.២.៦.អំពើគេចយកចំណេញហួសហេតុ ........ ២០**


## ជំពូកទី២

## ការលុបចោលកិច្ចសន្យា និង បណ្តឹងតវ៉ារបស់តតិយជន


**២.១.តតិយជន និង ការលុបចោលកិច្ចសន្យា ........ ២១**

**២.១.១.តតិយជន និង ការលុបចោលដោយការភាន់ច្រឡំ ........ ២១**

**២.១.២.តតិយជន និង ការលុបចោលដោយការឆបោក ........ ២២**

**២.១.៣.ព័ត៌មានមិនពិត និង តតិយជន ........ ២៤**

**២.១.៤.ការរំលោភបំពានលើស្ថានភាព និង តតិយជន ........ ២៤**

**២.១.៥.ការគំរាមកំហែង និង តតិយជន ........ ២៥**

**២.១.៦.អំពើគេចយកចំណេញហួសហេតុ និង តតិយជន ........ ២៥**

២.២.បណ្ដឹងតវ៉ារបស់តតិយជន ........ ២៥
២.២.១.មូលហេតុ ........ ២៦
២.២.២.សមត្ថកិច្ច ........ ២៧
២.២.៣.ការដាក់ពាក្យបណ្ដឹង ........ ២៧
២.២.៤.ពន្ធដាក់ពាក្យបណ្ដឹង ........ ២៨
២.២.៥.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ ........ ២៨

## ជំពូកទី៣

## ចំណាត់ការលើបណ្ដឹងតវ៉ារបស់តតិយជន

៣.១.ការរៀបចំពាក្យបណ្ដឹង ........ ៣០
៣.២.សមត្ថកិច្ចសាលាជម្រះក្ដី ........ ៣០
៣.៣.ពេលដាក់ពាក្យបណ្ដឹង ........ ៣១
៣.៤.ការរួមបញ្ចូលបណ្ដឹង ........ ៣១
៣.៥.ការផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹង ........ ៣១
៣.៦.ការវិនិច្ឆ័យបណ្ដឹងតវ៉ារបស់តតិយជន ........ ៣១
៣.៧.អង្គហេតុចម្បង ........ ៣២
៣.៨.ហេតុនៃការតវ៉ា ........ ៣២
៣.៨.១. កម្មសិទ្ធិ ........ ៣២
៣.៨.២. សិទ្ធិកាន់កាប់ ........ ៣៣
៣.៨.៣. សិទ្ធិជួលអចិន្ត្រៃយ៍ និងសិទ្ធិផលុបភោគ ជាអាទិ៍ ........ ៣៣
៣.៨.៤. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ........ ៣៣
៣.៨.៥. សិទ្ធិហ៊ីប៉ូតែក និងឯកសិទ្ធិ ........ ៣៣
៣.៨.៦. សិទ្ធិឃាត់ទុក ........ ៣៣
៣.៨.៧. ប្រាតិភោគដោយអនុប្បទាន ........ ៣៤
៣.៨.៨. ឧទាហរណ៍នៃសេចក្ដីសម្រេចបញ្ចប់ ........ ៣៤
៣.៩.អាជ្ញាអស់ជំនុំ ........ ៣៤
៣.១០.នីតិវិធីក្រោយចេញសាលក្រម ........ ៣៤
៣.១១.ការសះជា ........ ៣៥
៣.១២. ការផ្អាកការអនុវត្ត ........ ៣៥

៣.១២.១.ពាក្យសុំផ្អាកការអនុវត្ត......................................................................................36
៣.១២.២. លក្ខខណ្ឌនៃការផ្អាកការអនុវត្ត .....................................................................36
៣.១២.៣. វិធីវិនិច្ឆ័យ..........................................................................................................36
៣.១២.៤. អំពីប្រាតិភោគ....................................................................................................36
៣.១២.៥. ខ្លឹមសារនៃដីកាសម្រេច ...................................................................................37
៣.១២.៦. ដីកាសម្រេចផ្អាកការអនុវត្តដោយខ្ញុំ ...........................................................37
៣.១២.៧. សេចក្ដីសម្រេចបញ្ចប់......................................................................................37
**សេចក្ដីសន្និដ្ឋាន**................................................................................................................39
**អនុសាសន៍** .....................................................................................................................៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

កន្លងមកប្រទេសកម្ពុជាធ្លាប់មានក្រមរដ្ឋប្បវេណីមួយនាសម័យអាណានិគមនិយមបារាំង ដែលបានប្រកាសដាក់អោយប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ ដោយច្បាប់នោះត្រូវបាននិរាករណ៍ដោយក្រឹត្យច្បាប់លេខ៣៨វិញ នៅក្នុងច្បាប់ស្ដីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យានេះ បើទៅពិនិត្យមើលក្នុងនោះពុំបានចែងទាក់ទិននឹងការលុបចោលនៃកិច្ចសន្យាឡើយ។ ទើបតែរហូតមកដល់ឆ្នាំ១៩៩៩ សេចក្ដីព្រាងច្បាប់មួយបានលេចឡើងក្រោមរូបភាពរបស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ហៅកាត់ថាJICA។ ក្រោយពីបានពិនិត្យចប់សព្វគ្រប់ពីព្រឹទ្ធសភារួចនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ក៏មិនទាន់អាចចូលជាធរមានបាន ដោយហេតុថាត្រូវរង់ចាំច្បាប់ស្ដីពីការអនុក្រមរដ្ឋប្បវេណីមួយទៀត។ បន្ទាប់ពីបានការចូលជាធរមានរួចនូវច្បាប់ស្ដីពីការអនុវត្តក្រមនេះ ទើបក្រមរដ្ឋប្បវេណីបានចូលជាធរមាននៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។ ក្នុងក្រមនេះទៀតសោត មានគន្លឹះមួយចំនួនបានចែងទាក់ទិននឹងកិច្ចសន្យា ដោយក្នុងនោះបានគ្របដណ្ដប់ទៅការលុបចោល វិការៈនៃកិច្ចសន្យា និងការការពារតតិយជន។ នៅក្នុងជីវភាពប្រចាំថ្ងៃ យើងតែងតែមានទំនាក់ទំនងជាមួយគ្នានឹងគ្នា។ ទំនាក់ទំនងក្នុងតាមផ្លូវជំនួញ ដូចជាកិច្ចសន្យាលក់ទិញ កិច្ចសន្យាបញ្ចាំ...។ ទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាទាំងនោះសុទ្ធតែត្រូវបានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នេះ ចែងប្បញ្ញត្តិច្បាស់លាស់។ កិច្ចសន្យាដែលបានបង្កើតឡើងដោយសមស្របទៅតាមផ្លូវច្បាប់(សមត្ថភាពខាងឆន្ទៈ សមត្ថជន) ក៏ដោយ ក៏អាចនៅតែមានស្នើរសុំលុបចោលបាន។ តួយ៉ាងប្រសិនបើកិច្ចសន្យានោះបានបង្កើតឡើងដោយសារតែការភាន់ច្រឡំរបស់ភាគី ឬការបង្ហាញព័ត៌មានក្លែងក្លាយ(មិនពិត) ទៅកាន់ភាគី ទោះជាកិច្ចសន្យានោះបានព្រមព្រៀងពីភាគីនៃកិច្ចសន្យាក្ដី ក៏ជននោះមានសិទ្ធិក្នុងការលុបចោលបានដែរ។ ប្រសិនបើជាជនដែលត្រូវបានកម្រិតសមត្ថភាព (អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ)ជាអ្នកបង្កើតវិញ ក្រមរដ្ឋប្បវេណីក៏បានការពារដូចគ្នា។ ទម្រាំតែជាតតិយជនទៀត តើច្បាប់បានគាំពារគាត់បានដោយរបៀបណា? តើវិការៈក្នុងការលុបចោលកិច្ចសន្យាប៉ុន្មានប្រភេទ? ហើយតើប្រភេទណាខ្លះវិការៈដែលអាចការពារតតិយជនក្រោយការលុបចោលកិច្ចសន្យាបាន? ប្រសិនបើតតិយជនចង់ដាក់ពាក្យបណ្ដឹង តើគាត់ត្រូវធ្វើខ្លះដើម្បីអោយពាក្យបណ្ដឹងនោះមានសុពលភាពតាមផ្លូវច្បាប់បាន?

ខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទស្ដីពី "ការការពារតតិយជនក្រោយលុបចោលកិច្ចសន្យា" និងបានរៀបចំចងក្រងអត្ថបទសារណាមួយនេះឡើង មានគោលបំណងឱ្យមិត្តអ្នកអានដែលជានិស្សិតផ្នែកនីតិសាស្ត្រ អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយយល់ដឹងបន្ថែមទៅលើលក្ខខណ្ឌតតិយុត្តិដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះ។

គោលបំណងទាំងនោះរួមមាន៖ យល់ដឹងអំពីលក្ខខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការលុបចោលកិច្ចសន្យា អំពីសកម្មភាព និងជនដែលមានសិទ្ធិលុបចោលកិច្ចសន្យា អំពីវិធីនៃការលុបចោលកិច្ចសន្យា អំពីអ្នកមានសិទ្ធិសច្ចានុមតិ និងលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ ប្រៀបធៀបវិការៈនៃកិច្ចសន្យារវាងសមត្ថជន និងគតិយជន និងយល់ដឹងអំពីនីតិវិធីនៃច្បាប់សារធាតុដែលទាក់ទងទៅនឹងបណ្តឹងរបស់គតិយជន។

ប្រធានបទខាងលើ គឺយើងខ្ញុំនឹងផ្តោតសំខាន់ទៅលើការការពារ និងនីតិវិធីនៃបណ្តឹងរបស់គតិយជន។ ក្រៅពីនេះយើងខ្ញុំក៏បានដកស្រង់នៅចំណុចមួយចំនួនចេញពីយោបល់សាស្ត្រាចារ្យណែនាំ សារណាពីមុនៗរបស់សិស្សច្បងនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អត្ថបទច្បាប់ដែលរកបានតាមរយៈវេបសាយ កម្រងមេរៀនជាសៀវភៅ សេចក្តីពន្យល់ និងសេចក្តីកំណត់ដែលទាក់ទងរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី។

ដូចនេះ ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ពីប្រធានបទនេះឱ្យស៊ីជម្រៅក្រុមយើងខ្ញុំធ្វើការបែងចែកចេញជាបីជំពូកធំៗ៖

- ☞ ជំពូកទី១: សញ្ញាណគតិយុត្តនៃការលុបចោលកិច្ចសន្យា
- ☞ ជំពូកទី២: ការលុបចោលកិច្ចសន្យា និងបណ្តឹងតវ៉ារបស់គតិយជន
- ☞ ជំពូកទី៣: ចំណាត់ការលើបណ្តឹងតវ៉ារបស់គតិយជន

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃការលុបចោលកិច្ចសន្យា

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃការលុបចោលកិច្ចសន្យា
## ១.១.លក្ខខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការលុបចោលកិច្ចសន្យា

ការបង្កើតឡើងនូវកិច្ចសន្យាណាមួយ ឬការធ្វើសកម្មភាពឯកតោភាគី កាលបើមានមូលហេតុលុបចោលសកម្មភាពនោះ អ្នកមានសិទ្ធិលុបចោល អាចលុបចោលសកម្មភាពនោះបាន។[1] ការលុបចោលបណ្ដាលមកពីមូលហេតុដូចជា ការបង្ហាញឆន្ទៈដែលមានវិការៈដែលបានកំណត់ចាប់ពីមាត្រា ៣៤៦ រហូតដល់មាត្រា ៣៥១ កង្វះសមត្ថភាពខាងឆន្ទៈដែលមានចែងក្នុងមាត្រា ១៤ និង ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដែលមានចែងក្នុងមាត្រា ១៨ មាត្រា ២៦ និងមាត្រា៣០។

ឧទាហរណ៍ទី១៖ ករណីលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមានវិការៈ ក(អ្នកលក់) បានលក់រថយន្តរបស់ខ្លួនដែលកំពុងប្រើប្រាស់ឱ្យទៅ ខ(អ្នកទិញ)។ រថយន្តរបស់ ក ពណ៌ខ្មៅ រីឯ ខ ចង់បានរថយន្តពណ៌ខៀវ ដូច្នេះហើយដោយសារ ក ចង់លក់រថយន្តរបស់ខ្លួនឱ្យទៅ ខ ក៏បានកុហក ថារថយន្តខ្លួនពណ៌ខៀវ។ ដោយ ក បាននិយាយថា លក់រថយន្ត ១(មួយ) គ្រឿង ពណ៌ខៀវទៅឱ្យ ខ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ហើយបានប្រគល់ប្រាក់គ្រប់ចំនួនទៅឱ្យ ក។ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៣ ក បានប្រគល់រថយន្ត ១(មួយ) គ្រឿង ពណ៌ខ្មៅទៅឱ្យ ខ វិញ។ នៅក្នុងករណីនេះ ខ អាចលុបចោលកិច្ចសន្យាជាមួយ ក បានដោយផ្អែកលើការឆបោក ។

ឧទាហរណ៍ទី២៖ ករណីលុបចោលសកម្មភាពឯកតោភាគីដោយសារបង្ហាញឆន្ទៈមានវិការៈ លោក ក បានគម្រាមលោក ខ ថាបើមិនចុះហត្ថលេខាលើលិខិតលើកលែងបំណុលចំនួន ១០០០ដុល្លារ (មួយពាន់ដុល្លារអាមេរិក) ដែលលោក ក មានចំពោះលោក ខ ទេនោះ ខ្លួននឹងវាយលោក ខ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ លោកខ ក៏បានចុះហត្ថលេខាលើលិខិតលើកលែងបំណុលនោះដោយសារការភ័យខ្លាច។ ក្នុងករណីនេះលោក ខ អាចលុបចោលការលើកលែងបំណុលចំពោះលោក ក ដោយផ្អែកលើការគំរាមកំហែង។

ឧទាហរណ៍ទី៣៖ ករណីលុបចោលសកម្មភាពឯកតោភាគីដោយសារការកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ លោក ក និងលោក ខ បាននិងកំពុងអង្គុយផឹកស្រាជាមួយគ្នា។ លោក ខ ផឹកច្រើនពេក ក៏ស្រវឹងខ្លាំង ហើយក្រោយពីបាត់បង់សមត្ថភាពក្នុងការវិនិច្ឆ័យ គាត់បាននិយាយទៅកាន់លោក ក ថាប្រាក់ចំនួន ១០០០ដុល្លារ(មួយពាន់ដុល្លារអាមេរិក) ដែលបានខ្ចីនោះមិនបាច់សងក៏បានដែរ។

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥៨, កថាខណ្ឌទី១។

ពាក្យដែលលោក ខ បាននិយាយជាការបង្ហាញឆន្ទៈលើកលែងបំណុល។ ក្នុងករណីនេះលោក ខ អាចលុបចោលការលើកលែងបំណុលបាន ។

ឧទាហរណ៍ទី៤៖ ករណីលុបចោលកិច្ចសន្យាដោយសារការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ លោក ក (អ្នកលក់) មានអាយុ២០ឆ្នាំ និងក្មេងស្រី ខ (អ្នកទិញ) មានអាយុ១៥ឆ្នាំ បានបង្កើតកិច្ចសន្យាលក់ទិញទូរស័ព្ទ។ ឪពុកម្តាយរបស់ក្មេងស្រី ខ គឺជាអ្នកមានអំណាចមេបាចំពោះក្មេងស្រី ខ ប៉ុន្តែក្មេងស្រី ខ មិនស្តាប់បង្គាប់របស់ឪពុកម្តាយ ហើយបានលាក់រឿងលក់ទិញទូរស័ព្ទនេះមិនឱ្យម្តាយឪពុកដឹង។ ក្នុងករណីនេះក្មេងស្រី ខ ឬ ឪពុកម្តាយរបស់នាង ខ អាចលុបចោលកិច្ចសន្យាដែលបានធ្វើឡើងជាមួយលោក ក បាន។

**១.១.១.សកម្មភាពដែលអាចលុបចោល**

ការលុបចោល គឺជារបបមួយសម្រាប់ការពារភាគីដែលរងគ្រោះគួរអាណិតអាសូរ ដូច្នេះហើយ ការទទួលស្គាល់ឱ្យតែអ្នករងគ្រោះបែបនេះអាចលុបចោលបាន គឺជាការគ្រប់គ្រាន់។

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោលលុបចោលសកម្មភាពនោះ។[2] ប៉ុន្តែក្នុងករណីដែលអ្នកដែលមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបានហើយ សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។[3] អាចនិយាយបានថាកិច្ចសន្យានោះមានអានុភាពប្រតិសកម្ម។

ឧទាហរណ៍៖ ក្នុងករណីដែលលោក ក (អ្នកលក់) ហើយលោក ខ (អ្នកទិញ) អ្នកទាំងពីរបានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូមួយគ្រឿង។ មុនអនុវត្តកិច្ចសន្យាលោក ក ដែលមានកាតព្វកិច្ចប្រគល់ម៉ូតូ និងលោក ខ ដែលមានកាតព្វកិច្ចបង់ប្រាក់។ កាតព្វកិច្ចរបស់អ្នកទាំងពីរត្រូវបានរំលត់ដោយសារតែលោក ខ លុបចោលកិច្ចសន្យាយោងតាមការឆបោក ដូច្នេះ ការអនុវត្តកាតព្វកិច្ចរបស់លោក ក និងលោក ខ ពុំមានភាពចាំបាច់ទេ។

ប្រសិនបើលោក ក បានប្រគល់ម៉ូតូទៅលោក ខ ហើយលោក ខ បង់ប្រាក់ទៅលោក ក តើនឹងទៅជាយ៉ាងណា? ប្រសិនបើលោក ខ បានលុបចោលកិច្ចសន្យាយោងតាមការឆបោក? នៅក្នុងករណីនេះលោក ក មានកាតព្វកិច្ចប្រគល់ប្រាក់ទៅលោក ខ វិញហើយលោក ខ មានកាតព្វកិច្ចប្រគល់ម៉ូតូទៅលោក ក វិញ កាតព្វកិច្ចប្រគល់យោងតាមសេចក្តីចម្រើនដោយឥតហេតុ ដោយសារតែលោក ខ ជាអ្នក

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥៨, កថាខណ្ឌទី១។

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥៨, កថាខណ្ឌទី២។

ដែលទទួលបាននូវផលប្រយោជន៍ដោយសុចរិត ដូច្នេះត្រូវសងត្រឹមកម្រិតនៃផលប្រយោជន៍ដែលមាន។ ដោយសារតែលោក ក ជាអ្នកដែលទទួលបាននូវផលប្រយោជន៍ដោយទុច្ចរិត ហើយផលប្រយោជន៍ដែលទទួលបាន ដូច្នេះត្រូវសងទាំងការប្រាក់។

**១.១.២.អ្នកមានសិទ្ធិលុបចោល**

ស្របតាមស្មារតីនៃមាត្រាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អ្នកមានសិទ្ធិលុបចោលត្រូវបានបែងចែកចេញជាពីរគឺ៖[4]

អ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមានវិការៈ រួមមាន៖

- ☞ អ្នកបង្ហាញឆន្ទៈដោយមានវិការៈឬ
- ☞ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ
- ☞ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- ☞ អ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ
- ☞ អច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ។

សម្គាល់

អ្នកតំណាងដែលច្បាប់បានកំណត់ គឺផ្តោតសំខាន់លើ អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ។ ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ពោលគឺ ហិតូបត្ថម្ភកៈមានតួនាទីគ្រាន់តែផ្តល់ការយល់ព្រមទៅលើសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ។[5] ដោយឡែក ចំពោះអច្ច័យលាភីសកលក៏អាចអនុវត្តនូវសិទ្ធិលុបចោលបានដែរ។[6] ទោះជាមាត្រា៣៥៩ កថាខណ្ឌទី១ មិនបានកំណត់អំពីអច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈក្តី។

ឧទាហរណ៍៖ លោក ក(អ្នកលក់) បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តជាមួយលោក ខ(អ្នកទិញ)។ លោក ក មានរថយន្តរាង Sedan ប៉ុន្តែលោក ខ គិតថានេះ ជារថយន្តរាង Van ។ នៅក្នុងករណីនេះលោក ខ បានបង្កើតកិច្ចសន្យាដោយមានការភាន់ច្រឡំ (មាត្រា៣៤៦ កថាខណ្ឌទី១)។ ហេតុនេះលោក ខ អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាបានប្រសិនបើលោក ក បានដឹងអំពីការភាន់ច្រឡំនោះ។

---

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥៩។

[5] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណីនិងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌,២០០៩), មាត្រា៣០។

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា១២១២។

បន្ទាប់ពីលោក ខ បានចុះកិច្ចសន្យាជាមួយលោក ក ហើយលោក ខ ត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព និង អ្នកអាណាព្យាបាលទូទៅត្រូវបានជ្រើសតាំងសម្រាប់លោក ខ នោះ។ ក្នុងករណីនេះមួយ អាណាព្យាបាលទូទៅដែលជាអ្នកតំណាងដែលច្បាប់បានកំណត់អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះបាន។

នៅក្នុងករណីដែលលោក ខ ទទួលមរណភាពវិញលោក គ ដែលជាសន្តតិជនតែម្នាក់របស់លោក ខ អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានេះបាន។ ក្នុងករណីដែលលោក ខ បានធ្វើអច្ច័យទានសកលនូវទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅលោក ឃ នោះលោក ឃ ក៏គួរតែអាចអនុវត្តសិទ្ធិលុបចោលបានដែរ (មាត្រា១២១២ កថាខណ្ឌទី១)។

បើលោក ខ បានធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យា(មាត្រា៥១២ កថាខណ្ឌទី១) ឱ្យទៅលោក ង នោះលោក ង ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ដោយមូលហេតុការភាន់ច្រឡំរបស់លោក ខ។

អ្នកដែលមានសិទ្ធិលុបចោល ចំពោះការលុបចោលដោយមូលហេតុគ្មាន សមត្ថភាពក្នុងការបង្ហាញឆន្ទៈ[7] មានដូចខាងក្រោម៖

- ☞ អ្នកបង្ហាញឆន្ទៈ
- ☞ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ
- ☞ ហិតូបត្ថម្ភកៈនៃអ្នកបង្ហាញឆន្ទៈ
- ☞ សន្តតិជនរបស់អ្នកបង្ហាញឆន្ទៈ
- ☞ អច្ច័យលាភីសកលរបស់អ្នកបង្ហាញឆន្ទៈ
- ☞ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ

បញ្ញត្តិនៃមាត្រា៣៥៩ កថាខណ្ឌទី២ មិនបានកំណត់អំពីអ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈទេ ប៉ុន្តែបើមើលគោលគំនិតរបស់មាត្រា ៥១៤ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[8]

ជនដែលត្រូវបានកម្រិតសមត្ថភាពអាចអនុវត្តនូវសិទ្ធិលុបចោលដោយឯករាជ្យបាន ប៉ុន្តែក្រោយពីបានអនុវត្តសិទ្ធិលុបចោលហើយ ជននោះមិនអាចលុបចោលនូវការអនុវត្តសិទ្ធិលុបចោលនោះបានឡើយ។ ឧទាហរណ៍៖ លោក ក (អ្នកលក់) និងលោក ខ (អ្នកទិញ) បានបង្កើតកិច្ចសន្យាលក់ទិញទូ។ ក្នុងករណីដែលលោក ខ

[7] ពាក្យសមត្ថភាពក្នុងការបង្ហាញឆន្ទៈដែលមានចែងក្នុងមាត្រា ៣៥៩ ក.២ នេះ មានន័យដូចគ្នានឹងពាក្យសមត្ថភាពខាងឆន្ទៈ ដែលមានចែងក្នុងមាត្រា១៤ ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។

[8] *កិច្ចប្រជុំក្រុមការងារចម្រុះលើកទី៧* , សាលប្រជុំក្រសួងយុត្តិធម៌, ទំព័រទី៥។

គឺជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នោះលោក ខ និង អ្នកតំណាងដែលច្បាប់បានកំណត់របស់លោក ខ (អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកអាណាព្យាបាលទូទៅ) អាចអនុវត្តសិទ្ធិលុបចោលបាន។

ក្នុងករណីលោក ខ គឺជាជនស្ថិតនៅក្រោមរបបហិតូបត្ថម្ភ នោះលោក ខ ឬ ហិតូបត្ថម្ភកៈរបស់លោក ខ អាចអនុវត្តសិទ្ធិលុបចោលបាន។

ក្នុងករណីលោក ខ បានទទួលមរណភាពលោក គ ដែលជាសន្តតិជនរបស់លោក ខ អាចអនុវត្តសិទ្ធិលុបចោលបាន។ ប្រសិនបើលោក ខ បានធ្វើអច្ច័យទានសកលឱ្យទៅលោក ឃ នោះលោក ឃ អាចអនុវត្តសិទ្ធិលុបចោលបាន។

ប្រសិនបើក្នុងករណីដែលលោក ខ ធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាទៅលោក ឃ (មាត្រា៥១២ កថាខណ្ឌទី១) នោះលោក ឃ អាច អនុវត្តសិទ្ធិលុបចោល ដោយយកមូលហេតុនៃការកម្រិតសមត្ថភាពរបស់លោក ខ បាន (មាត្រា៥១៤)។

ឧទាហរណ៍៖ លោក ក (អ្នកឱ្យខ្ចី) និងលោក ខ (អ្នកខ្ចី) បានធ្វើកិច្ចសន្យាខ្ចីបរិភោគប្រាក់ ហើយលោក គ បានធានាកាតព្វកិច្ចរបស់លោក ខ។ ក្នុងករណីដែលលោក ខ គឺជាអ្នកដែលត្រូវបានកម្រិតនូវសមត្ថភាព ឬលោក ខ បានបង្ហាញឆន្ទៈដែលមានវិការៈហើយប្រសិនបើលោក ខ លុបចោលកិច្ចសន្យាខ្ចីបរិភោគប្រាក់នោះ កាតព្វកិច្ចធានារបស់លោក គ ក៏ត្រូវរលត់ដែរ(មាត្រា៩០៤ កថាខណ្ឌទី៣)។ ប្រសិនបើលោក ខ មិនអនុវត្តនូវសិទ្ធិលុបចោល តើលោក គ អាចអនុវត្តនូវសិទ្ធិលុបចោលក្នុងនាមជាអ្នកធានាបានដែរឬទេ? គឺមិនអាចទេ។ ដោយសារមាត្រា ៣៥៩ មិនបានកំណត់ថាអ្នកធានាគឺជាអ្នកដែលមានសិទ្ធិលុបចោល។ ទោះបីជាលោក គ មិនមានសិទ្ធិលុបចោលក៏ដោយក៏លោក គ អាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានារបស់ខ្លួនបានដោយសំអាងលើការបង្ហាញឆន្ទៈរបស់លោក ខ មានវិការៈ(មាត្រា៩០៥ កថាខណ្ឌទី៤)។

### ១.១.៣. វិធីនៃការលុបចោល ឬការផ្តល់សច្ចានុមតិ

ការលុបចោលកិច្ចសន្យា ត្រូវធ្វើឡើងតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀត។ អានុភាពនៃការលុបចោលកិច្ចសន្យា ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀត។[9] ការលុបចោលនេះ អាចធ្វើបានតាមក្រៅប្រព័ន្ធតុលាការ ឬតាមក្នុងប្រព័ន្ធនៅក្រៅតុលាការក៏បាន។

ភាគច្រើនការលុបចោលដែលធ្វើឡើងដោយភាគីក្រៅផ្លូវតុលាការ ភាគីដែលមានសិទ្ធិលុបចោលគ្រាន់តែជូនដំណឹងអំពីការលុបចោលទៅភាគីម្ខាងទៀត អានុភាពនឹងកកើតឡើងនាពេលនោះរួចជាស្រេច ទោះជាភាគីនោះ

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦០។

យល់ព្រម ឬបដិសេធអំពីការលុបចោលនេះក្តី។ ចំណែកវិធីនៃការជូនដំណឹង ភាគីអាចអនុវត្តបានដោយនិយាយផ្ទាល់មាត់ ឬតាមការផ្ញើអេឡិចត្រូនិចដូចជាSMS, Telegram, messenger, email… ដោយផ្ញើការជូនដំណឹងអំពីឆន្ទៈលុបចោលចំពោះភាគីម្ខាងទៀត។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ភាគីអាចធ្វើតាមវិធីតាមណាក៏បាន ឱ្យតែការបង្ហាញឆន្ទៈលុបចោលនោះ បានទៅដល់ភាគីម្ខាងទៀត។ ជាធម្មតា ភាគីម្ខាងទៀតនៃកិច្ចសន្យាអាចនឹងលើកឡើងអំពីការមិនទទួលបាននូវការជូនដំណឹងរបស់អ្នកលុបចោល ដូច្នេះហើយដើម្បីជៀសវាងពីការណ៍នេះ ភាគី គប្បីប្រើប្រាស់មធ្យោបាយណាដែលងាយស្រួលក្នុងការបង្ហាញជាសក្ខីកម្មបានតាមរយៈការចុះហត្ថលេខាការផ្តិតមេដៃ ឬថតទុកនូវសារដែលបានផ្ញើនោះ ដែលអាចបង្ហាញថាភាគីម្ខាងពិតជាបានទទួលបានការជូនដំណឹងរបស់ខ្លួន។

ចំពោះការលុបចោលតាមប្រព័ន្ធតុលាការ លុះត្រាណាតែគូភាគីមិនអាចព្រមព្រៀងគ្នាបាន ក្នុងករណីអ្នកមានសិទ្ធិលុបចោលអាចទាមទារដោយតុលាការបញ្ជាក់អំពីនត្ថិភាពនៃកិច្ចសន្យាតែប៉ុណ្ណោះ។ ប្រសិនបើក្នុងពាក្យបណ្តឹងរបស់ភាគីប្តឹងទាមទារអោយលុបចោលកិច្ចសន្យា នោះតុលាការនឹងលើកចោលបណ្តឹង ព្រោះបណ្តឹងនៃប្រភេទនេះ វាជាបណ្តឹងផ្ទុយច្បាប់។

### **១.១.៤.អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និងលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ**

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលមានសិទ្ធិលុបចោល បង្ហាញជាស្ថានភាពថាខ្លួនមិនអនុវត្តសិទ្ធិលុបចោល ដោយផ្អែកលើបុរេលក្ខខណ្ឌដែលបានដឹងថាសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។ [10] ឬអាចនិយាយបានថា មានតែអ្នកមានសិទ្ធិលុបចោល ទើបអាចផ្តល់សច្ចានុមតិទៅលើសកម្មភាពដែលអាចលុបចោលបាន។

ដូចដែលបានលើកឡើងក្នុងនៅចំណុច ១.១.២ហើយ អ្នកមានសិទ្ធិលុបចោលត្រូវបានចែងចែកជាពីរគឺអ្នកមានសិទ្ធិលុបចោលដោយមូលហេតុការបង្ហាញឆន្ទៈមានវិការៈ និងជនដែលត្រូវបានកម្រិតសមត្ថភាព។ ករណីដែលមានការបង្ហាញឆន្ទៈដោយមានវិការៈ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលបានដឹងពីមូលហេតុនៃការលុបចោល (ការភាន់ច្រឡំ ការឆបោកជាដើម)។ ចំពោះសកម្មភាពរបស់តតិយជនដែលត្រូវបានកម្រិតសមត្ថភាពវិញ គឺមានមធ្យោបាយចំនួន៣។

មធ្យោបាយទី១ ក្រោយពីពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់មធ្យោបាយដែលធ្វើសច្ចានុមតិដោយខ្លួនឯង។ [11] នៅពេលជនដែលត្រូវបានកម្រិតសកម្មភាព បានដល់នីតិភាព ឬមាន

[10] ក្រុមការងារនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ. *កិច្ចប្រជុំក្រុមការងារចម្រុះលើកទី៧.* ទំព័រទី៦។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦១, កថាខណ្ឌទី១, វាក្យខណ្ឌទី២។

សមត្ថភាពក្នុងការធ្វើសកម្មភាពឡើងវិញ នាំអោយការផ្តល់សច្ចានុមតិជាសកម្មភាពដែលធ្វើអោយសកម្មភាព នោះ មានអានុភាពជាស្ថាពរ។[12]

មធ្យោបាយទី២ មធ្យោបាយធ្វើសច្ចានុមតិដោយអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) ឬ ហិតូបត្ថម្ភកៈរបស់តតិយជនដែលត្រូវបានកម្រិតសមត្ថភាព។[13] ជនដែលត្រូវបានកម្រិតសមត្ថភាព អាចអនុវត្តសិទ្ធិលុបចោលនៅមុនពេលដែលជននោះត្រឡប់មកភាពដើមបាន ប៉ុន្តែមិនអាចផ្តល់សច្ចានុម័តបានទេ។[14] ប៉ុន្តែអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) និង ហិតូបត្ថម្ភកៈ របស់អ្នកដែលត្រូវបានកម្រិតសមត្ថភាព អាចផ្តល់សច្ចានុម័តនៅមុនពេលដែលសមត្ថភាពរបស់តតិយជននោះត្រឡប់មកភាពដើមវិញបាន។[15]

មធ្យោបាយទី៣ មធ្យោបាយធ្វើសច្ចានុមតិដោយជនត្រូវបានកម្រិតសមត្ថភាពដែលទទួលបានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈ។ មធ្យោបាយទី៣នេះ អនីតិជន ឬជននៅក្រោមហិតូបត្ថម្ភ ក៏អាចផ្តល់សច្ចានុមតិបានដែលឱ្យតែមានយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ប៉ុន្តែ ចំពោះជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅវិញ ទោះបីជាក្នុងករណីមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏មិនអាចផ្តល់សច្ចានុមតិបានឡើយ។

### ១.១.៥.សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុម័តបាន សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថាបានផ្តល់សច្ចានុម័តរួចហើយ ក្នុងករណីហេតុដូចខាងក្រោមនេះ៖[16]

១. ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ។

២.ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬការទាមទារអោយភាគីម្ខាងទៀតអនុវត្ត។

---

[12] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី២* (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌,២០០៩), មាត្រា៣៦១។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦១, កថាខណ្ឌទី២។

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦១, កថាខណ្ឌទី១។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦១, កថាខណ្ឌទី២។

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦២។

៣. អនុប្បទាន ឬការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬមួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានឋបនីយផ្លូវចិត្តថា ខ្លួនមិនបានផ្តល់សច្ចានុមតិ [17] នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណៅទាំងបីខាងលើនោះកើតឡើង។

ឧទាហរណ៍ទី១៖ លោក ក (អ្នកលក់) បានឆបោកលោក ខ (អ្នកទិញ) ឱ្យចុះកិច្ចសន្យាលក់ទិញម៉ាស៊ីនត្រជាក់មួយគ្រឿង។ ទោះបីជាលោក ខ បានបង់ប្រាក់ទៅឱ្យលោក ក មុនពេលបានដឹងអំពីការឆបោកក៏ដោយមិនមែនជាសច្ចានុម័តដែលច្បាប់បានកំណត់ដែរ ហេតុនេះលោក ខ អាចអនុវត្តសិទ្ធិលុបចោល ហើយទាមទារឱ្យប្រគល់ប្រាក់មកវិញបាន។ ប៉ុន្តែប្រសិនបើលោក ខ បានបង់ប្រាក់ឱ្យ ក នៅក្រោយពេលដែលបានអំពីការឆបោកហើយនោះ នឹងក្លាយជាសច្ចានុម័តដែលច្បាប់បានកំណត់ ហេតុនេះលោក ខ មិនអាចអនុវត្តសិទ្ធិលុបចោលបានទេ។

ឧទាហរណ៍ទី២៖ លោក ក (អ្នកលក់) បានចុះកិច្ចសន្យាលក់ទិញម៉ូតូជាមួយលោក ខ (អ្នកទិញ)។ នៅពេលចុះកិច្ចសន្យាលោក ខ គឺជាអនីតិជន។ នៅមុនពេលលោក ខ ក្លាយជានីតិជន ទោះបីជាលោក ខ បានបង់ប្រាក់រួចហើយក៏ដោយ មិនត្រូវបានចាត់ទុកថាជាសច្ចានុម័តដោយច្បាប់កំណត់នោះទេ ដូចនេះលោក ខ អាចអនុវត្តសិទ្ធិលុបចោល ហើយទាមទារឱ្យប្រគល់ប្រាក់មកវិញបាន។ ប៉ុន្តែប្រសិនបើលោក ខ បានបង់ប្រាក់ក្នុងនាមជាអ្នកតំណាងរបស់លោក ខ នោះត្រូវចាត់ទុកជាផ្តល់សច្ចានុម័តតាមច្បាប់កំណត់ ហើយទាំងអ្នកមានអំណាចមេបារបស់លោក ខ និងលោក ខ ផ្ទាល់ នឹងមិនអាចអនុវត្តសិទ្ធិលុបចោលបានទេ។

### ១.១.៦.អាជ្ញាយុកាលនៃការរំលត់សិទ្ធិ លុបចោល

អាជ្ញាយុកាល គឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតអោយមានអានុភាពនៃលទ្ធកម្ម ការរលត់សិទ្ធិណាមួយ។ [18] អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល មានន័យថាជាអំឡុងពេលមួយដែលសិទ្ធិលុបចោលកិច្ចសន្យារបស់អ្នកមានសិទ្ធិលុបចោល ត្រូវរលត់ដោយហួសអំឡុងពេលមួយដែលច្បាប់បានកំណត់។ ការទទួលស្គាល់សិទ្ធិក្នុងការលុបចោលកិច្ចសន្យា ទោះបីមូលហេតុវិការៈនៃការបង្ហាញឆន្ទៈក្តី ដោយមូលហេតុអសមត្ថភាពក្តី គឺក្នុងគោលដៅការពារផលប្រយោជន៍របស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ និងជនត្រូវបានកម្រិតសមត្ថភាពផងដែរនោះ ផលប្រយោជន៍របស់ភាគីម្ខាងទៀត ក៏ត្រូវបានយកមកពិចារណាផងដែរ។

---

[17] ឋបនីយផ្លូវចិត្តថា ខ្លួនមិនបានផ្តល់សច្ចានុមតិ មានន័យថាបុគ្គលដែលបានធ្វើសកម្មភាពត្រូវបង្ហាញចេញមកក្រៅថាខ្លួនមិនបានផ្តល់សច្ចានុម័តទេ ទោះជាតាមការសរសេរ ឬការនិយាយក៏ដោយ។

[18] សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ចំណុច១៩៦។

អាជ្ញាយុកាលនៃការរលត់សិទ្ធិត្រូវបានចែងចែកជាពីរៈ [19]

- ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល៣ឆ្នាំ ចាត់តាំងពីពេលដែលខ្លួនអាចផ្តល់សច្ចានុមតិនោះ សិទ្ធិលុបចោលត្រូវរលត់។ ការផ្តល់សច្ចានុមតិរបស់អ្នកបង្ហាញឆន្ទៈដោយវិការៈ នាំអោយមានការរៀបនៅអាជ្ញាយុកាលតាំងពីពេលមកម្ល៉េះ។ ចំណែកអសមត្ថជន (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងហិតូបត្ថម្ភកៈ) គឺរាប់ចាប់គិតពីពេលដែលជននោះមានសមត្ថភាពឡើងវិញ។

ពេលដែលអាចផ្តល់សច្ចានុម័តបាន គឺពេលដែលអ្នកមានសិទ្ធិលុបចោលដឹងអំពីមូលហេតុនៃការលុបចោល ឬ ពេលដែលសមត្ថភាពដែលបានកម្រិត បានត្រឡប់មកភាពដើមវិញ។ នៅមុនពេលលុបចោល ប្រសិនបើមានការប្រគល់វត្ថុដោយផ្អែកលើកិច្ចសន្យាដោយផ្អែកលើកិច្ចសន្យា អ្នកមានសិទ្ធិលុបចោលកិច្ចសន្យាបាន ហើយលើសពីនេះ ចាំបាច់ត្រូវទាមទារឱ្យប្រគល់សេចក្តីចម្រើនដោយឥតហេតុមកវិញ។ ក្នុងអំឡុងពេល ៣ឆ្នាំ ដែល អាចផ្តល់សច្ចានុម័តបាន អ្នកមានសិទ្ធិលុបចោលត្រូវចោលត្រូវអនុវត្តសិទ្ធិលុបចោល ហើយលើសពីនេះ ត្រូវទាមទារឲ្យប្រគល់មកវិញនូវសេចក្តីចម្រើនដោយឥតហេតុមកវិញ។

- ប្រសិនបើហួសអំឡុងពេល១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ។ ប្រសិនបើអនុវត្តសិទ្ធិលុបចោលក្នុងអំឡុងពេល ១០ឆ្នាំនោះ ទោះបីជាហួសអំឡុងពេល១០ឆ្នាំក៏ដោយ ក៏សិទ្ធិទាមទារឲ្យប្រគល់មកវិញនូវសេចក្តីចម្រើនដោយឥតហេតុមិនរលត់ដែរ។ សិទ្ធិទាមទារឲ្យប្រគល់មកវិញនូវសេចក្តីចម្រើនដោយឥតហេតុ នឹងត្រូវរលត់ផ្អែកតាមមាត្រា៣៦៣ កថាខណ្ឌទី១។

ភាពផ្ទុយគ្នារវាងមាត្រា ៣៦៣ កថាខណ្ឌទី១ និងកថាខណ្ឌទី២ គឺក្នុងកថាខណ្ឌទី១ ត្រង់ចំណុចសិទ្ធិលុបចោល និងសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុនឹងត្រូវរលត់ក្នុងអំឡុងពេល ៣ឆ្នាំ។ ចំណែកកថាខណ្ឌទី២វិញ បានកំណត់ត្រឹមតែរយៈពេល១០ឆ្នាំនៃសិទ្ធិលុបចោល តែមិនបានកំណត់អំពីសិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុទេ។

## ១.២.ប្រភេទផ្សេងៗនៃកិច្ចសន្យាដែលអាចលុបចោល

នៅពេលដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយគូភាគីដែលបានព្រមព្រៀងគ្នា ប្រកបដោយកម្មវត្ថុសមស្របទៅតាមច្បាប់ក្តី ក៏អាចនៅមានករណីដែលបណ្តាលអោយមានការលុបចោលបានដែរ។ ការលុបចោលប្រភេទនេះគឺបណ្តាលមកពីវិការៈនៃកិច្ចសន្យា រួមមានការភាន់ច្រឡំ ការឆបោក ការបង្ហាញព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង និងអំពើកេងចំណេញហួសហេតុ។

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៦៣។

### ១.២.១.ការភាន់ច្រឡំ

ការភាន់ច្រឡំ មានន័យថាជាការបង្ហាញនូវឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រឡំអំពីខ្លឹមសារនៃកិច្ចសន្យា[20] ការភាន់ច្រឡំកើតឡើងពីស្ថានភាពដែលភាគីម្ខាងជាអ្នកបង្ហាញឆន្ទៈមានការយល់ខុសដោយខ្លួនឯង។ ដើម្បីអាចលុបចោលកិច្ចសន្យាដែលមានការភាន់ច្រឡំបាន លុះត្រាតែបានបំពេញលក្ខខណ្ឌនីមួយៗនៃការភាន់ច្រឡំដែលរួមមាន ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ការភាន់ច្រឡំចំណុចសំខាន់របស់ភាគី និងការភាន់ច្រឡំរួមគ្នា។

#### ក. ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលមានការភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[21] ដូចនេះលក្ខខណ្ឌនៃការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យាមាន២គឺៈ

១.អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំលើចំណុចសំខាន់ក្នុងកិច្ចសន្យា គឺអ្នកបង្ហាញឆន្ទៈបានយល់ខ្លួនឯងដោយអន្តោម័តទៅលើចំណុចដែលសំខាន់ក្នុងកិច្ចសន្យាដែលខុសពីការពិត ហើយចំណុចសំខាន់នេះគឺជាចំណុចដែលសាធារណៈជនយល់ឃើញថាសំខាន់នៅក្នុងការបង្កើតកិច្ចសន្យា ព្រោះកាលណាមានការភាន់ច្រឡំ គឺផ្ទុយពីឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈក្នុងបង្កើតកិច្ចសន្យា។

២.ភាគីម្ខាងទៀតអាចដឹងអំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ គឺដើម្បីការពារភាគីម្ខាងទៀតកំពុងឱ្យទទួលរងនូវការខូចខាតដែលមិនបានគិតទុកជាមុន នៅពេលដែលអ្នកបង្ហាញឆន្ទៈភាន់ច្រឡំ បង្ហាញឆន្ទៈចង់លុបចោលកិច្ចសន្យា។ លទ្ធភាពក្នុងការដឹងអំពី ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ មិនមែនជាលក្ខខណ្ឌសកម្មដែលត្រូវបានបញ្ជាក់ពីភាគីដែលបង្ហាញឆន្ទៈភាន់ច្រឡំនោះទេ តែជាបន្ទុកក្នុងការបញ្ជាក់របស់ភាគីម្ខាងទៀតក្នុងអះអាងថាខ្លួនបានដឹង ឬ អាចដឹងអំពីការភាន់ច្រឡំនេះ។

អ្វីដែលចាំចាច់ក្នុងការបកស្រាយទៅលើលក្ខខណ្ឌនេះ គឺចំណុចសំខាន់នៃកិច្ចសន្យា។ តើអ្វីដែលអាចចាត់ទុកថាជាចំណុចសំខាន់នៃកិច្ចសន្យា? ចំណុចសំខាន់នៅក្នុងកិច្ចសន្យា គឺជាមនុស្សដែលរួមទាំងភាគីទូទៅទទួលស្គាល់ថាសំខាន់នៅក្នុងកិច្ចសន្យា។ ក្នុងកិច្ចសន្យានីមួយៗគឺ តែងតែមានចំណុចសំខាន់នៃកិច្ចសន្យា ហើយចំណុចសំខាន់នៃកិច្ចសន្យានេះ គឺអាស្រ័យទៅលើប្រភេទនៃកិច្ចសន្យានីមួយៗដែលអាចជា តម្លៃ កម្មវត្ថុ ជាដើម។ ចំពោះកិច្ចសន្យាលក់ទិញ ថ្លៃលក់គឺជាចំណុចសំខាន់សម្រាប់អ្នកទិញ និងអ្នកលក់ទាំងអស់។

[20] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, *ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី មេរៀនភាគ១*.ទំព័រទី២២។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៦, កថាខណ្ឌទី១។

ចំណែកឯ កិច្ចសន្យាការងារវិញ បុគ្គលដែលត្រូវមកធ្វើកិច្ចសន្យាការងារវិញ បុគ្គលដែលត្រូវមកធ្វើការទើបជាចំណុចសំខាន់។

**ខ.ការភាន់ច្រឡំចំណុចសំខាន់របស់ភាគី**

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើញកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[22]

ផ្អែកលើចំណុចខាងលើនេះ ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការភាន់ច្រឡំ អំពីចំណុចសំខាន់នៃកិច្ចសន្យាដែលអ្នកដែលអ្នកបង្ហាញឆន្ទៈយល់ឃើញ ត្រូវបំពេញលក្ខខណ្ឌដូចជា៖

១.អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា គឺអ្នកបង្ហាញឆន្ទៈមានការយល់ឃើញដោយអត្តនោម័តដោយខ្លួនឯងថាជាចំណុចសំខាន់នៃកិច្ចសន្យា ហើយអាចមិនពាក់ព័ន្ធទៅនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យា ព្រោះនេះគឺជាចំណុចសំខាន់សម្រាប់អ្នកបង្ហាញឆន្ទៈប៉ុណ្ណោះ បើមិនមានចំណុចសំខាន់ ក៏អ្នកបង្ហាញឆន្ទៈមិនបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាដែរ តែសម្រាប់សាធារណៈទូទៅវិញអាចគិតថាមិនមែនជាចំណុចសំខាន់ចំណែកចំណុចដែលអ្នកបង្ហាញឆន្ទៈយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាគឺជាករណីដែលត្រូវបាន ហៅថាជាការភាន់ច្រឡំអំពីមូលហេតុ មានន័យថា អ្នកបង្ហាញឆន្ទៈមានការយល់ឃើញថានៅពេលដែលបង្កើតកិច្ចសន្យានេះ មិនអាចប្រើប្រាស់ទៅតាមវត្ថុបំណងរបស់គាត់ ប៉ុន្តែផ្ទុយមកវិញកម្មវត្ថុនៃកិច្ចសន្យានេះ មិនអាចប្រើប្រាស់ទៅតាមវត្ថុបំណងរបស់គាត់បានទេ ហើយគោលបំណងនៃការបង្កើតកិច្ចសន្យានេះ គឺហេតុផលអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈមានលក្ខណៈអរូបី។

២.អំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកបង្ហាញឆន្ទៈពិតជាមានការភាន់ច្រឡំពិតប្រាកដក្នុងការបង្កើតកិច្ចសន្យា ហេតុនេះអ្នកបង្ហាញឆន្ទៈភាន់ច្រឡំ អាចលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែដោយសារតែការលុបចោលរបស់អ្នកបង្ហាញឆន្ទៈដោយភាន់ច្រឡំ គឺកើតឡើងដោយសារតែការភាន់ច្រឡំរបស់ខ្លួនគាត់ ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ហេតុដូច្នោះទើបតម្រូវឱ្យមានលក្ខខណ្ឌ ភាគីម្ខាងទៀតបានដឹងអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបានយល់ឃើញ។

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៦, កថាខណ្ឌទី២។

៣.ភាគីម្ខាងទៀតបានដឹងអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈយល់ឃើញ ជាទូទៅភាគីម្ខាងទៀតមិនអាចដឹងបានទេថា អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈភាន់ច្រឡំអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបានយល់ឃើញ ប្រសិនជាអ្នកបង្ហាញឆន្ទៈមិនបានបង្ហាញអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបានយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាទៅដល់ភាគីម្ខាងទៀត ប៉ុន្តែក៏មានករណីដែលភាគីម្ខាងទៀតបានដឹងថា អ្វីជាចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបានយល់ឃើញ តាមរយៈទម្លាប់ ជំនឿ សាសនា ក្បួនហ៊ុងស៊ុយ អាជីវកម្ម ឬ សកម្មភាពប្រចាំថ្ងៃរបស់អ្នកបង្ហាញឆន្ទៈ ដោយសារធ្វើជំនួញជាប្រចាំជាមួយគ្នា ជាមិត្តស្និទស្នាល ជាញាតិជាដើម។ ក្នុងករណីនេះ ភាគីដែលបង្ហាញ ឆន្ទៈភាន់ច្រឡំត្រូវរកសំអាងបញ្ជាក់ថា ភាគីម្ខាងទៀតបានដឹងអំពីការបង្ហាញឆន្ទៈនេះ។

**គ.ការភាន់ច្រឡំរួមគ្នា**

ក្នុងករណីដែលភាគីទាំងសងខាង មានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងទៀតមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីម្ខាងដែលបានភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[23]

យោងតាមមាត្រា ៣៤៦ កថាខណ្ឌទី៣ខាងលើ លក្ខខណ្ឌដែលត្រូវបំពេញនៃការភាន់ច្រឡំរួមគ្នាមាន៖

១.ភាគីទាំងសងខាងមានការភាន់ច្រឡំ គឺអ្នកបង្ហាញឆន្ទៈ និងភាគីម្ខាងទៀតមានការភាន់ច្រឡំដូចគ្នាទៅលើខ្លឹមសារនៃកិច្ចសន្យា ដូចជាតាវកាលិក ថ្លៃលក់ទិញ ឬ សិទ្ធិជាដើម។

២.ចំណុចដែលមានការភាន់ច្រឡំលើចំណុចសំខាន់នៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា គឺជាផ្នែកសំខាន់ជាសត្យានុម័តនៃកិច្ចសន្យា ជាផ្នែកនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ និងជាមូលហេតុនៃការបង្កើតកិច្ចសន្យា។

ភាគីនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យា ដោយផ្អែកលើការភាន់ច្រឡំរួមបានទោះបីជាភាគីម្ខាងគ្មានលទ្ធភាពដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ។ មានន័យថា ភាគីលុបចោលកិច្ចសន្យាដោយមិនចាំបាច់បញ្ជាក់ថាភាគីម្ខាងទៀតបានដឹង ឬ អាចដឹកអំពីការភាន់ច្រឡំរបស់ខ្លួន ដែលខុសពីការភាន់ច្រឡំ

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៦, កថាខណ្ឌទី៣។

ចំណុចសំខាន់នៃកិច្ចសន្យា និងការភាន់ច្រឡំចំណុចសំខាន់របស់អ្នកបង្ហាញឆន្ទៈឡើយ ដើម្បីបង្កភាពងាយស្រួលក្នុងការសង្គ្រោះប្រយោជន៍របស់ភាគី។

ខាងក្រោមនេះ យើងនឹងលើកយកឧទាហរណ៍ដែលកើតមាននៅក្នុងជីវភាពប្រចាំថ្ងៃមកបង្ហាញតើអាចលុបចោលបាន ឬមិនអាចលុបចោលបាន៖

ឧទាហរណ៍ទី១៖ លោកស្រី ក បានទៅផ្សារជាមួយកូនរបស់គាត់ ពេលដើរដល់តូបលក់នំមួយកន្លែង កូនរបស់លោកស្រី ក បានប្រាប់ថា “ម៉ាក ខ្ញុំចង់ញុាំនំ” លឺដូចនេះលោកស្រី ក បានប្រាប់អ្នកលក់ ខ ថា “បងសូមខ្ចប់នំនេះឱ្យខ្ញុំ៥កញ្ចប់” ប៉ុន្តែតាមពិតនំនោះគឺមិនមែនជានំដែល កូនរបស់លោកស្រី ក ចង់បាននោះទេ តើលោកស្រី ក អាចលុបចោលកិច្ចសន្យានោះបានដែលឬទេ?

ដើម្បីអាចឆ្លើយបានថាតើអាចលុបចោលបានឬទេ យើងត្រូវត្រួតពិនិត្យមើលថាលក្ខខណ្ឌទាំង៣ បានបំពេញឬអត់៖

ក្នុងឧទាហរណ៍ខាងលើយើងឃើញថា៖

- លោកស្រី ក មានការភាន់ច្រឡំ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំថា នំនោះជានំដែលកូនខ្លួនចង់បាន ដែលជាចំណុចសំខាងន់នៃកិច្ចសន្យា ព្រោះថាកូនរបស់គាត់ចង់ញុាំនំផ្សេង មិនមែននំដែលអ្នកលក់ ខ ដាក់ឱ្យនោះទេ។
- អ្នកលក់ ខ ឬបានដឹងថា លោកស្រី ក ចង់ទិញនំអ្វី ព្រោះកូនស្រីរបស់លោកស្រី ក និយាយនោះគឺនៅមុខតូបរបស់អ្នកលក់ ខ ដែល អ្នកលក់ ខ អាចលឺ (លក្ខខណ្ឌទី៣)

ដូចនេះ លោកស្រី ក អាចលុបចោលកិច្ចសន្យានោះបាន។

ឧទាហរណ៍ទី២៖ លោកស្រី ក បានទៅផ្សារទំនើប ពេលដើរដល់កន្លែងដាក់តាំងលក់ផ្លែឈើ គាត់បានគិតថាចង់ទិញក្រូច ផ្ញើកូនគាត់ ហើយបានយកពីរកញ្ចប់ទៅកន្លែងគិតលុយ ដោយមិនបានដឹងថាផ្លែឈើដែលប្រកស្រាប់នោះគឺជាផ្លែក្រូច ឬមិនមែនក្រូចនោះទេ។ តើលោកស្រី ក អាចលុបកិច្ចសន្យានោះបានទេ?

ក្នុងឧទាហរណ៍ទី២នេះ យើងឃើញថា៖

- លោស្រី ក បានភាន់ច្រឡំ (លក្ខខណ្ឌទី១)
- ការភាន់ច្រឡំថា ក្រូច ដែលជាចំណុចសំខាន់នៃកិច្ចសន្យា (លក្ខខណ្ឌទី២)
- ភាគីម្ខាងទៀត ពុំអាចស្ថិតក្នុងស្ថានភាពដែលអាចដឹងការភាន់ច្រឡំរបស់លោកស្រី ក នោះទេ ព្រោះយើងដឹងថា នៅផ្សារទំនើប អ្នកទិញជាអ្នកជ្រើសរើសទំនិញដោយខ្លួនឯង ទើបយកទៅគិតលុយ ដែល

ភាគីខាងអ្នកលក់ ឬអ្នកគិតលុយមិនដឹងថាយើងចង់បានអ្វីខ្លះនោះទេ (លក្ខខណ្ឌទី៣ មិនត្រូវបាន បំពេញ)។

ដូចនេះ លោកស្រី ក មិនអាចលុបចោលកិច្ចសន្យានោះទេ។

**១.២.២.ការឆបោក**

ការបង្ហាញឆន្ទៈដោយការឆបោក គឺជាការបង្ហាញឆន្ទៈយល់ខុសពីការពិតនៃកិច្ចសន្យាតាមរយៈការកុហកបោកប្រាស់ ការប្រើប្រាស់ល្បិចកល ឬ តាមមធ្យោបាយផ្សេងៗដោយបុគ្គលណាម្នាក់។ ការឆបោក អាចប្រព្រឹត្តដោយភាគីនៃកិច្ចសន្យា ឬ តតិយជន។[24]

អ្នកបង្ហាញឆន្ទៈដោយការឆបោករងនូវភាពអយុត្តិធម៌ និងគួរឱ្យការពារជាងអ្នកបង្ហាញឆន្ទៈដោយការភាន់ច្រឡំ។ ដូចនេះហើយ ទោះបីជាអ្នកបង្ហាញឆន្ទៈរងនូវការឆបោកលើចំណុចសំខាន់នៃកិច្ចសន្យាក្តី ចំណុចដែលខ្លួនយល់ឃើញក្តី ឬ ចំណុចដែលមិនសំខាន់ក្តី ក៏អ្នកបង្ហាញឆន្ទៈដោយការឆបោកអាចលុបចោលកិច្ចសន្យាបានផងដែរ ប្រសិនជាបំពេញលក្ខខណ្ឌដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី។

ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការឆបោកដោយភាគី ត្រូវបំពេញលក្ខខណ្ឌដូចជាៈ[25]

១.សកម្មភាពបោកបញ្ឆោត ឬ បំភ្លៃការពិតរបស់ភាគីនៃកិច្ចសន្យា គឺអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈយល់ព្រមបង្កើតកិច្ចសន្យាដោយសារតែការទទួលព័ត៌មានក្លែងក្លាយ មធ្យោបាយក្លែងបន្លំ ឬ សកម្មភាពបោកប្រាស់ពីភាគីនៃកិច្ចសន្យា។

២.ចេតនានៃការឆបោករបស់ភាគីនៃកិច្ចសន្យា ចេតនានៃការឆបោករបស់ភាគីនៃកិច្ចសន្យា គឺភាគីនៃកិច្ចសន្យាមានចេតនា ក្នុងការកុហក បោកប្រាស់ ឬ ប្រើប្រាស់កលល្បិចផ្សេងៗ រៀបចំឱ្យដូចជាការពិត ដើម្បីឱ្យអ្នកបង្ហាញឆន្ទៈជឿទុកចិត្តថាជាការពិត។ ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកាបង្ហាញឆន្ទៈបានយល់ខុសពីការពិតជាក់ស្តែង ហើយបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ ដោយមិនដឹងថាការយល់ខ្លួនខុសពីការពិត ផ្ទុយពីអ្វីដែលមានឡើយ។

៣. ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកបង្ហាញឆន្ទៈបានយល់ខុសពីការពិតជាក់ស្តែង ហើយបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ ដោយមិនដឹងថាការយល់ខ្លួនខុសពីការពិត ផ្ទុយពីអ្វីដែលមានឡើយ។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៧។

[25] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, *ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី មេរៀនភាគ១*. ទំព័រទី៣២-៣៣។

៤.ការបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ គឺខុសពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈ ទោះបីជាអ្នកបង្ហាញឆន្ទៈដោយការឆបោក គឺមានកំហុសដោយសារធ្វើប្រហែសឱ្យគេបោកក៏ដោយ ក៏ចាំបាច់ត្រូវតែការពារអ្នកបង្ហាញឆន្ទៈដែរ ព្រោះភាគីម្ខាងទៀតនៃកិច្ចសន្យា គឺមានគំនិតទុច្ចរិត ក្នុងការឆបោកអ្នកបង្ហាញឆន្ទៈឱ្យបង្កើតកិច្ចសន្យា។

**១.២.៣.ព័ត៌មានមិនពិត**

ព័ត៌មានមិនពិត សំដៅទៅលើព័ត៌មានក្លែងក្លាយដែលខុសពីការពិត។ ព័ត៌មានមិនពិតអាចកើតមានឡើងទោះបីជាអ្នកបង្ហាញព័ត៌មានមិនពិតមានចេតនា ឬ គ្មានចេតនាកុហក បោកប្រាស់ ឬ ក្លែងបន្លំអ្នកបង្ហាញឆន្ទៈក៏ដោយ។ ប៉ុន្តែកាលណាអ្នកបង្ហាញព័ត៌មានមិនពិតមានចេតនាកុហក បោកប្រាស់ ឬ ក្លែងបន្លំ ការផ្តល់ព័ត៌មានមិនពិតបែបនេះនឹងប្រែក្លាយជាការឆបោកដូចដែលបានរៀបរាប់ខាងលើ។

ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការផ្តល់ ព័ត៌មានមិនពិត ត្រូវបំពេញលក្ខខណ្ឌដូចជា៖[26]

១.ការបង្ហាញព័ត៌មានមិនពិតដោយភាគីនៃកិច្ចសន្យា គឺភាគីនៃកិច្ចសន្យាបានបង្ហាញព័ត៌មានក្លែងក្លាយដល់អ្នកបង្ហាញឆន្ទៈ ដោយសារតែការទទួល ឬ ការដឹងព័ត៌មានក្លែងក្លាយដូចគ្នា។

២.ពុំចាំបាច់មានចេតនារបស់អ្នកបង្ហាញព័ត៌មានពិតទេ គឺអ្នកបង្ហាញព័ត៌មានមិនពិតគ្មានចេតនាកុហក បោកប្រាស់ ក្លែងបន្លំដល់អ្នកបង្ហាញឆន្ទៈទេ។

៣.ភាគីយល់ច្រឡំអង្គហេតុ គឺអ្នកបង្ហាញឆន្ទៈជឿជាក់ថា ព័ត៌មានមិនពិតគឺជាព័ត៌មានពិត ដោយយល់ឃើញខុសពីការពិតជាក់ស្តែង។

៤.ភាគីនឹងមិនបង្ហាញឆន្ទៈទេបើមិនការយល់ច្រឡំគឺ ដោយសារតែការភាន់ច្រឡំតាមរយៈការទទួលព័ត៌មានមិនពិតដែលសំខាន់ ទៅលើចំណុចសំខាន់ក្នុងកិច្ចសន្យា ទើបអ្នកបង្ហាញឆន្ទៈយល់ព្រមបង្ហាញឆន្ទៈ តែបើមិនមានការភាន់ច្រឡំនោះទេអ្នកបង្ហាញឆន្ទៈមិនបង្ហាញឆន្ទៈឡើយព្រោះខុសពីបំណងក្នុងការបង្កើតកិច្ចសន្យារបស់គាត់។

ការលុបចោលកិច្ចសន្យាដោយសារទទួលព័ត៌មានមិនពិត គឺចាំបាច់ត្រូវពិនិត្យទៅចេតនារបស់អ្នកបង្ហាញព័ត៌មានមិនពិត ព្រោះកាលណាតែអ្នកបង្ហាញព័ត៌មានមិនពិតមានចេតនាបង្ហាញព័ត៌មានមិនពិតសកម្មភាពនោះនឹងក្លាយទៅជាការឆបោកវិញ។ ម្យ៉ាងទៀតក្នុងករណីដែលអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យាដោយសារតែការទទួលព័ត៌មានមិនពិត សកម្មភាពនោះអាចក្លាយទោជាការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា។ ការលុបចោលដោយឆបោក ឬ ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យាមិនត្រូវបានអនុញ្ញាតជានិច្ចកាលឡើយ លើកលែងតែបានបំពេញលក្ខខណ្ឌនៃការលុបចោលទាំងនេះ។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៨, កថាខណ្ឌទី១។

ហេតុនេះហើយទោះបីជាអ្នកបង្ហាញឆន្ទៈមិនមានលក្ខខណ្ឌគ្រប់គ្រាន់លុបចោលកិច្ចសន្យាដោយឆបោក ឬ ភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ក៏អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដែរ ប្រសិនជាអ្នកថបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយសារតែទទួលបានព័ត៌មានមិនពិតពីភាគីម្ខាងទៀត។

### ១.២.៤.ការរំលោភបំពានលើស្ថានភាព

ការរំលោភបំពានលើស្ថានភាព កើតឡើងដោយសារមានភាពមិនស្មើគ្នារវាងភាគីនៃកិច្ចសន្យា លើឋានៈ ឬ ស្ថានភាពផ្សេងៗ ដូចជាស្ថានភាពសេដ្ឋកិច្ចឬតួនាទី មុខតំណែង ជាដើម។

ក្នុងការរំលោភបំពានលើស្ថានភាព ភាគីម្ខាងទៀតនៃកិច្ចសន្យាមិនបានប្រើប្រាស់នូវពាក្យសំដី ឬ កាយវិការណាមួយ ដើម្បីបំភិតបំភ័យអ្នកបង្ហាញឆន្ទៈឡើយ ប៉ុន្តែអ្នកបង្ហាញឆន្ទៈភ័យខ្លាចដោយសារតែភាគីម្ខាងទៀតមានតួនាទី ឋានៈ យសសក្តិខ្ពស់ជាងខ្លួន។

ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការរំលោភបំពានលើស្ថានភាព ត្រូវបំពេញលក្ខខណ្ឌរួមមាន៖[27]

១.ការរំលោភបំពានដោយភាគីម្ខាងនៃកិច្ចសន្យាដែលឋានៈ ឬ ស្ថានភាពដែលមានអាទិភាពជាង គឺភាគីម្ខាងទៀតបានប្រើប្រាស់នូវឋានៈ ឬ ស្ថានភាពដែលមានអាទិភាពជាងខាងផ្នែកសង្គម ឬ ផ្នែកសេដ្ឋកិច្ច ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ[28] អាចជាតួនាទី មុខតំណាង បទពិសោធន៍ខាងផ្នែកធ្វើជំនួញ ទៅលើអ្នកបង្ហាញឆន្ទៈ។

២.ការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវឋានៈ ឬ ស្ថានភាពពីភាគីម្ខាងដែលរំលោភបំពានកិច្ចសន្យា គឺជាការដែលភាគីម្ខាងទៀតនៃកិច្ចសន្យាប្រើប្រាស់ដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ទៅលើអ្នកបង្ហាញឆន្ទៈ។

៣.ភាគីម្ខាងដែលរំលោភបំពានមានចេតនា គឺភាគីម្ខាងទៀតត្រូវតែមានចេតនាប្រើប្រាស់ឋានៈ ឬ ស្ថានភាពដែលខ្លួនមានអាទិភាពជាង គាបសង្កត់ទៅលើអ្នកបង្ហាញឆន្ទៈ ប៉ុន្តែបើភាគីម្ខាងគ្មានចេតនាប្រើប្រាស់ឋានៈ ឬ ស្ថានភាពដែលខ្លួនមានអាទិភាពជាងទេ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយការក្រែងចិត្តចង់ផ្គាប់ផ្គុំ ឬ ដោយសារសំលឹងឃើញផលប្រយោជន៍ផ្សេង នេះមិនមែនជាចេតនារបស់ភាគីម្ខាងនោះ។

៤.អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈដោយការភ័យខ្លាច និងមិនអាចតបតបាន គឺភាគីម្ខាងទៀតនៃកិច្ចសន្យាបានបង្ខំដោយប្រយោល ដូចជាការដកចេញពីមុខតំណែង ការបញ្ឈប់មុខងារ ឬ ការផ្តាច់ជំនួញ របស់អ្នកបង្ហាញឆន្ទៈ ដែលធ្វើឱ្យអ្នកបង្ហាញឆន្ទៈមិនអាចប្រឆាំងតបតបាន ហើយមិនអាចបង្ហាញឆន្ទៈដោយសេរី ព្រោះមានការភ័យខ្លាច។

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៩, កថាខណ្ឌទី១។

[28] *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,* (ភ្នំពេញ៖ ២០១១), មាត្រា៤១, កថាខណ្ឌទី៤។

### ១.២.៥.ការគម្រាមកំហែង

ការគម្រាមកំហែង គឺជាការសំឡុតបំភ័យ ក្នុងគោលដៅឱ្យអ្នកបង្ហាញឆន្ទៈមានភាពភ័យខ្លាច តាមរយៈការប្រើប្រាស់ពាក្យសម្តី ឬ កាយវិការចំពោះអ្នកបង្ហាញឆន្ទៈផ្ទាល់ ញាតិរបស់អ្នកបង្ហាញឆន្ទៈ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងជាមួយអ្នកបង្ហាញឆន្ទៈ។ ការគម្រាមកំហែងអាចប្រព្រឹត្តឡើងដោយភាគីផ្ទាល់ ឬ អាចប្រព្រឹត្តឡើងដោយតតិយជន។

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែង ពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់ជនអាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[29]

លក្ខខណ្ឌនៃការគម្រាមកំហែងមានៈ

១. សកម្មភាពគម្រាមកំហែងដោយខុសច្បាប់ ដោយភាគី ឬដោយតតិយជន គឺជាសកម្មភាពដែលធ្វើឡើងដោយភាគីនៃកិច្ចសន្យា ឬ ដោយតតិយជន តាមរយៈពាក្យសម្តី កាយវិការ សារអេឡិចត្រូនិច ឬ សម្តែងចេញតាមលិខិត រូបភាព វត្ថុ ដើម្បីឱ្យអ្នកបង្ហាញឆន្ទៈមានការភ័យខ្លាចដោយសារតែការគម្រាបទាក់ទងនឹងជីវិតរាងកាយ ទ្រព្យសម្បត្តិ កិត្តិយស សេរីភាពជាដើម។

២. ចេតនានៃការគម្រាមកំហែង គឺជាចេតនាគម្រាមរបស់ភាគីម្ខាងដើម្បីឱ្យអ្នកបង្ហាញឆន្ទៈ មានការភ័យខ្លាច ករណីខ្លះភាគីម្ខាងអាចមិនមានចេតនាទេ ប៉ុន្តែសកម្មភាពដែលភាគីម្ខាងបានធ្វើមើលទៅហាក់ដូចជាគម្រាមកំហែងតែគ្មានបំណងធ្វើឱ្យអ្នកបង្ហាញឆន្ទៈភ័យខ្លាច ដូចជាការបង្ហាញឱ្យឆន្ទៈដឹងថាខ្លួនមានភ្ជាប់អាវុធមកតាមជាមួយ មិនមែនាជាចេតនានៃការគម្រាមកំហែង។

៣. អ្នកបង្ហាញឆន្ទៈមានការភ័យខ្លាចចំពោះការគម្រាមកំហែង ប្រសិនបើការបង្ហាញឆន្ទៈ ធ្វើឡើងដោយឥទ្ធិភាពអ្វីធ្វើឱ្យការភ័យខ្លាច គឺជាការគម្រាមកំហែង ប៉ុន្តែប្រសិនបើអ្នកបង្ហាញឆន្ទៈមិនមានការភ័យខ្លាច ឬ ព្រួយបារម្ភចំពោះការគម្រាមកំហែងទេ ទោះបីជាភាគីម្ខាងទៀតបានគម្រាមកំហែងក៏ដោយ មិនមែនជាការគម្រាមកំហែងទេ ព្រោះមិនមានទំនាក់ទំនងរវាងការភ័យ និងការបង្ហាញឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈទេ។

៤. ការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែង គឺអ្នកបង្ហាញឆន្ទៈយល់ព្រមក្នុងការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងរបស់ភាគីម្ខាងទៀត ឬ តតិយជន។ ការលុបចោលកិច្ចសន្យាដោយសារតែមានការគម្រាមកំហែងពីសំណាក់តតិយជន ទោះបីជាភាគីម្ខាងទៀតមិនបានដឹងអំពីការគម្រាមកំហែងក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងអាចលុបចោលកិច្ចសន្យាបានដែរ។

---

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥០។

### ១.២.៦.អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

លក្ខខណ្ឌដែលជាមូលហេតុនាំឱ្យមានការលុបចោលកិច្ចសន្យា ដោយផ្អែកលើអំពើកេងយកចំណេញហួសហេតុ៖[30]

១.ការឆ្លៀតឱកាសរបស់ភាគីម្ខាងនៃកិច្ចសន្យាចំពោះភាគីម្ខាងទៀត ដែលកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬ ការខ្វះការពិសោធន៍។ ការឆ្លៀតឱកាសនេះមិនមានការដាក់សម្ពាធ ឬការកម្រិតលើការសម្រេចចិត្តរបស់ភាគីឡើយ។

២.ឆន្ទៈនៃអំពើកេងយកចំណេញហួសហេតុ គឺជាការចាំបាច់ត្រូវមានឆន្ទៈបង្កើតកិច្ចសន្យាដោយឆ្លៀតឱកាសដែលអ្នកបង្ហាញឆន្ទៈកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះពិសោធន៍។

៣.ការបង្ហាញឆន្ទៈដោយសាររងសម្ពាធក្នុងការសម្រេចចិត្តដោយសេរី គឺមានតែក្នុងករណីដែលសម្ពាធក្នុងការសម្រេចចិត្តដោយសេរីដែលកើតចេញពីការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះពិសោធន៍នោះមានឥទ្ធិពលដល់ការបង្ហាញឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈតែប៉ុណ្ណោះទេ ទើបកើតឡើងនូវអំពើកេងយកចំណេញហួសហេតុបាន។

៤.អ្នកធ្វើអំពើកេងយកចំណេញហួសហេតុទទួលបានប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ជាធម្មតា នៅក្នុងកិច្ចការជំនួញ អ្នកធ្វើជំនួញតែងតែចង់លក់វត្ថុ ឬ សេវាឱ្យបានថ្លៃ និងឱ្យបានច្រើន ដើម្បីទទួលបានចំណេញច្រើន ដូចនេះ មិនមែនមានន័យថា ទំនិញដូចគ្នា បែរជាលក់ថ្លៃជាងភ្ញៀវផ្សេងទៀតហើយហៅថា ជាអំពើកេងយកយកចំណេញហួសហេតុភ្លាមនោះទេ។ តើកម្រិតប៉ុណ្ណាទើបក្លាយជាអំពើកេងយកចំណេញហួសហេតុនោះ គឺចាំបាច់ត្រូវសិក្សាទៅតាមករណីនីមួយៗ។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥១។

# ជំពូកទី២

# ការលុបចោលកិច្ចសន្យា និង បណ្តឹងតវ៉ា
# របស់តតិយជន

# ជំពូកទី២
# ការលុបចោលកិច្ចសន្យា និង បណ្តឹងតវ៉ារបស់តតិយជន

## ២.១.តតិយជន និង ការលុបចោលកិច្ចសន្យា

ការបង្ហាញឆន្ទៈដោយមានវិការៈរបស់ភាគីម្ខាងនៃកិច្ចសន្យា អាចជាមូលហេតុនៃការលុបចោលកិច្ចសន្យាបាន ដូចដែលបានរៀបរាប់នៅជំពូកទី១ខាងលើ។ កិច្ចសន្យា ដែលបង្កើតឡើងដោយតតិយជនក៏ត្រូវបានការពារផងដែរ។ ប៉ុន្តែ មិនមែនគ្រប់តតិយជនទាំងអស់សុទ្ធតែទទួលបានការការពារឡើយ។ ជាក់ស្តែងដូចជាតតិយជនដែលមានកំហុស ឬហៅម្យ៉ាងទៀតថាជនទុច្ចរិត មិនអាចអះអាងចំពោះការលុបចោលបានទេ។

### ២.១.១.តតិយជន និង ការលុបចោលដោយការភាន់ច្រឡំ

កិច្ចសន្យាដែលមានការភាន់ច្រឡំ អាចលុបចោលបាន ហើយសកម្មភាពដែលត្រូវបានលុបចោលនោះត្រូវចាត់ទុកជាមោឃៈភាពតាំងពីដំបូង។ [31] ក្នុងករណីលុបចោលកិច្ចសន្យា តាវកាលិកដែលទទួលបានពីកិច្ចសន្យានឹងក្លាយជាសេចក្តីចម្រើនឥតហេតុ។ [32] បើបុគ្គលដែលទទួលបានផលប្រយោជន៍មានចេតនា ឬកំហុសចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះដោយភ្ជាប់ជាមួយនឹងការប្រាក់។ លើសពីនេះ បើបុគ្គលដែលត្រូវបាត់បង់ផលប្រយោជន៍ទទួលការខូចខាត បុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាត។[33]

ការលុបចោលកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំនោះមិនអាចអះអាងនូវការលុបចោលចំពោះតតិយជនបានឡើយ។[34]

ឧទាហរណ៍៖ ក បានលក់វត្ថុអនុស្សាវរីយ៍ឱ្យ ខ ហើយ បានលក់បន្តទៅឱ្យ គ។ ក្រោយមកកិច្ចសន្យារវាង ក និង ខ ត្រូវបានលុបចោល។ ករណីនេះ គ គឺជាតតិយជនមុនពេលលុបចោលកិច្ចសន្យា។

ឧទាហរណ៍៖ ក បានលក់វត្ថុអនុស្សាវរីយ៍ឱ្យ ខ បន្ទាប់មកកិច្ចសន្យារវាង ក និង ខ ត្រូវបានលុបចោល។ ក្រោយមក ខ បានលក់បន្តទៅឱ្យ គ។ ករណី គ គឺជាតតិយជនក្រោយពេលលុបចោលកិច្ចសន្យា។

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៥៨, កថាខណ្ឌទី១។
[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៧៣៦, កថាខណ្ឌទី២។
[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៧៣៧, កថាខណ្ឌទី២ និងកថាខណ្ឌទី៣។
[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៦, កថាខណ្ឌទី៤។

ក្នុងវាក្យខណ្ឌទី៣ កថាខណ្ឌទី៤ នៃមាត្រា៣៤៦ មិនមានបែងចែកតតិយជនមុន ឬក៏ក្រោយការលុបចោលកិច្ចសន្យានោះទេ ហេតុនេះហើយអាចធ្វើការបកស្រាយថាគឺសំដៅទៅលើតតិយជនទាំងមុន និងក្រោយការលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែបើយោងតាមទ្រឹស្តីច្បាប់ ស្ថានភាពរបស់តតិយជនមុនពេលលុបចោលកិច្ចសន្យា និងតតិយជនក្រោយពេលលុបចោលកិច្ចសន្យាមានភាពខុសគ្នា ហេតុនេះហើយគួរធ្វើការបែងចែកឱ្យដាច់ពីគ្នា។ ពាក្យថា តតិយជន ក្នុងវាក្យខណ្ឌទី២ កថាខណ្ឌទី៤ នៃមាត្រា៣៤៦ មានគំនិតមួយលើកឡើងថា សំដៅទៅលើតែតតិយជននៅមុនពេលលុបចោលកិច្ចសន្យាតែប៉ុណ្ណោះ។

**២.១.២.តតិយជន និង ការលុបចោលដោយការឆបោក**

**ក. ការឆបោកដោយតតិយជន**

ការឆបោកដោយតតិយជន សំដៅទៅលើជនទាំងឡាយដែលក្រៅពីភាគីម្ខាងទៀត បានប្រើមធ្យោបាយឆបោក ដើម្បីធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ដោយសារមធ្យោបាយឆបោកនោះ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន។

នៅក្នុងករណីនៃការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានតែក្នុងករណីដែលភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការឆបោកនេះ។[35] ដោយសារតែវាមិនមានភាពចាំបាច់ការការពារភាគីម្ខាងទៀត ចំពោះករណីនេះ។

ឧទាហរណ៍៖ លោក ខ បានពិភាក្សាជាមួយលោក គ ដែលជាមិត្តភក្តិថា “ខ្ញុំកំពុងតែមានបញ្ហាដោយសារលោក ក មិនព្រមលក់ផ្ទះរបស់គាត់មកឱ្យខ្ញុំសោះ”។ លោក គ គិតថានឹងជួល លោក ខ ហើយ បាននិយាយបោកប្រាស់លោក ក ថា “ផ្ទះរបស់គាត់ កាលពីមុនបានសាងសង់រោងចក្រផលិតឱសថ ហើយបច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ”។ ហេតុនេះលោក ក បានសម្រេចលក់ផ្ទះរបស់ខ្លួនឱ្យទៅលោក ខ ។ លោក ខ មិនបានដឹងអំពីការណ៍ដែលលោក គ បោកប្រាស់ លោក ក ទេ ប៉ុន្តែស្រាប់តែលោក ក បានប្រាប់ថាព្រមលក់ផ្ទះ ឱ្យទៅលោក ខ ភ្លាមនោះលោក ខ ក៏បានគិតថាលោក គ បានជួយអ្វីមួយជាមិនខាន។ តើលោក ក អាចលុបចោលកិច្ចសន្យាជាមួយលោក ខ ដោយមូលហេតុនៃការឆបោកបានដែរឬទេ?

ដើម្បីពិភាក្សាទៅលើករណីសិក្សាខាងលើ យើងគប្បីពិនិត្យទៅលើលក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ៣៤៧ កថាខណ្ឌទី២ ក្នុងនោះមាន៖

លក្ខខណ្ឌទី១៖ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន។

លក្ខខណ្ឌទី២៖ ករណីភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈបានដឹង ឬអាចដឹងអំពីការឆបោក។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៧, កថាខណ្ឌទី២។

ដូច្នេះក្នុងករណីនេះ យោងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី យើងត្រូវបញ្ជាក់ថាតើ លោក ក អាចដឹងអំពីការឆបោករបស់លោក គ ដែរឬទេ។ ហើយឃើញថាលោក ក បានសម្រេចចិត្តលក់ផ្ទះ គឺដោយសារការឆបោករបស់លោក គ មានន័យថាលោក ក បានដឹងអំពីការឆបោករបស់លោក គ។លក្ខខណ្ឌទី១ ត្រូវបានបំពេញ។ បន្ទាប់មក យើងត្រូវពិនិត្យមើលលក្ខខណ្ឌទី២បន្តទៀត។ តើលោក ខ បានដឹងពីការឆបោករបស់លោក គ ដែរឬទេ? តាមអង្គហេតុលោក ខ បានគិតថាលោក គ បានជួយអ្វីម្យ៉ាងជាមិនខាន"។ មានន័យថាលោក ខ អាចដឹងអំពីការឆបោករបស់លោក គ។ ដូច្នេះលក្ខខណ្ឌទី២ចំណុច២ ត្រូវបានបំពេញ។ សរុបសេចក្តីមកលោក ក អាចលុបចោលកិច្ចសន្យាជាមួយលោក ខ ដោយមូលហេតុនៃការឆបោកបាន។

**ខ.ការឆបោក និង តតិយជន**

ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោកមិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។[36]

ឧទាហរណ៍៖ បន្ទាប់ពីលោក ខ បានបោកប្រាស់លោក ក ហើយបានទិញផ្ទះលោក ក ហើយ លោក ខ ក៏បានលក់ផ្ទះនោះទៅឱ្យលោក គ។ លោក គ មិនបានដឹងអំពីការណ៍ដែលលោក ខ បោកប្រាស់លោក ក ទេ ហើយក៏មិនមានកំហុសក្នុងការមិនដឹងនេះដែរ។ ក្រោយមកលោក ក បានលុបចោលកិច្ចសន្យាជាមួយលោក ខ ដោយមូលហេតុនៃការឆបោក។ តើលោក ក អាចអះអាងពីការលុយបោលដោយការឆបោកចំពោះលោក គ បានដែរឬទេ?

ដំបូងយើងត្រូវពិនិត្យមើលលក្ខខណ្ឌនៃការឆបោកយោងតាមមាត្រា៣៤៧ កថាខណ្ឌទី៣ ដូចខាងក្រោម៖

តតិយជនជាជនទុច្ចរិត ឬ តតិយជនមានកំហុសអំពីការឆបោក

តាមអង្គហេតុខាងលើ យើងឃើញថាលោក គ ជាជនសុចរិត ដូច្នេះ លក្ខខណ្ឌទី១ មិនត្រូវបានបំពេញទេ។ យើងត្រូវពិនិត្យមើលលក្ខខណ្ឌទី២ទៀត។ តាមអង្គហេតុដដែលលោក គ ជាជនគ្មានកំហុសអំពីការឆបោកនេះទេ ដូច្នេះលក្ខខណ្ឌទី២ក៏មិនត្រូវបានបំពេញទៀត។ សរុបមក យើងអាចសន្និដ្ឋានបានថាលោក ក មិនអាចអះអាងអំពីការលុបចោលកិច្ចសន្យាជាមួយលោក គ បានទេ។

ដូចគ្នានឹងឧទាហរណ៍ខាងលើ លោក ក បានលុបចោលកិច្ចសន្យាជាមួយលោក ខ ដោយមូលហេតុនៃការឆបោក។ ប៉ុន្តែការចុះបញ្ជីកម្មសិទ្ធិលើផ្ទះ បានផ្ទេរពីលោក ក ទៅឱ្យលោក ខ ហើយមិនទាន់បានផ្ទេរត្រលប់ទៅឱ្យលោក ក វិញទេ។ លោក ខ ប្រើប្រាស់ការចុះបញ្ជីផ្ទះនោះជារបស់ខ្លួន ហើយក៏លក់ផ្ទះនោះ ទៅឱ្យលោក

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៧, កថាខណ្ឌទី៣។

គ និងបានផ្ទេរការចុះបញ្ជីទៅឱ្យលោក គ។ លោក គ បានដឹងអំពីការណ៍ដែលលោក ខ បានប្រគល់ផ្ទះ និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបានដែរឬទេ? លោក ក អាចអះអាងពីការលុបចោលដោយការឆបោកហើយទាមទារលោក គ ឱ្យប្រគល់ផ្ទះ និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបានព្រោះលោក គ បានដឹងអំពីការណ៍ដែរលោក ខ បានបោកប្រាស់លោក ក។

លោក ក អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារលោក គ ឱ្យប្រគល់ផ្ទះ និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបាន ព្រោះលោក គ បានដឹងអំពីការណ៍ដែលលោក ខ បានបោកប្រាស់លោក ក ។ ប្រើបានទាំងតតិយជនក្រោយ និងមុនពេលលុបចោលកិច្ចសន្យាបាន។ ប្រសិនបើ ប្រើមាត្រា១៣៤ និងមាត្រា១៣៥ ដើម្បីកំណត់អ្នកឈ្នះអ្នកចាញ់ទោះលោក គ ជាជនសុចរិត ឬទុច្ចរិតក៏ដោយលោក គ យល់ថាលោក ខ មានការចុះបញ្ជី ដូច្នេះលោក គ ត្រូវបានការពារ។ បើលោក គ បានចុះបញ្ជីមុនលោក ក មិនអាចអះអាងពីការលុបចោល និងមិនអាចទាមទារឱ្យលោក គ ផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបានទេ។ បើប្រើមាត្រា៣៥៣ កថាខណ្ឌទី២ លោក គ បានទិញផ្ទះពីជនដែលមិនមានសិទ្ធិលោក ខ ដូច្នេះលោក ក អាចទាមទារការចុះបញ្ជីពីលោក គ មកវិញបានដោយការអនុវត្តដោយប្រយោល ហើយលោក គ ជាជនទុច្ចរិតមិនត្រូវបានការពារទេ។

### ២.១.៣.ព័ត៌មានមិនពិត និង តតិយជន

ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអនុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ។[37] មានន័យថា ប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលដោយសារហេតុផលនៃព័ត៌មានមិនពិត អានុភាពនៃការលុបចោលកិច្ចសន្យាអាចតតាំងបាន មិនត្រឹមភាគីម្ខាងទៀតប៉ុណ្ណោះទេ ថែមទាំងតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់ផងដែរ។[38]

### ២.១.៤.ការរំលោភបំពានលើស្ថានភាព និង តតិយជន

ការលុបចោលនៃកិច្ចសន្យាមិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសបានឡើយ។ [39] ចែងអំពីអានុភាពនៃការលុបចោលកិច្ចសន្យាដែលភាគីម្ខាងបានធ្វើដោយហេតុថា ភាគីម្ខាងទៀតបានប្រើឋានៈខ្លួនខាងផ្នែកសេដ្ឋកិច្ច ជាអាទិ៍ ចំពោះតតិយជន។ ដើម្បីសម្របសម្រួលជាមួយនឹងផលប្រយោជន៍របស់តតិយជនដែលជាជនសុចរិតហើយគ្មានកំហុស កថាខណ្ឌនេះចែងថា ការលុបចោលកិច្ចសន្យា ដោយហេតុនៃការរំលោភបំពានលើស្ថានភាព មិនអាចតតាំងចំពោះតតិយជនសុចរិតដែលគ្មានកំហុសបានឡើយ។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៨, កថាខណ្ឌទី៣។

[38] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ២ គន្ថីទី៤, ឆ្នាំ២០១០, មាត្រា៣៤៨, កថាខណ្ឌទី៣។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៣៤៩, កថាខណ្ឌទី២។

### ២.១.៥.ការគំរាមកំហែង និង តតិយជន

ការគំរាមកំហែង៖ អ្នកបានបង្ហាញឆន្ទៈ ដោយគ្មានការភាន់ច្រឡំទេ ប៉ុន្តែ វាផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាច ដែលបង្កឡើងដោយភាគីម្ខាងទៀត ឬ តតិយជន។[40]

ឧទាហរណ៍៖ លោក ក ចង់ទិញដីរបស់លោក ខ ទោះបីជាលោក ឱ្យតម្លៃថ្លៃយ៉ាងណាក៏ដោយក៏លោក ខ នៅមិនព្រមលក់ដីរបស់ខ្លួននោះទេ ដោយហេតុតែចង់បានដី លោក ក បានគំរាមលោក ខ ថាស្រលាញ់ដីជាង ឬស្រលាញ់ជីវិតជាងបន្ទាប់មកលោក ខ ក៏មានការភ័យខ្លាចខ្លាំងក៏សម្រេចចិត្តលក់ដីឱ្យទៅលោក ក។

ចំពោះការពារតតិយជនទាក់ទងទៅ និងការគំរាមកំហែងនេះមិន មានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជននោះទេ ទោះបីតតិយជនបានបង្កើតទំនាប់ទំនងក្នុងកិច្ចសន្យា ដោយផ្អែកលើកិច្ចសន្យាដែលអាចត្រូវបានគេលុបចោលនោះ។ ក្នុងករណីនេះ អ្នកបង្ហាញឆន្ទៈ អាចអះអាងពីអានុភាពនៃការលុបចោល ចំពោះតតិយជនបានទោះបីជាតតិយជននោះ គឺជាជនសុចរិតក៏ដោយ។ មូលហេតុដែលមិនមានបញ្ញត្តិ សំរាប់ការពារតតិយជនទាក់ទងនឹងការគំរាមកំហែង គឺជាអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយគ្មានការភាន់ច្រឡំ នៅក្នុងករណីនៃការឆបោក ឬការភាន់ច្រឡំ។[41]

### ២.១.៦.អំពើកេងយកចំណេញហួសហេតុ និង តតិយជន

បើយើងក្រឡេកទៅមើល មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណី បញ្ញត្តិនៃមាត្រានេះ គឺមិនបានកំណត់ឡើយអំពីវត្តមានរបស់តតិយជន ហេតុនេះហើយអំពើកេងយកចំណេញហួសហេតុមិនអាចជាមូលដ្ឋានក្នុងការអះអាងចំពោះតតិយជនបានឡើយ។

## ២.២.បណ្តឹងតវ៉ារបស់តតិយជន

គោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺដើម្បីដកចេញពីការអនុវត្តដោយបង្ខំនូវកម្មវត្ថុជាក់ណាមួយពីការអនុវត្តដោយបង្ខំ។ បណ្តឹងតវ៉ារបស់តតិយជនមានសារៈសំខាន់ ពីព្រោះករណីនេះ សំរាប់ស្ថាប័នអនុវត្តមិនពិនិត្យមើលថា អ្នកណាជាម្ចាស់កម្មសិទ្ធិនោះទេ ប៉ុន្តែគ្រាន់តែពិនិត្យល័ក្ខខណ្ឌទំរង់សំរាប់ចាប់ផ្តើមការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ។

អ្នកដែលអាចសុំឱ្យអនុវត្តដោយបង្ខំបាន គឺអ្នកដែលមានលិខិតអនុវត្តជាសាលក្រម ឬឯកសារផ្សេងទៀតដែលបង្ហាញពីលទ្ធភាពខ្ពស់នៃអត្ថិភាពនៃមូលដ្ឋានសំរាប់ការអនុវត្តដោយបង្ខំ។ ជាទូទៅគេអាចនិយាយ

[40] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១ ,(ខែមេសា ឆ្នាំ២០១៣), ១៣១។

[41] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគី១*, បោះពុម្ពកែសម្រួលលើកទី១ (រាជធានីភ្នំពេញ៖ ខែមេសា ឆ្នាំ២០១៣), ១៣២។

ថា សិទ្ធិរបស់ម្ចាស់បំណុលត្រូវបានគេទទួលស្គាល់រួចហើយ ហើយសិទ្ធិនោះមានអនុភាព ដោយមិនចាំបាច់ធ្វើការពិនិត្យជាលក្ខណៈសារធាតុបន្ថែមទៀតនោះទេ។

នេះជាមូលហេតុដែលស្ថាប័នអនុវត្ត មិនពិនិត្យជាលក្ខណៈសារធាតុនូវទំនាក់ទំនងគតិយុត្ត ថាតើមានអត្ថិភាព ឬ នត្ថិភាពនោះទេ ហើយក៏មិនពិនិត្យ មើលថាតើកម្មវត្ថុនៃការអនុវត្តជារបស់កូនបំណុល ឬអត់នោះទេផងដែរ។ មូលហេតុដែលនាំឱ្យមានមធ្យោបាយមួយចំនួនសំរាប់តតិយជនដើម្បីដាក់ពាក្យបណ្ដឹងតវ៉ាគឺដើម្បីផ្ដល់ឱកាសឱ្យតតិយជនធ្វើការតវ៉ាក្នុងករណីដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះគឺជារបស់គាត់។

បន្ទាប់មកតតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដូចជាសិទ្ធិលើការបញ្ចាំ សិទ្ធិជួលអចិន្ត្រៃយ៍ជាដើម អាចដាក់ពាក្យបណ្ដឹងតវ៉ាដើម្បីដកចេញ ឬលុបចោលនូវការអនុវត្តដោយបង្ខំ។ នេះហៅថា បណ្ដឹងតវ៉ារបស់តតិយជន។

**២.២.១.មូលហេតុ**

មូលហេតុដែលនាំឱ្យមានបណ្ដឹងតវ៉ារបស់តតិយជន ត្រង់ចំណុចដែលថា "ជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ"។[42]

ផ្អែកតាមបញ្ញត្តិខាងលើអាចយល់បានថា មូលហេតុដែលនាំឱ្យមានបណ្ដឹងតវ៉ារបស់តតិយជន គឺការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ នឹងបំពានសិទ្ធិរបស់តតិយជន។ ក្នុងករណីនេះយើងត្រូវបែងចែកជាពីរករណី៖

ករណីដែលលិខិតអនុវត្តមានខ្លឹមសារឱ្យប្រគល់វត្ថុ សាលក្រមចុងក្រោយបានសម្រេចបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុជាក់លាក់ណាមួយឱ្យទៅម្ចាស់បំណុល។ សិទ្ធិរាំងស្ទះដល់ការប្រគល់វត្ថុនេះអាចជាសិទ្ធិកាន់កាប់ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិជួល ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិឃាត់ទុក និងសិទ្ធិលើការបញ្ចាំ។

សិទ្ធិទាំងឡាយដែលបានរៀបរាប់ខាងលើ ធ្វើឱ្យការកាន់កាប់វត្ថុរបស់តតិយជនមានភាពត្រឹមត្រូវតាមច្បាប់ ហេតុនេះ ការប្រគល់វត្ថុទៅឱ្យម្ចាស់បំណុលនៃការអនុវត្តនាំឱ្យបំពានដល់សិទ្ធិរបស់តតិយជន។ ចំណែកឯហ៊ីប៉ូតែក និងឯកសិទ្ធិ ពុំមែនជាសិទ្ធិដែលរាំងស្ទះដល់ការប្រគល់ទេ។

ហេតុដែលនាំឱ្យអះអាងថា ឯកសិទ្ធិ និងហ៊ីប៉ូតែក មិនមែនជាសិទ្ធិដែលរាំងស្ទះដល់ការប្រគល់វត្ថុឱ្យម្ចាស់បំណុលនៃការអនុវត្ត គែដោយសារតែម្ចាស់ឯកសិទ្ធិ និងម្ចាស់បំណុលហ៊ីប៉ូតែក ពុំមានសិទ្ធិដោយផ្ទាល់

[42] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៦៥, កថាខណ្ឌទី១។

ក្នុងការកាន់កាប់វត្ថុទេ គ្រាន់តែមានសិទ្ធិទទួលការសងពីទ្រព្យដែលជាកម្មវត្ថុនៃឯកសិទ្ធិ ឬហ៊ីប៉ូតែក ដោយមានអាទិភាពជាងម្ចាស់បំណុលដទៃទៀតប៉ុណ្ណោះ។[43]

ក្នុងករណីដែលការអនុវត្តដោយបង្ខំ មានកម្មវត្ថុជាការលក់ដោយបង្ខំនូវអចលនវត្ថុជាក់លាក់ណាមួយវិញនោះ តតិយជនដែលមានកម្មសិទ្ធិលើវត្ថុ អាចយកមូលហេតុមកសំអាងដើម្បីតវ៉ាកុំឱ្យមានការអនុវត្តដោយបង្ខំ ព្រោះថា ការអនុវត្តដោយបង្ខំនឹងធ្វើឱ្យខ្លួនបាត់បង់នូវកម្មសិទ្ធិលើវត្ថុ។ ផ្ទុយទៅវិញប្រសិនបើតតិយជន មានត្រឹមតែសិទ្ធិកាន់កាប់ សិទ្ធិលើការបញ្ចាំ ផលុបភោគ ជាអាទិ៍ ការលក់ដោយបង្ខំនូវអចលនវត្ថុ មិនបណ្តាលឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជនឡើយ។ ហេតុនេះ ការអះអាងអំពីសិទ្ធិកាន់កាប់ ឬ សិទ្ធិលើការបញ្ចាំ ឬ ផលុបភោគ មិនមែនជាមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជនទេ។

**២.២.២.សមត្ថកិច្ច**

ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ារបស់តតិយជន អាស្រ័យទៅតាមសមត្ថកិច្ចរបស់ស្ថាប័នអនុវត្តដោយបង្ខំ។[44]

ក្នុងករណីដែលតុលាការអនុវត្តមានសមត្ថកិច្ចក្នុងការអនុវត្តដោយបង្ខំ ជនដែលដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងការអនុវត្តដោយបង្ខំ ត្រូវដាក់ពាក្យបណ្តឹងតវ៉ារបស់ខ្លួនទៅតុលាការអនុវត្ត។[45]

សំណុំរឿងទាក់ទងនឹងពាក្យបណ្តឹងតវ៉ារបស់តតិយជន គឺជាសំណុំរឿងមួយដាច់ដោយឡែកពីសំណុំរឿងអនុវត្តដោយបង្ខំ ប៉ុន្តែសំណុំរឿងនេះ ស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តដែរ។ ក្នុងន័យនេះ សំណុំរឿងទាក់ទងនឹងបណ្តឹងតវ៉ារបស់តតិយជន និងត្រូវបែងចែកនៅស្ថាប័ននៃតុលាការអនុវត្ត។[46]

ប្រសិនបើ អាជ្ញាសាលាមានសមត្ថកិច្ចក្នុងការអនុវត្តដោយបង្ខំ ជនដែលដាក់ពាក្យបណ្តឹងតវ៉ាត្រូវដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។

**២.២.៣.ការដាក់ពាក្យបណ្តឹង**

ការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ត្រូវធ្វើឡើងដោយអនុលោមទៅតាមវិធីទូទៅសម្រាប់ការដាក់ពាក្យបណ្តឹង។ ចំពោះខ្លឹមសារនៃសាលក្រមដើមចោទទាមទារឲ្យតុលាការចេញ ត្រូវរៀបរាប់អំពីការសុំឲ្យចេញសាលក្រមខ្លឹមសារថា "ការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនេះត្រូវហាមឃាត់"។

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៨១ និងមាត្រា ៨៤៣។

[44] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៦៥, កថាខណ្ឌទី២។

[45] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៣៦, កថាខណ្ឌទី២។

[46] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦។

លើសពីនេះទៅទៀត ក៏អាចទាមទារឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិរបស់បុគ្គលណាម្នាក់ផងដែរ។ ចំពោះមូលហេតុនៃការទាមទារ ត្រូវរៀបរាប់អំពីទំនាក់ទំនងគតិយុត្តជាសារជាតុ ដែលជាមូលហេតុនាំឲ្យការអនុវត្តបង្ខំនោះត្រូវហាមឃាត់។

### ២.២.៤.ពន្ធដាក់ពាក្យបណ្តឹង

ពេលដាក់ពាក្យបណ្តឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ដោយគណនាទៅតម្លៃនៃកម្មវត្ថុនៃបណ្តឹងដែលបានកំណត់ក្នុងចំណុចនីមួយៗ។[47]

ការកំណត់អំពីតម្លៃកម្មវត្ថុនៃបណ្តឹង នៅក្នុងបណ្តឹងតវ៉ារបស់តតិយជន អាចជួបនឹងបញ្ហាខ្លះដែលត្រូវស្រាយបំភ្លឺឱ្យបានច្បាស់លាស់។ ជាទូទៅ តម្លៃកម្មវត្ថុនៃបណ្តឹង គឺជាតម្លៃនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ារបស់តតិយជន។ ប៉ុន្តែប្រសិនបើ តម្លៃនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ារបស់តតិយជន មានតម្លៃច្រើនជាងសិទ្ធិលើបំណុល តម្លៃកម្មវត្ថុនៃបណ្តឹងគឺជាតម្លៃនៃសិទ្ធិលើបំណុល។

ឧទាហរណ៍ៈ ប្រសិនបើ ម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិទាមទារប្រាក់ចំនួន៣០ លានរៀល ពីកូនបំណុលនៃការអនុវត្តតាមអំណាចសាលក្រម ហើយម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅលើដីមួយកន្លែងដែលមានតម្លៃ ២០ លានរៀល ប៉ុន្តែជនបានអះអាងថា ដីនោះជាកម្មសិទ្ធិរបស់ខ្លួន ហើយបានដាក់ពាក្យបណ្តឹងតវ៉ា។ ក្នុងករណីនេះ តម្លៃ ២០ លានរៀល គឺជាផលប្រយោជន៍អតិបរមាដែលតតិយជនអាចទទួលបានពីការដាក់ពាក្យបណ្តឹងរបស់ខ្លួន។

ហេតុនេះ តម្លៃកម្មវត្ថុនៃបណ្តឹងតវ៉ារបស់តតិយជន គឺ ២០លានរៀល ពីព្រោះគោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺគ្រាន់តែបញ្ឈប់នូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិជាក់លាក់ណាមួយតែប៉ុណ្ណោះ។

ផ្ទុយទៅវិញ ប្រសិនបើដីដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំមានតម្លៃ ៥០ លានរៀលវិញនោះផលប្រយោជន៍នៃការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនមានតម្លៃត្រឹមតែ ៣០លានតែប៉ុណ្ណោះ ដែលជាតម្លៃនៃសិទ្ធិលើបំណុលទាមទារដោយម្ចាស់បំណុលនៃការអនុវត្ត ពីព្រោះអ្វីដែលត្រូវបានបំពាននោះគឺគ្រាន់តែតម្លៃមួយផ្នែកនៃ ៣០ លានរៀល នៃតម្លៃកម្មវត្ថុតែប៉ុណ្ណោះ។

### ២.២.៥.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ

គោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយហេតុថា តតិយជនមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះដល់ការធ្វើអនុប្បទាន ឬប្រគល់។[48]

[47] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦១ កថាខណ្ឌទី១។

នៅក្នុងការសរសេរពាក្យបណ្ដឹងតវ៉ារបស់តតិយជន ដើមចោទត្រូវគោរពតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយយោងតាមមាត្រា ៣៣៥ នៃក្រមដែលឱ្យយកបញ្ញត្តិពីគន្ថីទី២ ដល់គន្ថីទី៤ នៃក្រមនេះយកមកអនុវត្តដូចគ្នាចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ។

ក្នុងន័យនេះ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញគឺ "ការអនុវត្តដោយបង្ខំដោយចុងចំលើយចំពោះអចលនវត្ថុដែលពិណ៌នានៅក្នុងបញ្ជីអចលនវត្ថុ ដោយផ្អែកលើសាលក្រមចុងក្រោយមិនត្រូវបានអនុញ្ញាត"។

ក្នុងករណីដែលតុលាការយល់ឃើញថា ការអនុវត្តដោយបង្ខំនឹងបំពានដល់កម្មសិទ្ធិ ឬសិទ្ធិរបស់តតិយជន តុលាការនឹងចេញសាលក្រមដែលមានខ្លឹមសារដូចរៀបរាប់ខាងលើ។ ជាចុងបញ្ចប់ការអនុវត្តដោយបង្ខំទៅលើវត្ថុដែលមានពាក់ព័ន្ធនឹងសិទ្ធិរបស់តតិយជន នឹងមិនអាចធ្វើទៅបាន គឺមានន័យថា សិទ្ធិរបស់តតិយជនជាដើមចោទនៅក្នុងបណ្ដឹងតវ៉ានោះ នឹងត្រូវបានធានាការពារ។

ពេលខ្លះ សេចក្ដីសំរេចរបស់តុលាការទៅលើបណ្ដឹងតវ៉ារបស់តតិយជន ពុំមានផលប៉ះពាល់ណាមួយដល់លិខិតអនុវត្តទេ ប៉ុន្តែពេលខ្លះការសម្រេចមិនអនុញ្ញាតការអនុវត្តដោយបង្ខំអាចមានផលប៉ះពាល់ដល់លិខិតអនុវត្តទាំងមូលបាន។

[48] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៦៥ កថាខណ្ឌទី១។

# ជំពូកទី៣

# ចំណាត់ការលើបណ្តឹងតវ៉ារបស់តតិយជន

# ជំពូកទី៣
# ចំណាត់ការលើបណ្តឹងតវ៉ារបស់តតិយជន

បណ្តឹងតវ៉ារបស់តតិយជន ជាបណ្តឹងរបស់តតិយជនដែលមានកម្មសិទ្ធិ ជាអាទិ៍ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ទាមទារកុំឱ្យអនុញ្ញាតការអនុវត្តទៅលើទ្រព្យសម្បត្តិជាក់លាក់ ដោយផ្អែកលើលិខិតជាក់លាក់ ចំពោះម្ចាស់បំណុលនៃការអនុវត្ត។

បណ្តឹងតវ៉ារបស់តតិយជន គឺធ្វើឡើងតាមនីតិវិធីរដ្ឋប្បវេណីទូទៅ។ ដូចនេះ ការវិនិច្ឆ័យលើបណ្តឹងនេះ ត្រូវយកក្រមនីតិវិធីរដ្ឋប្បវេណីគន្ថីទី២ និងគន្ថីទី៣ មកអនុវត្ត ហើយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ និងការទាញហេតុផលផ្ទាល់មាត់ គឺត្រូវតែមានជាចាំបាច់។[49]

បណ្តឹងតវ៉ានេះ អាចដាក់បានមិនត្រឹមតែករណីការអនុវត្តដោយបង្ខំក្នុងន័យចង្អៀតនោះទេ ការអនុវត្តសិទ្ធិប្រាតិភោគ និងការអនុវត្តរក្សាការពារក៏អាចដាក់បានដែរ។

## ៣.១. ការរៀបចំពាក្យបណ្តឹង

### ៣.១.១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

#### ក. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ សំដៅលើអង្គហេតុដែលបញ្ជាក់ពីខ្លឹមសារនៃសិទ្ធិលើបំណុលដែលទាមទារ ហើយអង្គហេតុនេះ ត្រូវតែសរសេរបញ្ជាក់ឱ្យច្បាស់លាស់នៅក្នុងពាក្យបណ្តឹង។[50] ហេតុនេះ ដើមចោទត្រូវសរសេរបញ្ជាក់អំពីអត្តសញ្ញាណរបស់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។ ប៉ុន្តែ ជាក់ស្តែងអង្គហេតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ហើយវាមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើការបញ្ជាក់។

#### ខ. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

អង្គហេតុដែលជាមូលហេតុនៃការទាមទារ សំដៅលើអង្គហេតុដែលបង្កើតនូវសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។ នៅក្នុងពាក្យបណ្តឹងរបស់ដើមចោទ គប្បីសរសេរបញ្ជាក់អំពីអង្គហេតុដែលបង្ហាញឱ្យឃើញអំពីការចាប់ផ្តើមអនុវត្តដែរ លើកលែងតែករណីដែលលិខិតអនុវត្តមានខ្លឹមសារជាការប្រគល់នូវវត្ថុជាក់លាក់ណាមួយ។[51]

---

[49] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, គន្ថីទី២ និងគន្ថីទី៣។

[50] *សេចក្តីពន្យល់អំពីចំណុចសំខាន់ៗនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា*.(ភ្នំពេញ៖ ២៨ ធ្នូ ២០០៥), ទំព័រទី៣២។

[51] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥, កថាខណ្ឌទី៣។

## ៣.២. សមត្ថកិច្ចសាលាជម្រះក្តី

ក្នុងករណីតុលាការជាស្ថាប័នដែលត្រូវអនុវត្តដោយបង្ខំ នាំឲ្យតុលាការនោះជាអ្នកអនុវត្ត។ ក្នុងករណីអាជ្ញាសាលាជាស្ថាប័នដែលត្រូវអនុវត្តដោយបង្ខំ នាំឲ្យសាលាដំបូងដែលជាអាជ្ញាសាលានោះស្ថិតនៅ គឺជាសមត្ថកិច្ច។[52]

## ៣.៣. ពេលដាក់ពាក្យបណ្តឹង

កម្មវត្ថុនៃការអនុវត្តមិនអាចកំណត់បានទេ បើសិនមិនមែននៅក្រោយពេលចាប់ផ្តើមអនុវត្ត។ ក្នុងករណីកម្មវត្ថុនៃការអនុវត្តអាចកំណត់បាននៅដំណាក់កាលលិខិតអនុវត្ត (ការអនុវត្តដោយបង្ខំនៃសិទ្ធិទាមទារឱ្យប្រគល់ ឬការប្រគល់វត្ថុដាក់លាក់) យើងអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាននៅមុនពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ។ បណ្តឹងតវ៉ារបស់តតិយជនមិនអាចដាក់បាន ក្រោយពេលបញ្ចប់នៃការអនុវត្តដោយបង្ខំទេ។

## ៣.៤. ការរួមបញ្ចូលបណ្តឹង

បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងរដ្ឋប្បវេណី ហេតុដូច្នេះបណ្តឹងនេះអាចរួមបញ្ចូលជាមួយបណ្តឹងផ្សេងបាន។ ប្រភេទនៃបណ្តឹងដែលមានលក្ខណៈសមស្របដើម្បីបញ្ចូលបានមានដូចជា បណ្តឹងទាមទារឱ្យបញ្ជាក់អំពីកម្មសិទ្ធិលើវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តដែលជនបានដាក់ចំពោះម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ឬការទាមទារសំណងការខូចខាត (អំពើអនីត្យានុកូល) ដោយផ្អែកលើការអនុវត្តដោយបង្ខំដែលមិនត្រឹមត្រូវដែលជនបានដាក់ចំពោះម្ចាស់បំណុលនៃការអនុវត្តជាអាទិ៍។

## ៣.៥. ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងរដ្ឋប្បវេណី ហេតុនេះយើងអាចផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងបានប្រសិនបើលក្ខខណ្ឌបានបំពេញ។[53] ឧទាហរណ៍៖ ចំពោះការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង យើងអាចពិចារណាបានក្នុងករណីដែលការអនុវត្តបានបញ្ចប់នៅពេលដែលបណ្តឹងតវ៉ារបស់តតិយជនកំពុងតែដំណើរការនោះ បណ្តឹងតវ៉ារបស់តតិយជននឹងក្លាយជាខុសច្បាប់ ហេតុនេះដើមចោទអាចដាក់ពាក្យសុំផ្លាស់ប្តូរកម្មវត្ថុបណ្តឹងទៅជាការទាមទារសំណងការខូចខាត បើសិនជាដើមចោទទទួលរងការខូចខាតដោយសារតែ ការអនុវត្តនោះ។

## ៣.៦. ការវិនិច្ឆ័យបណ្តឹងតវ៉ារបស់តតិយជន

បណ្តឹងតវ៉ារបស់តតិយជននឹងត្រូវបានទទួលស្គាល់ ក្នុងករណីដែល៖

១. ជន (ដើមចោទ) មានសិទ្ធិដាក់លាក់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត

២. ហើយសិទ្ធិនោះត្រូវទទួលយកការអនុវត្តដែលបំពាននោះ។

---

[52] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៥, កថាខណ្ឌទី២។

[53] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៨៤, កថាខណ្ឌទី១។

៣. ជននោះមិនមានមូលហេតុនឹងត្រូវទទួលយកការអនុវត្តដែលបំពាននោះ។ ជន (ដើមចោទ) ត្រូវតែអះអាងអំពីសិទ្ធិលើកម្មវត្ថុនៃការអនុវត្ត អំពីការទទួលរង ការបំពានខុសច្បាប់សារជាតុនៅក្នុងទំនាក់ទំនងជាមួយម្ចាស់បំណុលនៃការអនុវត្ត(ចុងចម្លើយ)។

ចំណុចសំខាន់ដើម្បីសម្រេចថាទទួលស្គាល់ ឬមិនទទួលស្គាល់បណ្តឹងតវ៉ារបស់តតិយជនមាន២ ចំណុចដូចខាងក្រោមៈ

១. តើដើមចោទមានសិទ្ធិដែលអាចតតាំងជាមួយម្ចាស់បំណុលនៃការអនុវត្ត (សិទ្ធិដែលអាចរាំងស្ទះការផ្ទេរអនុប្បទាន ឬ ប្រគល់វត្ថុដែលជាកម្មវត្ថុ) ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដែរ ឬទេ?

២. តើសិទ្ធិខាងលើរបស់ដើមចោទត្រូវបានបំពានដោយការអនុវត្តដែរឬទេ?

## ៣.៧. អង្គហេតុចម្បង

អង្គហេតុចម្បងនៃការតវ៉ារបស់របស់តតិយជនគឺៈ

**ក. អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

ការចាប់ផ្តើមនីតិវិធីអនុវត្តជាក់ស្តែង (ករណីទូទៅ) និងអង្គហេតុដែលជាមូលហេតុនៃការកកើតសិទ្ធិដែលរាំងស្ទះការផ្ទេរអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុ។

**ខ. ការតវ៉ា**

ការបញ្ចប់នីតិវិធីអនុវត្ត និងអង្គហេតុរំលត់សិទ្ធិ ឬឧបសគ្គនៃការកកើតសិទ្ធិដែលរាំងស្ទះការផ្ទេរ អនុប្បទាន ឬប្រគល់របស់ដើមចោទ។

## ៣.៨. ហេតុនៃការតវ៉ា

### ៣.៨.១. កម្មសិទ្ធិ

បុគ្គលដែលមានកម្មសិទ្ធិចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ផ្អែកតាមលិខិតអនុវត្តចំពោះអ្នកដទៃ អាចដាក់បណ្តឹងតវ៉ារបស់តតិយជន និងដកចេញការអនុវត្តលើកម្មវត្ថុខាងលើ។[54] លើកលែងករណីកម្មសិទ្ធិកម្មសិទ្ធិនោះអាចតតាំងចំពោះម្ចាស់បំណុល (ចុងចម្លើយ)បាន។ អនុវត្តដូចគ្នាចំពោះសិទ្ធិប្រត្យក្សផ្សេងទៀត។ ធម្មតាបើសិនជាការអនុវត្តដោយបង្ខំនោះ មិនធ្វើឱ្យបំពានដល់កម្មសិទ្ធិទេ បណ្តឹងតវ៉ារបស់តតិយជនដែលធ្វើឡើងដោយកម្មសិទ្ធិករមិនត្រូវបានទទួលស្គាល់ទេ។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា២០៦។

### ៣.៨.២. សិទ្ធិកាន់កាប់

អ្នកមានសិទ្ធិកាន់កាប់ដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី អាចដាក់បណ្តឹងតវ៉ារបស់តតិយជន បើសិនជាសិទ្ធិកាន់កាប់ត្រូវបានបំពានដោយការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះអ្នកដទៃ។

### ៣.៨.៣. សិទ្ធិជួលអចិន្ត្រៃយ៍ និងសិទ្ធិផលុបភោគ ជាអាទិ៍

ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍អាទិ៍ គឺមិនបំពានដល់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងនោះទេ ហេតុនេះ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍មិនអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានឡើយ។ ប៉ុន្តែ ជាករណីលើកលែង ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ជាអាទិ៍ អាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន បើសិនការអនុវត្តដោយបង្ខំលើកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ជាដើម ដោយផ្អែកតាមលិខិត អនុវត្តចំពោះអ្នកដទៃ ធ្វើឱ្យបំពានដល់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងនោះ។

### ៣.៨.៤. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ជាគោលការណ៍ យើងអាចពិចារណ៍ដូចគ្នានឹងកម្មសិទ្ធិករ។ មានន័យថា អ្នកដែលមានសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត អាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន ក្នុងករណីសិទ្ធិទាំងនោះត្រូវបានបំពាន ដោយសារការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តរបស់អ្នកដទៃ។

### ៣.៨.៥. សិទ្ធិហ៊ីប៉ូតែក និងឯកសិទ្ធិ

ម្ចាស់សិទ្ធិហ៊ីប៉ូតែក និងឯកសិទ្ធិមានសិទ្ធិទទួលបានការសងដោយអាទិភាពពីវត្ថុដែលជាកម្មវត្ថុ ហេតុនេះ ជាគោលការណ៍ម្ចាស់សិទ្ធិហ៊ីប៉ូតែក ជាអាទិ៍មិនអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានទេ ពីព្រោះសិទ្ធិហ៊ីប៉ូតែក ជាអាទិ៍ មិនត្រូវបានបំពានដោយការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែកនោះទេ។

ប៉ុន្តែ នៅពេលដែលការអនុវត្តត្រូវបានធ្វើឡើងតែមួយផ្នែក និងបំបែកវត្ថុដែលជាកម្មវត្ថុនោះ ហើយកម្មវត្ថុនោះនៅមានតម្លៃជាប្រាតិភោគនៅពេលមិនបំបែកប៉ុណ្ណោះ។ ឧទាហរណ៍: ម្ចាស់បំណុលទូទៅបានរឹបអូសដើមឈើដែលអានុភាពនៃសិទ្ធិហ៊ីប៉ូតែកខាងលើ ករណីនេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែកអាចដាក់បណ្តឹងតវ៉ារបស់តតិយជន និងដកចេញការអនុវត្តលើដើមឈើនោះបាន ដោយសារតែម្ចាស់សិទ្ធិហ៊ីប៉ូតែកមិនមានករណីយកិច្ចទទួលយកការធ្លាក់តម្លៃលើវត្ថុដែលជាកម្មវត្ថុប្រាតិភោគទេ។

### ៣.៨.៦. សិទ្ធិឃាត់ទុក

ករណីកម្មវត្ថុគឺជាអចលនវត្ថុ ជាគោលការណ៍ ការអនុវត្តដោយបង្ខំមិនធ្វើឱ្យបំពានសិទ្ធិឃាត់ទុកទេ ហេតុនេះ ម្ចាស់សិទ្ធិឃាត់ទុកមិនអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានទេ។

ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន នៅក្នុងករណីការអនុវត្តដោយបង្ខំទាមទារឱ្យប្រគល់ ឬករណីរឹបអូសលើចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិឃាត់ទុកបាន។[55]

### ៣.៨.៧. ប្រាតិភោគដោយអនុប្បទាន

នៅក្នុងប្រាតិភោគដោយអនុប្បទាន កម្មសិទ្ធិត្រូវផ្ទេរទៅឱ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ហេតុនេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន ក្នុងករណីម្ចាស់បំណុលរបស់អ្នកបង្កើតបានអនុវត្តដោយបង្ខំលើវត្ថុដែលជាកម្មវត្ថុ។[56]

### ៣.៨.៨. ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់

មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំលើវត្ថុដូចមានក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុចុះថ្ងៃទី/ខែ/ឆ្នាំ តាមសេចក្តីចម្លងយថាភូតនៃសាលក្រមដែលបានផ្តល់រូបមន្តអនុវត្តក្នុងរឿងក្តី (ឈ្មោះតុលាការ លេខរឿងក្តី និងឈ្មោះរឿងក្តី) របស់ចុងចម្លើយ (ឈ្មោះកូនបំណុល)។

## ៣.៩. អាជ្ញាអស់ជំនុំ

បណ្តឹងតវ៉ារបស់តតិយជនជានីតិវិធីនៃបណ្តឹង ហេតុនេះ អានុភាពនៃអាជ្ញាអស់ជំនុំកើតមានចំពោះអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិតវ៉ា។[57]

នៅក្នុងករណីដែលបណ្តឹងតវ៉ារបស់តតិយជនត្រូវបានច្រានចោល ដើមចោទមិនអាចទាមទារឱ្យសងនូវសេចក្តីចម្រើនឥតហេតុដោយមូលហេតុការអនុវត្តនោះខុសច្បាប់ ឬមិនត្រឹមត្រូវ និង មិនអាចទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលទេ។

## ៣.១០. នីតិវិធីក្រោយចេញសាលក្រម

ទោះបីជាមានសាលក្រមទទួលស្គាល់ការតវ៉ារបស់តតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនត្រូវបានផ្អាក (លុបចោល) ដោយឯកឯងនោះទេ។ យើងត្រូវដាក់សេចក្តីចម្លងយថាភូតនៃសាលក្រមទៅការអនុវត្ត ឬ អាជ្ញាសាលា ដើម្បីផ្អាកការអនុវត្ត (លុបចោល)។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមិនមានបញ្ញត្តិថាត្រូវ ឬមិនត្រូវរង់ចាំការចូលជាស្ថាពរនៃសាលក្រមតវ៉ារបស់តតិយជន ដើម្បីផ្អាកការអនុវត្តដោយបង្ខំនោះទេ (លុបចោល)។

---

[55] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៥ និងមាត្រា៣៨៦ នៃកថាខណ្ឌទី១។

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧, មាត្រា៨៤៨, កថាខណ្ឌទី១។

[57] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៩៤។

ប៉ុន្តែ យើងខ្ញុំយល់ថាសេចក្តីសម្រេចនោះគួរតែចូលជាស្ថាពរសិន ដើម្បីក្លាយជាលិខិតដែលមានកំណត់ដោយផ្អែកតាមហេតុផលខាងក្រោមៈ[58]

- ក្នុងករណីដើមចោទឈ្នះក្តីក្នុងការតវ៉ារបស់តតិយជន តុលាការអាចសម្រេចសេចក្តីអំពីការតវ៉ារបស់តតិយជនជាមួយនឹងការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្ត ឬការផ្អាក ការលុបចោលការអនុវត្តបាន
- អានុភាពអនុវត្ត នៃសាលក្រមកើតឡើងពេលចូលជាស្ថាពរ
- ប្រសិនបើអាចលុបចោលការអនុវត្តដោយបង្ខំនៅក្នុងស្ថានភាពមុនពេលស្ថាពរបាន ម្ចាស់បំណុលនឹងទទួលការខូចខាតយ៉ាងខ្លាំង នៅពេលដែលលទ្ធផលប្រែប្រួលនៅតុលាការជាន់ខ្ពស់។

## ៣.១១. ការសះជា

បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងធម្មតា ហេតុនេះការសះជាក៏ធ្វើបានដែរ។ ជាធម្មតា យើងមិនមែនសះជាអំពីខ្លឹមសារនៃសិទ្ធិតវ៉ានោះទេ (មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ជាអាទិ៍) ប៉ុន្តែយើងបញ្ចូលខ្លឹមសារ និងអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិតាមច្បាប់សារធាតុដែលជាមូលហេតុនៃការតវ៉ា (ការបញ្ជាក់អំពីកម្មសិទ្ធិ ជាអាទិ៍) ទៅក្នុងចំណុចសះជា។[59] លើសពីនេះ យើងក៏មានបញ្ចូលចំណុចដូចជា មិនអនុវត្តដោយបង្ខំផងដែរ។ នៅក្នុងករណីណាក៏ដោយ យើងត្រូវធ្វើយ៉ាងណាមិនឱ្យនៅសល់សិទ្ធិតវ៉ាតាមនីតិវិធីច្បាប់ ហើយជាទូទៅយើងកំណត់ទុកជាមុនអំពីការព្រមព្រៀងបញ្ចប់បណ្តឹង ឬព្រមព្រៀងដកបណ្តឹងតវ៉ានោះ។

## ៣.១២. ការផ្អាកការអនុវត្ត

ទោះបីជាដាក់បណ្តឹងរបស់តតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនផ្អាកដោយឯកឯងដែរ។ ដើម្បីផ្អាកការអនុវត្តដោយបង្ខំ យើងត្រូវដាក់ពាក្យសុំផ្អាកការអនុវត្តទៅតុលាការដែលបានទទួលពាក្យបណ្តឹង។[60]

### ៣.១២.១. ពាក្យសុំផ្អាកការអនុវត្ត

សមត្ថកិច្ច គឺតុលាការដែលទទួលពាក្យបណ្តឹងតវ៉ារបស់តតិយជន។[61] ចំពោះខ្លឹមសារនៃពាក្យសុំផ្អាក

[58] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧០, កថាខណ្ឌទី១, ចំណុចខ។

[59] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧០, កថាខណ្ឌទី១, ចំណុចច។

[60] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៦៧។

[61] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី១។

ការអនុវត្តដោយបង្ខំមួយរយៈ។ ផ្អាកការអនុវត្តដោយបង្ខំមួយរយៈ[62] និង លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ។[63]

### ៣.១២.២. លក្ខខណ្ឌនៃការផ្អាកការអនុវត្ត

មានការដាក់បណ្តឹងតវ៉ារបស់តតិយជន និង មានការបញ្ជាក់ដំបូងអំពីហេតុនៃការតវ៉ាដែលបានអះអាង។[64] គឺជាការបញ្ជាក់ដំបូងអំពីអត្ថិភាពនៃ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលអាចរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់វត្ថុដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ។

### ៣.១២.៣. វិធីវិនិច្ឆ័យ

ជាទៅទៅការវិនិច្ឆ័យធ្វើឡើងទៅលើតែឯកសារ ដោយមិនមានការបើកការទាញហេតុផលផ្ទាល់មាត់ ឬសាកសួរភាគីម្ខាងទៀតទេ។[65]

ក. មានភាពប្រញាប់។

ខ.នៅក្នុងសាលក្រមចុងក្រោយ តុលាការមានឆន្ទានុសិទ្ធិសម្រេចអំពីការទទួលស្គាល់ ឬមិនទទួលស្គាល់សេចក្តីសម្រេចផ្អាកការអនុវត្តជាអាទិ៍ ហេតុនេះទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬសាកសួរភាគីម្ខាងទៀតក៏ដោយក៏តុលាការអាចស្តាប់យោបល់របស់ភាគីម្ខាងទៀតបាននៅក្នុងបណ្តឹងអង្គសេចក្តីដែរ។

### ៣.១២.៤. អំពីប្រាតិភោគ

#### ក. ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ

តុលាការអាចបង្គាប់ឱ្យដាក់ ឬមិនដាក់ប្រាតិភោគបាន។[66] ប្រសិនបើត្រូវដាក់ប្រាតិភោគក៏ដោយក៏ប្រាតិភោគនោះធ្វើឡើងសម្រាប់តែការខូចខាតដែលកើតមានចំពោះម្ចាស់បំណុល ដោយសារយឺតយ៉ាវនៃការអនុវត្តនោះទេ ហេតុនេះតម្លៃប្រាតិភោគជាទូទៅមិនមានចំនួនច្រើនខ្លាំងទេ។

---

[62] ពាក្យថា ការផ្អាកការអនុវត្តមួយរយៈ គឺជាអំឡុងពេលដែលត្រូវសម្រេចសេចក្តីលុបចោល ផ្លាស់ប្តូរ ឬទទួលស្គាល់លើសាលក្រមចុងក្រោយ នៅក្នុងដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។

[63] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី២។

[64] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី១។

[65] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៨។

[66] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី១។

**ខ. ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ រួមទាំងលុបចោលការចាត់ចែងការអនុវត្ត ដែលបានធ្វើរួចហើយ**

តុលាការត្រូវតែបង្គាប់ឱ្យដាក់ប្រាតិភោគ តម្លៃប្រាតិភោគ គឺតម្រូវឱ្យគ្រប់ចំនួនការពារផលប្រយោជន៍ទាំងអស់ដែលម្ចាស់បំណុលមានលើការអនុវត្តចាត់ចែងដែលត្រូវបានលុបចោល ហេតុនេះ តម្លៃប្រាតិភោគមានចំនួនច្រើនខ្លាំង។[67]

ក្នុងករណីតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ ដំបូងតុលាការនឹងចេញដីកាសម្រេចអំពីតម្លៃប្រាតិភោគ (ឬវត្ថុដែលជាប្រាតិភោគ) និងអំឡុងពេលដាក់ប្រាតិភោគ។ តុលាការចេញដីកាផ្អាកការអនុវត្ត ក្រោយពីបញ្ជាក់ថាបានដាក់ប្រាតិភោគ។ វិធីដាក់ប្រាតិភោគគឺតម្កល់ ឬផ្ញើប្រាក់ជាអាទិ៍ នៅទីកន្លែងតម្កល់ (តុលាការ)។ ក្នុងករណីដែលមិនបានដាក់ប្រាតិភោគក្នុងអំឡុងពេលកំណត់ទេ តុលាការនឹងលើកចោលពាក្យសុំ។

**៣.១២.៥. ខ្លឹមសារនៃដីការសម្រេច**

ករណីតុលាការបានចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ តុលាកានឹងចេញដីកាសម្រេចអំពីការផ្អាកការអនុវត្តក្រោយពេលបញ្ជាក់អំពីការដាក់ប្រាតិភោគ។

- តុលាការអាចបង្គាប់ឱ្យដាក់ ឬ មិនដាក់ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន[68]
- តុលាការត្រូវបង្គាប់ឱ្យដាក់ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្នរួមទាំងលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ។[69]

តុលាការមានឆន្ទានុសិទ្ធិក្នុងការចេញដីកាសម្រេចណាមួយ។ ប៉ុន្តែ តុលាការមិនអាចចេញដីកាសម្រេចលុបចោលការអនុវត្តចំពោះពាក្យសុំដែលទាមទារត្រឹមតែការផ្អាកការអនុវត្តនោះទេ។

**៣.១២.៦. ដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ**

អ្នកដាក់ពាក្យសុំបានដាក់បណ្តឹងតវ៉ារបស់តតិយជនចំពោះការអនុវត្តដោយបង្ខំផ្អែកតាមសេចក្តីចម្លងយថាភូតនៃសាលក្រមដែលមានអនុភាពអនុវត្តចំពោះ (រឿងក្តីឈ្មោះ....រឿងក្តីលេខ.... និងតុលាការ...) ពីភាគីម្ខាងទៀត (កូនបំណុលឈ្មោះ....) និងបានដាក់ពាក្យសុំផ្អាកការអនុវត្តនោះ។ តុលាការទទួលស្គាល់ថាពាក្យសុំនោះមានមូលហេតុសមរម្យ ហើយអ្នកដាក់ពាក្យសុំបានដាក់តម្កល់ជាប្រាក់ប្រាតិភោគចំនួន....។

[67] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី២។

[68] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី១។

[69] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧, កថាខណ្ឌទី២។

### ៣.១២.៧. សេចក្តីសម្រេចបញ្ចប់

ផ្អាកការអនុវត្តដោយបង្ខំមួយរយៈលើវត្ថុដូចមានក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុចុះថ្ងៃទី/ខែ/ឆ្នាំ (សង្ខេប) ផ្អែកតាមការអនុវត្តខាងលើ រហូតដល់តុលាការនៃបណ្តឹងអង្គសេចក្តី ធ្វើការសម្រេចអំពីការលុបចោល ឬផ្លាស់ប្តូរ ឬទទួលស្គាល់ការអនុវត្ត។

#### ក. ក្រោយចេញដីកាសម្រេច

ការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាក (ត្រូវបានលុបចោល) បើសិនជាភាគីបានដាក់សេចក្តីចម្លងយថាភូតនៃដីកាសម្រេចផ្អាកការអនុវត្ត (លុបចោល) ទៅតុលាការអនុវត្ត ឬអាជ្ញាសាលា។[70]

#### ខ. ការធ្វើឧបាស្រ័យ

ភាគីមិនអាចធ្វើឧបាស្រ័យចំពោះដីកាសម្រេចផ្អាកការអនុវត្ត (របស់តុលាការនៃបណ្តឹងតវ៉ារបស់តតិយជន) ដោយសារតែមិនមានបញ្ញត្តិទទួលស្គាល់ការប្តឹងជំទាស់។ ប៉ុន្តែ ភាគីអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (របស់តុលាការអនុវត្ត) ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានផ្អាកដែលផ្អែកលើសេចក្តីចម្លងយថាភូតនៃដីកាសម្រេចនេះបាន។[71]

#### គ. ឋានៈរបស់ដីកាសម្រេចផ្អាកការអនុវត្តនៅក្នុងសាលក្រមចុងក្រោយ

តុលាការអាចធ្វើការផ្អាកការអនុវត្ត ឬផ្អាកការអនុវត្ត និង លុបចោលការចាត់ចែង នៅក្នុងសាលក្រមចុងក្រោយនៃការតវ៉ារបស់តតិយជនបាន។ ប្រសិនបើសេចក្តីសម្រេចអំពីការផ្អាកការអនុវត្តជាដើមត្រូវបានផ្អាកហើយ តុលាការត្រូវតែសម្រេចថាលុបចោលផ្លាស់ប្តូរ ឬទទួលស្គាល់នូវសេចក្តីសម្រេចទាំងនោះ។[72]

[70] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧០, កថាខណ្ឌទី២, ចំណុចក, និងកថាខណ្ឌទី១, ចំណុចឆ។

[71] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៤។

[72] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៨។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ ព្រមទាំងបកស្រាយទៅអត្ថបទសារណាដែលមានចំណងជើងថា ការការពារតតិយជនក្រោយការលុបចោលកិច្ចសន្យា រួចមក យើងខ្ញុំពិតជាបានទទួលចំណេះដឹង និងយល់ដឹងអំពីសារៈសំខាន់នៃប្រធានបទមួយនេះ។ កិច្ចសន្យាត្រូវចាប់ទុកថាមានសុពលភាព អាចយកទៅអនុវត្តបានលុះត្រាតែ កិច្ចសន្យានោះត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងគូភាគីនៃកិច្ចសន្យានោះ។ ហើយ ជាទូទៅកិច្ចសន្យានោះត្រូវមានកម្មវត្ថុស្របច្បាប់ និងត្រូវធ្វើឡើង ដោយភាគី ដែលមានសមត្ថភាពក្នុងការចុះកិច្ចសន្យា។ នៅក្នុងករណីខ្លះ ទោះបីកិច្ចសន្យា នោះត្រូវធ្វើដោយស្របទៅនឹងគោលគំនិតខាងលើក៏ដោយ ក៏វាអាចនឹងត្រូវបានលុបចោលបានផងដែរ ប្រសិនបើការបង្កើតកិច្ចសន្យានោះមានវិការៈនៃការព្រមព្រៀង រួមមានដូចជាកិច្ចសន្យានោះកើតឡើងដោយមានការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង និងអំពើកេងយកចំណេញហួសហេតុជាដើម។ មិនមែនគ្រប់បុគ្គលសុទ្ធតែមានសិទ្ធិលើកឡើងអំពីការលុបចោលបានឡើយ។ ជាមូលដ្ឋាន មានតែការបង្ហាញឆន្ទៈដោយវិការៈរបស់សមត្ថជន និងជនដែលត្រូវកម្រិតសមត្ថភាពប៉ុណ្ណោះ។ អសមត្ថជននៅត្រង់នេះ គាត់អាចអះអាងចំពោះការលុបចោលដោយខ្លួនឯងបាន លុះត្រាណាតែជននោះទទួលបានវិញនូវសមត្ថភាពក្នុងការទទួលសិទ្ធិ។ ចំពោះការជូនដំណឹងពីការលុបចោលកិច្ចសន្យាវិញ អាចធ្វើបានក្រោមរូបភាពជាក្រៅប្រព័ន្ធតុលាការ តាមរយៈការជូនដំណឹងដោយផ្ទាល់មាត់ ការសរសេរសំបុត្រ ឬការផ្ញើសារតាមប្រព័ន្ធអេឡិចត្រូនិច....។ និងតាមប្រព័ន្ធតុលាការវិញ កាលណាតែភាគីមិនអាចព្រមព្រៀងបាន ទើបភាគីអាចដាក់ពាក្យបណ្តឹងអោយតុលាការបញ្ជាក់ពីនត្ថិភាពនៃកិច្ចសន្យា។ រីឯ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលវិញ ត្រូវបានចែកចេញជាពីរស្របតាមមាត្រា៣៦៣នៃក្រមរដ្ឋប្បវេណី។ សម្រាប់អំឡុងពេលបីឆ្នាំ ប្រសិនណាបើអ្នកមានសិទ្ធិលុបចោលមិនបានផ្តល់សច្ចានុមតិអំពីការលុបចោលនោះអោយទាន់ពេលវេលាទេ នោះសិទ្ធិលុបចោលនឹងត្រូវរលត់។ ផ្ទុយទៅវិញ ប្រសិនបើការផ្តល់សច្ចានុមតិនោះ មិនបានហួសអាជ្ញាយុកាលទេ អ្នកមានសិទ្ធិលុបចោលអាចទាមទារបានវិញដោយផ្អែកលើសេចក្តីចម្រើនឥតហេតុបាន។ សម្រាប់អំឡុងពេលដែលបានហួសដល់ទៅ១០ឆ្នាំ គឺពុំអាចទាមទារអ្វីបានទាំងអស់ ដោយហេតុថាអាជ្ញាយុកាលនៃការរលត់សិទ្ធិត្រូវបានហួស។

ការការពារតតិយជនក្រោយការលុបចោលកិច្ចសន្យា វាគឺជាភាពចាំបាច់ក្នុងគោលបំណងដើម្បី ការពារផលប្រយោជន៍របស់តតិយជន ជាពិសេសដើម្បីកុំឱ្យមានផលប៉ះពាល់ដល់សុវត្ថិភាពក្នុងកិច្ចការជំនួញ ដែលកើតឡើងដោយសារការបង្កើតកិច្ចសន្យាដោយមានវិការៈ។ ប្រសិនបើកិច្ចសន្យានោះ អាចត្រូវបានលុបចោលដោយផ្អែកលើវិការៈណាមួយនោះតតិយជនដែលបានបង្កើតទំនាក់ទំនងកិច្ចសន្យា ហើយដោយផ្អែកលើកិច្ច

សន្យាដែលអាចត្រូវបានលុបចោល អាចនឹងទទួលរងនូវការខាតបង់ ដែលយើងមិនអាចរំពឹងទុកបាន។ ដូច្នេះ មធ្យោបាយសមស្របទាំងឡាយដើម្បីការពារតតិយជនក្រោយការលុបចោលកិច្ចសន្យា គឺជាការចាំបាច់បំផុត ស្របទៅនឹងគោលការណ៍ចំពោះមុខ និងសិទ្ធិក្នុងការពឹងពាក់តុលាការក្នុងការដោះស្រាយ វិវាទរដ្ឋប្បវេណី ទើប ក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិស្ដីពី បណ្ដឹងតវ៉ារបស់តតិយជន ដែលអាចធ្វើប្រឆាំងទៅនឹងការអនុវត្តដោយ បង្ខំ ហើយបើសិទ្ធិដល់ភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមឲ្យអនុវត្តដោយបង្ខំ ឬផ្សេងទៀត មានលទ្ធ ភាពក្នុងការប្រើប្រាស់សិទ្ធិទាមទារឱ្យ តុលាការ ឬចៅក្រមដែលបានចេញសាលក្រមនោះធ្វើការសម្រេចសេចក្ដី ម្ដងទៀត ឬ ឈានដល់ការលុបចោលតែម្ដង។

បទបញ្ញត្តិពាក់ព័ន្ធនឹងបណ្ដឹងតវ៉ារបស់តតិយជន ដែលមានចែងនៅ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ គឺមានភាពល្អប្រសើរ និងជាកត្តាមួយដ៏សំខាន់ក្នុងការរួមចំណែក ស្វែងរកយុត្តិធម៌ជូនភាគី និងបានផ្ដល់នូវសិទ្ធិដល់តតិយជន មានសិទ្ធិក្នុងការធ្វើបណ្ដឹងតវ៉ា ដើម្បី បង្ហាញនូវសិទ្ធិ និងដាក់មធ្យោបាយក្នុងការតទល់ឱ្យអស់ពីលទ្ធភាព។ នៅពេលដែលគូភាគីបានប្រើ ប្រាស់នូវសិទ្ធិរបស់ខ្លួនរួចហើយ និងព្រមទទួលយកនូវសេចក្ដីសម្រេចរបស់តុលាការ។

យើងអាចនិយាយបានថា បណ្ដឹងតវ៉ារបស់តតិយជន ជាបណ្ដឹងមួយដ៏មានសារៈសំខាន់ចំពោះគូភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមអនុវត្តដោយបង្ខំ ឬផ្សេងទៀត មានលទ្ធភាពក្នុងការប្រើប្រាស់នូវសិទ្ធិ របស់ពួកគេម្ដងទៀត ក្នុងនីតិវិធីធ្វើបណ្ដឹងតវ៉ា និងផ្ដល់ឱកាសដល់តុលាការក្នុងស្វែងរកយុត្តិធម៌។

# អនុសាសន៍

# អនុសាសន៍

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ យើងខ្ញុំទាំងពីរនាក់សូមសំណូមពរដល់អ្នកដែលពាក់ព័ន្ធដូចជាៈ

១.រដ្ឋាភិបាលៈ ជាពិសេសក្រសួងពាក់ព័ន្ធនានាជួយពង្រឹង លើកកម្ពស់ ផ្សព្វផ្សាយ ចំពោះដឹងផ្នែកច្បាប់ឱ្យបានទូលំទូលាយបន្ថែមទៀត តាមរយៈការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ក្រោមឧត្តមសិក្សានូវចំណេះដឹងជាមូលដ្ឋានផ្នែកច្បាប់ ក៏ដូចជាការបង្កើតជាកម្មវិធីផ្សព្វផ្សាយផ្សេងៗ ទាំងតាមរយៈការចុះទៅដល់សហគមន៍ផ្ទាល់ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដោយសារប្រជាជនភាគច្រើន ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលពិតជាមិនសូវបានចាប់អារម្មណ៍ ឬទទួលបានចំណេះដឹងច្បាប់ទេ ខណៈដែលថ្មីៗកំពុងតែត្រូវបានបង្កើតជាបន្តបន្ទាប់។

២.ក្រសួងយុត្តិធម៌ៈ គប្បីចេញនីតិវិធីឱ្យមន្ត្រីដែលជាអ្នកអនុវត្តច្បាប់ យកចិត្តទុកដាក់ ពន្លឿនក្នុងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ តាមរយៈការផ្តល់មតិយោបល់ដល់ពួកគាត់ ឬ ផ្តល់មធ្យោបាយផ្សេងៗដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ពីច្បាប់ ជាចំណែកក្នុងការចូលរួមអនុវត្តច្បាប់ផងដែរ។

៣.មន្ត្រីរាជការ សិស្សនិស្សិតៈ បុគ្គលទាំងនេះ ត្រូវបានចាត់ទុកជាអ្នកដែលចំណេះដឹង និងមានការយល់ដឹងអំពីច្បាប់ ក៏ដូចជាព័ត៌មានផ្សេងៗ ច្បាស់ជាងប្រជាពលរដ្ឋ។ ដូចនេះ សិស្សនិស្សិត មន្ត្រីរាជការ គួរធ្វើខ្លួនជាគំរូ ដោយគោរពច្បាប់ និងមិនប្រព្រឹត្តអ្វីដែលល្មើសច្បាប់ ហើយជាពិសេស ត្រូវមានស្មារតីចេះចែករំលែកក្នុងនាមជាប្រជាជនខ្មែរដូចគ្នា។

៤.ប្រជាពលរដ្ឋៈ ប្រជាពលរដ្ឋគួរចូលរួមក្នុងការអនុវត្តច្បាប់ឱ្យបានខ្ជាប់ខ្ជួន ស្របតាមភាពសុចរិត និងស្មោះត្រង់ ព្រោះទាល់តែគាត់គោរពតាមច្បាប់ ទើបគេអាចប្រើប្រាស់ច្បាប់ការពារគាត់បាន។ ពួកគាត់ក៏គួរស្វះស្វែង ស្វែងយល់ពីច្បាប់នានា តាមដែលអាចធ្វើបាន ព្រោះយើងទាំងអស់គ្នារស់នៅក្នុងសង្គមនីតិរដ្ឋ ការយល់ដឹងពីច្បាប់គឺជារឿងមួយដែលសំខាន់បំផុត។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣, ០៨ ធ្នូ ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៦០៧/០២១, ០៦ កក្កដា ២០០៦។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

## ២.ប្រកាស

ប្រកាសរបស់ក្រសួងយុត្តិធម៌ ស្តីពីការកែសម្រួលឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពី ប្រភេទ ពាក្យសុំដែលតម្រូវអោយបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធដាក់ពាក្យសុំ និងចំនួនពន្ធដែលបង់ត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការអោយសម្រេចសេចក្តី និងមាត្រាដ្ឋានសម្រាប់គណនាប្រាប់ប្រដាប់ក្តី តុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង,លេខ៥៤ កយប្រក./០៩,២២មិថុនា២០០៩។

## ៣.សៀវភៅ

គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា. *នីតិរដ្ឋប្បវេណី១*. ២០១២-២០១៧។

ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ. *សេក្តីផ្តើមនីតិរដ្ឋប្បវេណី*. បោះពុម្ពលើកទី៥. ភ្នំពេញ ៖ ២០១១។

មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ របស់ក្រសួងយុត្តិធម៌, ធ្នូ ២០១៥។

មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ របស់ក្រសួងយុត្តិធម៌, វិច្ឆិកា ២០១៦។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១. ២០០៩។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២. ២០១០។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី. ២០១១។

សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១: នីតិវិធីបណ្តឹង។

សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២: ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ។

សេចក្តីពន្យល់អំពីចំណុចសំខាន់ៗនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. ភ្នំពេញ ៖ ២៨ ធ្នូ ២០០៥។

អ៊ុំ ប៉ូលី. *បណ្តឹងតវ៉ារបស់តតិយជន*, ព្រឹត្តិបត្រមេធាវីត្រីមាសទី៤ លេខ១៩ ខែតុលា-ធ្នូ ឆ្នាំ២០១៨។

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

- លិខិតពាក្យសុំ-ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ
- លិខិតដីកាសម្រេច-ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ
- លិខិតពាក្យសុំឱ្យអនុវត្ត-ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ
- លិខិតពាក្យសុំ
- លិខិតពាក្យសុំ-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ
- លិខិតដីកាសម្រេច-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ
- ដីកាសម្រេចលុបចោលនីតិវិធីអនុវត្តដោយបង្ខំ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

## ម្ចាស់បំណុល

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។[1]

## អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី[2].................

## កូនបំណុល

ឈ្មោះ ៖ Y

[1] អំពីឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងចំណុច ក កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែ ចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ។ ដូច្នេះ ករណីត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគីបាន។

[2] យោងមាត្រា ៥៣៩ មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយលក្ខអក្សរដូចជានៅក្នុងពាក្យសុំ ជាអាទ៍។

អាសយដ្ឋាន៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវប្រធានសាលាដំបូងរាជធានីភ្នំពេញ**[3]

## ក. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ៖[4]

រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។

---

[3] រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (កថាខណ្ឌទី ១ មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្តីនេះ ដោយសារតែលំនៅដ្ឋានរបស់កូនបំណុលនៅខេត្តបាត់ដំបង ហើយលំនៅដ្ឋានរបស់កម្ចាស់បំណុល និងទីកន្លែងដែលត្រូវអនុវត្តនូវកាតព្វកិច្ចប្រាក់កម្ចី នៅខេត្តបាត់ដំបងដែរ ហេតុនេះហើយ សាលាដំបូងខេត្តបាត់ដំបង គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុ។ ម្យ៉ាងវិញទៀត អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅរាជធានីភ្នំពេញ ដូច្នេះហើយសាលាដំបូងរាជធានីភ្នំពេញក៏មានសមត្ថកិច្ចលើលើរឿងក្តីរឹបអូសជាបណ្តោះអាសន្នផងដែរ។ រវាងសាលាដំបូងខេត្តបាត់ដំបង ឬ សាលាដំបូងរាជធានីភ្នំពេញ ម្ចាស់បំណុលអាចដាក់ពាក្យសុំ ទៅសាលាដំបូងណាមួយក៏បាន ប៉ុន្តែ នៅក្នុងរឿងក្តីនេះ បានដាក់ពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញ ដោយសារលំនៅដ្ឋានរបស់អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនៅជិតជាង។

[4] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកពាក្យសុំទាមទារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ខ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណី ស្នើរសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះ គឺស្នើសុំដីកាសម្រេចដែលមានន័យថា រឹបអូសជាបណ្តោះអាសន្នចំពោះទ្រព្យសម្បត្តិរបស់កូន ។ ម្យ៉ាងវិញទៀត ត្រូវកំណត់ជាក់លាក់នូវអលនវត្ថុដែលជាកម្មវត្ថុនោះ (មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយវិធីដើម្បីកំណត់ជាក់លាក់នេះ ត្រូវភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិ លើបំណុលដែលទាមទារ និងបញ្ជីឧបម្ព័ន្ធអំពីវត្ថុនៅក្នុងពាក្យសុំ និងយោងតាមរយៈបញ្ជីឧបសម្ព័ន្ធទាំងនេះ។

យ៉ាងណាមិញ ចំពោះប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ៥៣៩ និង មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ទោះបីជាមាន ឬ មិនមានពាក្យសុំពីភាគី ក៏ត្រូវកំណត់ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូច្នេះ អ្នកដាក់ពាក្យសុំ មិនមានភាពចាំបាច់ដែលត្រូវសរសេរនៅក្នុងខ្លឹមសារនៃដិកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារនោះទេ។

## ខ. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ[5]

### ខ.១ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ម្ចាស់បំណុលបានបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល ជាមួយកូនបំណុល។ នៅក្នុងកិច្ចសន្យាដដែលនេះ ម្ចាស់បំណុល និងកូនបំណុល បានកំណត់ថា ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សង។ ម្យ៉ាងវិញទៀត ម្ចាស់បំណុល និងកូនបំណុល បានព្រមព្រៀងទៅលើខ្លឹមសារដែលបង់ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើមចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល ហើយការព្រមព្រៀងនេះបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់កូនបំណុល។ (**ភស្តុតាង**$X_1$)

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយផ្អែកតាមកិច្ចសន្យាខាងលើ ម្ចាស់បំណុលបានប្រគល់សាច់ប្រាក់ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល ទៅកូនបំណុល។ (**ភស្តុតាង**$X_2$) [6]

### ខ.២ ការកន្លងផុតនៃពេលកំណត់សង

ពេលកំណត់សង ដែលជាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ បានកន្លងផុត។

---

[5] សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញនៃដីកាសម្រេចរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយចំណុចនេះ ត្រូវសរសេរឱ្យបានលម្អិតនូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ និងអង្គហេតុដែលជាមូលហេតុនៃសិទ្ធិ។ ម្យ៉ាងទៀត ដើម្បីឱ្យដីកាសម្រេចចេញបានដោយយ៉ាងឆាប់រហ័ស និងការកំណត់ចំនួនទឹកប្រាក់ប្រាតិភោគឱ្យបានទាបតាមដែលអាចធ្វើបាន គួរតែសរសេរនូវការតវ៉ាតបចំពោះការតវ៉ាដែលនឹងត្រូវបានរំពឹងទុក។

[6] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គួរតែខិតខំប្រឹងប្រែងសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់ (កថាខណ្ឌទី ២ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ វិធីកំណត់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ ត្រូវធ្វើការយោង និងភ្ជាប់ឧបសម្ព័ន្ធសិទ្ធិលើបំណុលដែលនឹងទាមទារទៅនឹងពាក្យសុំ។

**ខ.៣ ការសន្និដ្ឋានអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ**

ហេតុដូច្នេះ ម្ចាស់បំណុល មានសិទ្ធិទាមទារចំពោះកូនបំណុលដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគនៃរឿងក្តីនេះដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុល ដែលទាមទារ (១) ប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល , (២) ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ គឺចំនួន ២.០០០.០០០ (ពីរលាន) រៀល, (៣) ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ គឺ ចំនួន ៣២៨.០០០ (បីសែនពីរម៉ឺនប្រាំបីពាន់) រៀល។

**គ. ភាពចាំបាច់នៃការរក្សាការពារ**[7]

**គ.១** ក្រោយពេលកំណត់សង ដែលជាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ បានកន្លងផុត កូនបំណុលមិនបានសងទាល់តែសោះមកម្ចាស់បំណុល។ អំឡុងពេលខែតុលា ឆ្នាំ២០២០ ម្ចាស់បំណុល បានទាមទារឱ្យសងជាច្រើនលើកទៅកាន់កូនបំណុល ប៉ុន្តែកូនបំណុលមិនបានឆ្លើយតបទេ រហូតមកដល់អំឡុងដើម ខែវិច្ឆិកា ឆ្នាំ២០២០ សូម្បីទាក់ទងក៏លែងបានដែរ។ (**ភស្តុតាង**X$_3$)

**គ.២**យោងតាមដែលម្ចាស់បំណុលបានសួរ និងឮពីអ្នកដែលបានស្គាល់កូនបំណុលថា កូនបំណុល មានអាជីវកម្មហាងបោកអ៊ុត ប៉ុន្តែអាជីវកម្មនោះមិនបានដំណើរទៅដោយយ៉ាងរលូននោះទេ ហើយដើម្បីមើលថែទាំឪពុកដែលមានជំងឺ កូន

---

[7] ភាពចាំបាច់នៃការរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងការរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរនូវស្ថានភាពឱ្យបានច្បាស់លាស់ផ្អែកតាមការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។

បំណុលបានខ្ចីប្រាក់ពីសាច់ញាតិ និងអ្នកស្គាល់គ្នាជាច្រើន។ លើសពីនេះ ការស្រាវជ្រាវរបស់ម្ចាស់បំណុល គឺថាកូនបំណុលមានកម្មសិទ្ធិលើដីដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ (**ភស្តុតាង**$X_4$) ប៉ុន្តែ ក្រៅពីនេះទៀត រកមិនឃើញទ្រព្យសម្បត្តិផ្សេងទៀតមានតម្លៃទេ។ (**ភស្តុតាង**$X_3$)

**គ.៣** ម្ចាស់បំណុល កំពុងតែរៀបចំដើម្បីដាក់បណ្តឹងទាមទារឱ្យបង់សិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារចំពោះកូនបំណុល ប៉ុន្តែ ប្រសិនបើមិនធ្វើការរឹបអូសជាបណ្តោះអាសន្នចំពោះដីដែលមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុនាពេលនេះទេ នាពេលក្រោយ ទោះបីជាទទួលបានសាលក្រមឈ្នះក្តីក្នុងបណ្តឹងអង្គសេចក្តីក៏ដោយ ក៏នឹងមិនអាចអនុវត្ត ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តនោះ ។

**ឃ. ភស្តុតាង**[8]

១. លិខិតកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ (**ភស្តុតាង**$X_1$)

២. លិខិតវិក្កយបត្រទទួលប្រាក់កម្ចី ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ២០១៩(**ភស្តុតាង**$X_2$)

៣. របាយការណ៍ (**ភស្តុតាង**X3)

៤. ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់សៀវភៅចុះបញ្ជី (**ភស្តុតាង**$X_4$)

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំនាញប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំនាញប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

---

[8] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ ( ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) មានភាពចាំបាច់ត្រូវភ្ជាប់នូវឯកសារដើម្បីធ្វើសេចក្តីបញ្ជាក់ដំបូង (កថាខណ្ឌទី ៣ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ខេត្តបាត់ដំបង, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០១ ច្បាប់"

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ[9]

ចំនួនទឹកប្រាក់៖ ៩២.៣២៨.០០០ (សែសិបពីរលានបីសែនពីរម៉ឺនប្រាំបីពាន់) រៀល

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគប្រាក់ដែលបង្កើតឡើងរវាងម្ចាស់បំណុល និងកូនបំណុល ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយយកថ្ងៃទី៣០ កញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សង មានចំនួនសរុបនៃសិទ្ធិទាមទារទឹកប្រាក់ដូចខាងក្រោម៖

១. ប្រាក់ដើម ចំនួន ៩០.០០០.០០០ (សែសិបលាន) រៀល

២. ការប្រាក់ ចំនួន ២០.០០០.០០០ (ពីរលាន) រៀល

ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៩០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

៣. ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៣២៨.០០០ (បីសែនពីម៉ឺនប្រាំបីពាន់) រៀល

[9] សិទ្ធិបំណុលដែលទាមទារ ត្រូវកំណត់ជាក់លាក់នូវ ខ្លឹមសារ និង ចំនួនទឹកប្រាក់ ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកជាមួយនឹងសិទ្ធិលើបំណុលផ្សេងទៀតបាន។ ប្រសិនបើជាកិច្ចសន្យាខ្ចីបរិភោគប្រាក់ ត្រូវសរសេរកំណត់ជាក់លាក់ដោយសរសេរ អំពីភាគី កាលបរិច្ឆេទនៃកិច្ចសន្យា ពេលកំណត់សងជាអាទិ៍។ម្យ៉ាងទៀត បន្ថែមពីប្រាក់ដើមដែលជាប្រាក់កម្ចី ក្នុងករណីដែលទាមទារការប្រាក់ និង ប្រាក់សំណខូចខាត ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់នីមួយៗ ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់នូវអត្រាការប្រាក់ និង អំឡុងពេល ជាអាទិ៍។

ប្រាក់សំណងខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខៈ ០០

ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

ដីកាសម្រេចលេខៈ០០

ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០

## ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[1]

យើង J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ ចំណុច ក មាត្រា ៥៣១, មាត្រា ៥៤២, កថាខណ្ឌទី ១ មាត្រា ៥៤៥, កថាខណ្ឌទី ១ មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[2]
- បានឃើញពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។

[1] ការសម្រេចសេចក្ដី មាន សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ គឺមានភាពចាំបាច់ដែលត្រូវសសេរប្រភេទនៃការសម្រេចសេចក្ដីនៅក្នុងក្បាលដើមនៃឯកសារ។ ពីព្រោះថា វិធីនៃឧបាស្រ័យជាអាទិ៍ មានភាពខុសគ្នារវាង សាលក្រម និងដីកាសម្រេច។ បណ្ដឹងឧបាស្រ័យចំពោះសាលក្រមរបស់សាលាដំបូង ជាគោលការណ៍ គឺត្រូវធ្វើឡើងជាបណ្ដឹងឧទ្ធរណ៍ ចំណែកឯបណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច គឺត្រូវឡើងជាបណ្ដឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងដីកាសម្រេចរក្សាការពារ មានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដូច្នេះ គឺមានការចាំបាច់កំណត់ឱ្យបានច្បាស់លាស់ថាជាដីកាសម្រេចណាមួយ។

[2] នៅពេលដែលយោងក្រមនីតិវិធីរដ្ឋប្បវេណី គួរតែសរសេរឱ្យបានលម្អិតត្រឹមតែលេខមាត្រាដែលត្រូវអនុវត្ត។

**ម្ចាស់បំណុល**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**អ្នកតំណាងដោយអាណត្តិ**

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**កូនបំណុល**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

## ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ[3]

រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។

## សំអាងហេតុ[4]

---

[3] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[4]មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ង មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើមើលពីគោលគំនិតនៃលក្ខណៈបន្ទាន់បង្ហំ (លក្ខណៈឆាប់រហ័ស) នៃការរក្សាការពារផ្នែករដ្ឋប្បវេណី ដីកាសម្រេចរក្សាការពារ ត្រូវធ្វើឱ្យបានឆាប់រហ័ស ហើយជាពិសេសនៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាធម្មតា ប្រសិនបើមិនបើកការទាញហេតុផលដោយផ្ទាល់មាត់ និងសួរកូនបំណុលទេ នាំឱ្យការសរសេរនៅក្នុងសំអាងហេតុ គ្រាន់តែសរសេរឱ្យមានលក្ខណៈជារួម និងខ្លីៗ គឺគ្រប់គ្រាន់។ លើសពីនេះ នៅក្នុងសម្អាងហេតុក្រោយពី បានកំណត់អំពីប្រភេទ ខ្លឹមសារ និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន ត្រូវសរសេរនូវខ្លឹមសារថា រឹបអូសជាបណ្តោះចំពោះទ្រព្យសម្បត្តិរបស់កូនបំណុល

យោងតាមសំណុំរឿងនៃរឿងក្តីនេះ ទទួលស្គាល់ថាម្ចាស់បំណុលមានសិទ្ធិលើបំណុលដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារចំពោះកូនបំណុល និងទទួលស្គាល់ផងដែរនូវភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។

ដូច្នេះ តុលាការ ទទួលស្គាល់ថា ពាក្យសុំរបស់ម្ចាស់បំណុលគឺសមរម្យ ហើយឱ្យម្ចាស់បំណុលដាក់ប្រាតិភោគចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ដើម្បីរក្សាការពារនូវការអនុវត្តសិទ្ធិលើបំណុលដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទាររបស់ម្ចាស់បំណុលចំពោះកូនបំណុល ដូចក្នុងការសម្រេចសេចក្តីខាងក្រោម។

## សេចក្តីសម្រេចបញ្ចប់[5]

១.រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។

២. កូនបំណុល ត្រូវផ្ញើចំនួនប្រាក់ ចំនួន ៨២.៣២៨.០០០ (សែសិបពីរលានបីសែន ពីរម៉ឺនប្រាំបីពាន់) រៀល[6] ដើម្បីទទួលបាននូវការលុបចោលការអនុវត្តដីកាសម្រេចនេះ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

---

ដើម្បីរក្សាការពារការអនុវត្តនេះ។ នៅក្នុងឯកសារទម្រង់គំរូនេះ មានភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារនៅក្នុងលិខិតដីកាសម្រេច ហើយតាមរយៈការយោងបញ្ជីឧបសម្ព័ន្ធនេះ មានការកំណត់ជាក់លាក់សិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន។

[5] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ច កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍ ត្រូវចេញដីកាសម្រេច ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ (មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងឯកសារទម្រង់គំរូនេះ មានភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីវត្ថុនៅក្នុងលិខិតដីកាសម្រេច ហើយតាមរយៈការយោងបញ្ជីឧបសម្ព័ន្ធនេះ មានការកំណត់ជាក់លាក់នូវអចលនវត្ថុដែលជាកម្មវត្ថុ។

យ៉ាងណាមិញ ទោះបីមាន ឬ មិនមានពាក្យសុំពីភាគី ក៏ត្រូវកំណត់ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ៥៣៩, មាត្រា ២១៦, កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[6] នេះគឺជាចំនួនទឹកប្រាក់សមរម្យនៃសិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ ។

ដីកាសម្រេចនេះអាចអនុវត្តបានភ្លាម។

ចំពោះដីកាសម្រេចនេះ អាចដាក់ពាក្យសុំតវ៉ាយោងតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

ថ្ងៃសុក្រ ៤រោជ ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០២០

**ចៅក្រម**

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ[7]

ចំនួនទឹកប្រាក់៖ ៤២.៣២៨.០០០ (សែសិបពីរលានបីសែនពីរម៉ឺនប្រាំបីពាន់) រៀល

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគប្រាក់ដែលបង្កើតឡើងរវាងម្ចាស់បំណុល និងកូនបំណុលនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយកំណត់ថ្ងៃទី៣០ កញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សង មានចំនួនសរុបនៃសិទ្ធិទាមទារទឹកប្រាក់ដូចខាងក្រោម៖

១. ប្រាក់ដើម ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល

២. ការប្រាក់ ចំនួន ២.០០០.០០០ (ពីរលាន) រៀល

ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

៣. ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៣២៨.០០០ (បីសែនពីរម៉ឺនប្រាំបីពាន់) រៀល

[7] សិទ្ធិដែលនឹងត្រូវបានរក្សាការពារ (សិទ្ធិលើបំណុលដែលទាមទារ) ត្រូវកំណត់ជាក់លាក់ដូចជា ខ្លឹមសារ និង ចំនួនទឹកប្រាក់ ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកចេញពីសិទ្ធិលើបំណុលផ្សេងទៀត។ ប្រសិនបើជាកិច្ចសន្យាខ្ចីបរិភោគប្រាក់ ត្រូវកំណត់ជាកលាក់ដោយសរសេរដូចជា ភាគី កាលបរិច្ឆេទ នៃកិច្ចសន្យា និងពេលកំណត់សង ជាអាទិ៍។ ម្យ៉ាងទៀត បន្ថែមពីប្រាក់ដើម ក្នុងករណីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ គឺជាការប្រាក់ និង ប្រាក់សំណងខូចខាត គឺមានភាពចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់អំពីចំនួនទឹកប្រាក់នីមួយៗ ព្រមទាំងចំនួនទឹកប្រាក់ដើមដែលជាកម្មវត្ថុ អត្រាការប្រាក់ និង អំឡុងពេល ជាអាទិ៍ ពីព្រោះទាំងអស់នេះ គឺជាសិទ្ធិដាច់ដោយឡែកផ្សេងៗពីគ្នា។

ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឱ្យអនុវត្តវិធានការបណ្ដោះអាសន្ន

**ម្ចាស់បំណុល**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង[1]។

**អ្នកតំណាងដោយអាណត្តិ**

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ ................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

**កូនបំណុល**

ឈ្មោះ ៖ Y

អាសយដ្ឋាន ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

---

[1] យោងមាត្រា ៥៦៤ , ចំណុច ក កថាខណ្ឌទី ១ និង ចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[2] យោងមាត្រា ៥៣៩, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយលក្ខអក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ ប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]**

**លិខិតអនុវត្តះ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លេខ ០០ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ**

ម្ចាស់បំណុល ទាមទារឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបនៃការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដែលជាការអនុវត្តតាមការបង្ខំដោយផ្ទាល់ ផ្អែកតាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[4]លេខ០០ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។ [5]

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តម/លោកជំទាវប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តបាត់ដំបង, ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១-ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ១ច្បាប់

២-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ១ច្បាប់

P

---

[3] ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ (កថាខណ្ឌទី ២ មាត្រា ៥៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ មាន សមត្ថកិច្ចជាតុលាការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។

[4] យោងមាត្រា ៥៦៤ និង ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៣៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5] យោងមាត្រា ៥៦៤, ចំណុច គ និង ចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខ/លេខឡូត៍" ០០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំឱ្យលក់ដោយបង្ខំ

## ម្ចាស់បំណុលនៃការអនុវត្ត
ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង[1]។

## អ្នកតំណាងដោយអាណត្តិ
ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ .........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................. [2]

---

[1] យោងចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្តដែលសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវតែឱ្យដូចគ្នានឹងភាគីដែលមានសរសេរនៅក្នុងលិខិតអនុវត្ត និងរូបមន្តអនុវត្ត។ ករណីដែលមានការផ្លាស់ប្ដូរ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ត្រូវតែដាក់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ជាបុគ្គលឱ្យដូចគ្នានឹងភាគីដែលមានសរសេរនៅក្នុងលិខិតអនុវត្ត និងរូបមន្តអនុវត្ត។

[2] យោងមាត្រា ៣៣៥, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលនៃការអនុវត្ត មានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយល័ក្ខអក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

**កូនបំណុលនៃការអនុវត្ត**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**សិទ្ធិលើបំណុលដែលទាមទារ** ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុល ដែល ទាមទារ[3]

**អចលនវត្ថុដែលជាកម្មវត្ថុ** ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ[4]

## សូមគោរពជូន
## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ[5]

## លិខិតអនុវត្ត៖ អនុសារសាលក្រមដែលមានអានុភាពអនុវត្តសាលក្រមរដ្ឋប្បវេណី លេខ០០ ចុះថ្ងៃទី០០ ខែ០០ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ

ម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិលើបំណុលដូចដែលមានសញ្ញាណនៅក្នុងលិខិតអនុវត្ត [6] និងមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារចំពោះកូនបំណុលនៃការអនុវត្ត ប៉ុន្តែ កូនបំណុលនៃការអនុវត្តមិនធ្វើការសងនូវសិទ្ធិលើបំណុលនោះទេ អាស្រ័យហេតុនេះ ម្ចាស់បំណុលនៃការអនុវត្ត ទាមទារឲ្យចាប់ផ្តើមនីតិវិធីការលក់ដោយបង្ខំចំពោះអចលនវត្ថុដែលមានសរសេរនៅក្នុងបញ្ជី

---

[3] កថាខណ្ឌទី ២ មាត្រា ៣៤៩ មិនបានចែងអំពីសញ្ញាណសិទ្ធិលើបំណុលដែលទាមទារទេ ប៉ុន្តែគួតែមានសញ្ញាណសិទ្ធិលើបំណុលដែលទាមទារ ដើម្បីឱ្យសិទ្ធិលើបំណុលដែលទាមទារ និងជាមូលហេតុនៃ ការអនុវត្តដោយបង្ខំចំពោះកូនបំណុលនៃការអនុវត្ត ឱ្យមានភាពកាន់តែច្បាស់លាស់។

[4] យោងចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5] ចំពោះការអនុវត្តដោយបង្ខំដែលមានកម្មវត្ថុជាដី ឬ វត្ថុដែលត្រូវបានចុះបញ្ជី គឺសាលាដំបូងនៅទីកន្លែងដែលដី ឬវត្ថុដែលត្រូវបានចុះបញ្ជីនោះ ជាតុលាការអនុវត្តដែលមានសមត្ថកិច្ច (ចំណុច ក មាត្រា ៤១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ អចលនវត្ថុដែលជាកម្មវត្ថុ មានទីតាំងនៅ រាជធានីភ្នំពេញ ដូច្នេះសាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ចលើរឿងក្តីនេះ។។

[6] យោងចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ជាការអនុវត្តតាមការបង្ខំដោយផ្ទាល់[7]។

ចំពោះរឿងក្តីនេះ បានចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកតាម ដីកាសម្រេចលេខ 00 AJ 00 របស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០[8]។

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តម/ លោកជំទាវប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តបាត់ដំបង, ថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០២១

**អ្នកតំណាងដោយអាណត្តិ**

P

[7] យោងចំណុច គ និងចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[8] នៅពេលដាក់ពាក្យឱ្យសុំលក់ដោយបង្ខំ ចំពោះករណីដែលមានការឹបអូសជាបណ្ដោះអាសន្ន គួរតែសរសេរនូវខ្លឹមសារដែលការដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ ជាការផ្ទេរទៅការអនុវត្តដោយបង្ខំពីការរឹបអូសជាបណ្ដោះអាសន្ន ហើយភ្ជាប់ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ យ៉ាងណាមិញ ដើម្បីការរឹបអូសជាបណ្ដោះផ្ទេរទៅជាការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវការ ①អត្ថិភាពនៃលិខិតអនុវត្ត ②ភាគីនៃការអនុវត្តរក្សាការពារ និងការអនុវត្តដោយបង្ខំ ជាភាគីដូចគ្នា ③ការណ៍ដែលអាចទទួលស្គាល់ថាសិទ្ធិ ឬ ទំនាក់ទំនងដែលនឹងត្រូវបានរក្សា ការពាររឹបអូសជាបណ្ដោះអាសន្ន ដូចគ្នាជាមួយនឹងសិទ្ធិលើបំណុលដែលទាមទារនៅក្នុងការអនុវត្តដោយបង្ខំ។

**ឯកសារភ្ជាប់**

១-អនុសារសាលក្រមដែលមានអានុភាពអនុវត្ត[9]

២-លិខិតបញ្ជាក់ការបញ្ជូន[10]

៣-ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី

៤- ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

៥-លិខិតប្រគល់សិទ្ធិអ្នកតំណាងដោយអាណត្តិ "ច្បាប់ដើម"

---

[9] នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ជាគោលការណ៍ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់ជារបៀប ដែល បានទទួលរូបមន្តអនុវត្ត (មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយបានសរសេរភ្ជាប់បន្ថែម នៅ ផ្នែកខាងក្រោមនៃឯកសារចម្លងនៃលិខិតអនុវត្ត (មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[10] ការអនុវត្តដោយបង្ខំ អាចចាប់ផ្តើមបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬ ឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្តីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូល ជាស្ថាពរ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្តទុកជាមុន (មាត្រា ៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ

សិទ្ធិលើបំណុលដែលមានសញ្ញាណនៅក្នុងអនុសារសាលក្រមដែលមានអនុភាពអនុវត្តសាលក្រមរដ្ឋប្បវេណីលេខ ០០ ចុះថ្ងៃទី០០ ខែ០០ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ រវាងម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត មានដូចខាងក្រោម៖

១. ប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល

២. ការប្រាក់ចំនួន ២.០០០.០០០ (ពីរលានរៀល) រៀល

ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៥០.០០០.០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

៣. ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ[11]

ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

[11] ម្ចាស់បំណុលនៃការអនុវត្តអាចទទួលបានការចែកចំណែកប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក (យោង កថាខណ្ឌទី ៤ មាត្រា ៥៩០ ក្រមនីតិវិធីរដ្ឋប្បវេណី)។

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

### ម្ចាស់បំណុល

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ......... រាជធានីភ្នំពេញ។[1]

### អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................លេខទូរស័ព្ទ ៖ .................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី[2].................

### កូនបំណុល

ឈ្មោះ ៖ Y

---

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងចំណុច ក កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ។ ក្នុងករណីនេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគីបាន។

[2] យោងមាត្រា ៥៣៩, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូនមិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយល័ក្ខណ៍អក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

អាសយដ្ឋាន៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ......... រាជធានីភ្នំពេញ។

## សូមគោរពជូន
## ឯកឧត្តម/លោកជំទាវប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]

## ក. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ៖[4]

---

[3] រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (កថាខណ្ឌទី១ មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្តីនេះ ដោយសារតែលំនៅដ្ឋានរបស់កូនបំណុលនៅរាជធានីភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចនៃរឿងក្តីនេះ (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត រឿងក្តីនេះ ជា "បណ្តឹងទាក់ទងនឹងការចុះបញ្ជី" ដែលទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដូច្នេះ តុលាការដែលស្ថិតនៅ "កន្លែងដែលត្រូវចុះបញ្ជី" ក៏មានសមត្ថកិច្ចផងដែរ (ចំណុច ជ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "កន្លែងដែលត្រូវចុះបញ្ជី" គឺ "រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ" (កថាខណ្ឌទី២ ប្រការ ៥ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ ដោយសារតែអចលនវត្ថុស្ថិតនៅរាជធានីភ្នំពេញ ដូច្នេះ រដ្ឋបាលសុរិយោដីនៅរាជធានីភ្នំពេញ គឺជា "ទីកន្លែងដែលត្រូវចុះបញ្ជី" ហើយនៅក្នុងខ្លឹមសារនៃសមត្ថកិច្ចនេះ គឺសាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចលើរឿងក្តីនេះ។ លើសពីនេះទៅទៀត រឿងក្តីនេះ គឺជា "បណ្តឹងទាក់ទងនឹងអចលនវត្ថុ" ដែលទាមទារឱ្យប្រគល់អចលនវត្ថុ ដូច្នេះ តុលាការដែលអចលនវត្ថុស្ថិតនៅ ក៏មានសមត្ថកិច្ចផងដែរ (ចំណុច ឆ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ គឺអចលនវត្ថុ មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ហេតុដូច្នេះ នៅក្នុងខ្លឹមសារនៃសមត្ថកិច្ចនេះ ក៏សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចលើរឿងក្តីនេះផងដែរ។ ដូចដែលបានរៀបរាប់ដូចខាងលើ សាលាដំបូងរាជធានីភ្នំពេញ ជា "តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនេះ" ហើយមានសមត្ថកិច្ចលើរឿងក្តីឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។

ម្យ៉ាងទៀត នៅក្នុងរឿងក្តីនេះ អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ហេតុដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ ជា "តុលាការដែលមានសមត្ថកិច្ចលើទីតាំងនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ" ហើយនៅក្នុងខ្លឹមសារនេះ ក៏សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចលើរឿងក្តីឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នផងដែរ។

[4] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកពាក្យសុំទាមទារ ជាចំណុចត្រូវសរសេរជាចាំបាច់នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ខ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

១. ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែក ជាអាទិ៍) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្តោះអាសន្ន។[5]

២. ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្តោះអាសន្ន។[6]

បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ទៅឱ្យ អាជ្ញាសាលា ។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

---

[5] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ នៅក្នុងកថាខណ្ឌទី ១ គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ដើម្បីរក្សាការពារសិទ្ធិទាមទារចុះបញ្ជីទាក់ទងនឹងអចលនវត្ថុនៅក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នទាក់ទងនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[6] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ នៅក្នុងកថាខណ្ឌទី២ គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់អចលនវត្ថុ នៅក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នទាក់ទងនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ការចាត់ចែងដែលហាមឃាត់ការផ្ទេរការកាន់កាប់ មានខ្លឹមសារថាជាការហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ និងបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ព្រមទាំងអាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ (កថាខណ្ឌទី១ មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ករណីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ក៏ត្រូវបង្គាប់រួមទាំងខ្លឹមសារនេះផងដែរ។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

## ខ. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ[7]

### ខ.១ ការបង្កើតកិច្ចសន្យាលក់ទិញ

**ខ.១.១** ម្ចាស់បំណុល បានលក់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន ទៅឱ្យកូនបំណុល ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិច នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ")។ **(ភស្តុតាង $X_1$)**[8]

**ខ.១.២** ម្ចាស់បំណុល និង កូនបំណុល បានបង្កើតលិខិតយថាភូត (លិខិតលក់ផ្តាច់) ទៅលើ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។ **(ភស្តុតាង $X_2$)**

**ខ.១.៣** ម្ចាស់បំណុល និង កូនបំណុល បានព្រមព្រៀងគ្នាទៅលើកាលបរិច្ឆេទនៃការបង់ប្រាក់ថ្លៃលក់នៅក្នុង "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលមានសេចក្តីដូចខាងក្រោម៖

i. ចំពោះប្រាក់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលជាប្រាក់ពាក់កណ្តាលនៃប្រាក់ថ្លៃលក់ ត្រូវបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

---

[7] សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញនៃដីកាសម្រេចរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយចំណុចនេះត្រូវសរសេរឱ្យបានលម្អិតនូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ និងអង្គហេតុដែលជាមូលហេតុនៃសិទ្ធិ។ ម្យ៉ាងទៀត ដើម្បីឱ្យដីកាសម្រេចចេញបានដោយយ៉ាងឆាប់រហ័ស និងការកំណត់ចំនួនទឹកប្រាក់ប្រាតិភោគឱ្យបានទាបតាមដែលអាចធ្វើបាន គួរតែសរសេរនូវការតវ៉ាតបចំពោះការតវ៉ាដែលនឹងត្រូវបានរំពឹងទុក។

[8] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គួរតែខិតខំប្រឹងប្រែងសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់ (កថាខណ្ឌទី ២ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ii. ចំពោះប្រាក់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលជាប្រាក់ថ្លៃលក់នៅសល់ ត្រូវបង់នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

## ខ.២ ការរំលាយកិច្ចសន្យាលក់ទិញដោយសារមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយ

**ខ.២.១** ម្ចាស់បំណុល និង កូនបំណុល បានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលនៅរដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១។ **(ភស្តុតាង $X_2$)**

កូលបំណុលបានបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ទៅលើដី L ទៅឱ្យម្ចាស់បំណុល ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញរឿងក្តីនេះ" នៅថ្ងៃដដែលនេះ។ **(ភស្តុតាង $X_3$)**

**ខ.២.៣** នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ "ដី L" ត្រូវបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលពីម្ចាស់បំណុលទៅកូនបំណុល។ **(ភស្តុតាង $X_4$)**

**ខ.២.៤** ម្ចាស់បំណុល បានប្រគល់ "ដី L" ទៅកូនបំណុល នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។ កូនបំណុល កំពុងរស់នៅលើ "ដី L" និង កំពុងកាន់កាប់ "ដី L" ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១។ **(ភស្តុតាង $X_{6,7}$)**

**ខ.២.៥** ថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ បានកន្លងផុត។

**ខ.២.៦** ម្ចាស់បំណុល បានដាស់តឿន[9]ឱ្យកូនបំណុលបង់ប្រាក់ថ្លៃលក់ដែលនៅសល់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ព្រមទាំងបានបង្ហាញឆន្ទៈ[10] នូវខ្លឹមសាថានឹងរំលាយ "កិច្ចសន្យាលក់ទិញ

[9] ចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។ ការរំលាយដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច សូមយោងឯកសារនៅក្នុងសិក្ខាសាលាជុំទី៣។

[10] ចំណុច គ កថាខណ្ឌទី ១ មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី។ ការរំលាយដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច សូមយោងឯកសារនៅក្នុងសិក្ខាសាលាជុំទី ៣។

នៃរឿងក្តីនេះ" នៅពេល ដែលកូនបំណុលមិនបង់ប្រាក់ថ្លៃលក់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍។ (**ភស្តុតាង X$_7$**)

**ខ.២.៧** កូនបំណុល មិនបានបង់ប្រាក់ថ្លៃលក់ដែលនៅសល់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ត្រឹមថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នោះទេ។

## ខ.៣ ការសន្និដ្ឋានអំពី សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

ហេតុដូច្នេះ ម្ចាស់បំណុល មានសិទ្ធិទាមទារឱ្យចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិចំពោះ "ដី L" ដោយផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ចំពោះកូនបំណុល (កថាខណ្ឌទី២ មាត្រា៤១១ នៃក្រមរដ្ឋប្បវេណី)។[11] ម្យ៉ាងទៀត ម្ចាស់បំណុល មានសិទ្ធិទាមទារឱ្យប្រគល់ "ដី L" ដោយផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" (កថាខណ្ឌទី២ មាត្រា៤១១ នៃក្រមរដ្ឋប្បវេណី)។[12]

## គ. ភាពចាំបាច់នៃការរក្សាការពារ[13]

---

[11] នេះគឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង។ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាសិទ្ធិទាមទារតាវកាលិកទាក់ទងនឹងវត្ថុដែលកម្មវត្ថុនៃវិវាទ ដែលផ្តោតសំខាន់ទៅលើសិទ្ធិទាមទារ ឱ្យចុះបញ្ជី។

[12] នេះគឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការកាន់កាប់។ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការកាន់កាប់ គឺជាសិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ។ វាមិនត្រឹមតែជាសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ ជាអាទិ៍ នោះទេ វាក៏ជាសិទ្ធិទាមទារលើបំណុលផងដែរ។

[13] ភាពចាំបាច់នៃការរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅពេលដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចាំបាច់ត្រូវមានការបារម្ភថា ការអនុវត្តសិទ្ធិនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំង ដោយសារតែការផ្លាស់ប្តូរអ្នកកាន់កាប់។ នៅពេលដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ចាំបាច់ត្រូវមានការបារម្ភថា ការអនុវត្តសិទ្ធិនាពេលអនាគត នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំង ដោយសារតែគ្រោះថ្នាក់កើតចេញពីការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន ដូចជាអនុប្បទាន ឬ ការបង្កើតសិទ្ធិប្រាតិភោគចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដែលបានធ្វើឡើងដោយកូនបំណុល។

**គ.១** ម្ចាស់បំណុល កំពុងត្រៀមរៀបចំដាក់បណ្ដឹងរដ្ឋប្បវេណី ដើម្បីសម្រេចនូវសិទ្ធិនីមួយៗដែលបានសរសេរនៅក្នុង ខ.៣។

**គ.២** ប៉ុន្តែ យោងតាមដែលម្ចាស់បំណុលបានសួរ និងឮពីអ្នកដែលបានស្គាល់កូនបំណុលថា កូនបំណុល មានអាជីវកម្មដែលមិនបានដំណើរទៅដោយយ៉ាងរលូននោះទេ និងមានជាប់ជំពាក់ប្រាក់កម្ចីក្នុងចំនួនច្រើនគួរសម ទើបនាំឱ្យមានការបារម្ភយ៉ាងខ្លាំងដែលកូនបំណុលនឹងចាត់ចែង "ដី L"។ **(ភស្តុតាង $X_7$)**

**គ.៣** ម្យ៉ាងទៀត កូនបំណុលកំពុងរស់នៅក្នុងអាគារលើ "ដី L" ក៏ពិតមែន ប៉ុន្តែជាញឹកញាប់ កូនបំណុលមិននៅក្នុងអាគារនោះទេ ហើយនៅក្នុងអំឡុងពេលដែលកូនបំណុលមិននៅ មានបុគ្គលដែលហាក់ដូចជាសាច់ញាតិ ឬ មិត្តភក្តិជិតស្និទ្ធរបស់កូនបំណុលចេញចូលអាគារនោះ។ ចំពោះស្ថានភាពបែបនេះ គឺមានការបារម្ភថា កូនបំណុលងាយនឹងផ្ទេរការកាន់កាប់ "ដី L" ទៅឱ្យតតិយជន។ **(ភស្តុតាង $X_7$)**

**គ.៤** ប្រសិនបើការបារម្ភទាំងនោះនឹងក្លាយជាការពិត នាំឱ្យម្ចាស់បំណុលទោះបីជាទទួលបានសាលក្រមឈ្នះលើបណ្ដឹងអង្គសេចក្ដី ក៏នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងអនុវត្តសិទ្ធិទាំងនោះ។

## ឃ. ភស្តុតាង[14]

១. លិខិតលក់ផ្ដាច់ ចុះនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ **(ភស្តុតាង $X_1$)**

២. ឯកសារថតចម្លងពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល **(ភស្តុតាង $X_2$)**

៣. វិក័យប័ត្រទទួល **(ភស្តុតាង $X_3$)**

៤. ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី **(ភស្តុតាង $X_4$)**

៥. រូបថត (សារនៅក្នុង Telegram ដែលត្រូវបានបញ្ជូន និងទទួល រវាងម្ចាស់បំណុលនិងកូនបំណុល នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១) **(ភស្តុតាង $X_5$)**

---

[14] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) មានភាពចាំបាច់ត្រូវភ្ជាប់នូវឯកសារដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូង (កថាខណ្ឌទី ៣ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

៦. រូបថត (ស្ថានភាពកាន់កាប់ ដី L នាពេលបច្ចុប្បន្ន) **(ភស្តុតាង $X_6$)**

៧. របាយការណ៍ **(ភស្តុតាង $X_7$)**

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំនាញប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំនាញប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០២១

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០១ ច្បាប់"

P

**ឧបសម្ព័ន្ធ**

# បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

"សមាសភាពនៃដីខាងលើ" អាគារ (ផ្ទះ)

លេខ៖ 00

ប្រភេទ៖ សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារ៖ ធ្វើពីថ្មឥដ្ឋ

ទំហំអាគារ៖ 00 $m^2$

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខៈ 00

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

# ដីកាសម្រេចចាត់ចែងបណ្ដោះអាសន្ន[1]

ដីកាសម្រេចលេខៈ00

ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

យើង J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ ចំណុច ក មាត្រា ៥៣១, មាត្រា ៥៤២, កថាខណ្ឌទី ១ មាត្រា ៥៤៨, មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[2]
- បានឃើញពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។

---

[1] ការសម្រេចសេចក្ដី មាន សាលក្រម និង ដីកាសម្រេច (មាត្រា១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ គឺមានភាពចាំបាច់ដែលត្រូវសសេរប្រភេទនៃការសម្រេចសេចក្ដីនៅក្នុងក្បាលដើមនៃឯកសារ។ ពីព្រោះថា វិធីនៃឧបាស្រ័យជាអាទិ៍ មានភាពខុសគ្នារវាង សាលក្រម និងដីកាសម្រេច។ បណ្ដឹងឧបាស្រ័យចំពោះសាលក្រមរបស់សាលាដំបូងជាគោលការណ៍ គឺត្រូវធ្វើឡើងជាបណ្ដឹងឧទ្ធរណ៍ ចំណែកឯ បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច គឺត្រូវឡើងជាបណ្ដឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះដីកាសម្រេចរក្សាការពារកូនបំណុល អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលបានចេញដីកាសម្រេចនោះ (មាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងដីកាសម្រេចរក្សាការពារ មានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដូច្នេះ គឺមានការចាំបាច់កំណត់ឱ្យបានច្បាស់លាស់ថាជាដីកាសម្រេចណាមួយ។

[2] នៅពេលដែលយោងក្រមនីតិវិធីរដ្ឋប្បវេណី គួរតែសរសេរឱ្យបានលម្អិតត្រឹមតែលេខមាត្រាដែលត្រូវអនុវត្ត។

**ម្ចាស់បំណុល**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................លេខទូរស័ព្ទ ៖ ..................................................

**កូនបំណុល**

ឈ្មោះ ៖ Y

អាសយដ្ឋាន៖ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ។

**ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ**[3]

១. ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែក ជាអាទ៏) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្តោះអាសន្ន។

២. ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្តោះអាសន្ន។

បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា ។

---

[3] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយ អាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

## សំអាងហេតុ[4]

យោងតាមសំណុំរឿងនៃរឿងក្តីនេះ ទទួលស្គាល់ថាម្ចាស់បំណុលមានសិទ្ធិទាមទារចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ និង សិទ្ធិទាមទារឱ្យប្រគល់វិញ ទៅលើអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ចំពោះកូនបំណុល និងទទួលស្គាល់ផងដែរនូវភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

ដូច្នេះ តុលាការ ទទួលស្គាល់ថាពាក្យសុំរបស់ម្ចាស់បំណុលគឺសមរម្យ ហើយឱ្យម្ចាស់បំណុលដាក់ប្រាតិភោគចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ទើបធ្វើការសម្រេចសេចក្តីដូចខាងក្រោម ដើម្បីរក្សាការពារនូវសិទ្ធិទាមទារចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

[4]មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ង កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើមើលពីគោលគំនិតនៃលក្ខណៈបន្ទាន់បង្ខំ (លក្ខណៈឆាប់រហ័ស) នៃការរក្សាការពារផ្នែករដ្ឋប្បវេណី ដីកាសម្រេចរក្សាការពារ ត្រូវធ្វើឱ្យបានឆាប់រហ័ស ហើយជាពិសេសនៅក្នុងដីកាសម្រេចរឹបអូសជា បណ្តោះអាសន្ន ជាធម្មតាប្រសិនបើមិនបើកការទាញហេតុផលដោយផ្ទាល់មាត់ និងសួរកូនបំណុលទេ នាំឱ្យការសរសេរនៅក្នុងសំអាងហេតុគ្រាន់តែសរសេរឱ្យមានលក្ខណៈជារួម និងខ្លីៗ គឺគ្រប់គ្រាន់។ ម្យ៉ាងវិញទៀត ករណីដែលមានការស្នើរសុំទៅលើវិធីឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុវិវាទ នៅក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ នាំឱ្យជះឥទ្ធិពលយ៉ាងខ្លាំងទៅលើកូនបំណុល ដូច្នេះ គួរតែធ្វើការសាកសួរមិនត្រឹមតែទៅម្ចាស់បំណុលទេ ក៏ត្រូវសាកសួរកូនបំណុលផងដែរ ដើម្បីផ្តល់ឱកាសឱ្យកូនបំណុលធ្វើការអះអាង។ ក្នុងករណីនេះ ត្រូវតែសរសេរសំអាងហេតុឱ្យបានលម្អិតចំពោះករណីដែលបានមិនឱ្យកូនបំណុលធ្វើការអះអាង។

ចំពោះអចលនវត្ថុដូចមាន នៅក្នុងកំណត់បញ្ជីឧបសម្ព័ន្ធនៃវត្ថុដែលបានរៀបរាប់នៅក្នុងចំណុច ១ និង ដើម្បីរក្សាការពារនូវសិទ្ធិទាមទារឱ្យប្រគល់វិញចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងរៀបរាប់ខាងលើនៅក្នុងចំណុច ២។

## សេចក្ដីសម្រេចបញ្ចប់[5]

១.ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែក ជាអាទិ៍) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។[6]

២.ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។[7]

បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា ។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

---

[5] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ច កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ករណីនេះខុសពីការរឹបអូសជាបណ្ដោះអាសន្ន ហើយនៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន មិនមានការបញ្ញត្តអំពីប្រាក់ដែលកូនបំណុលត្រូវផ្ញើរ (ប្រាក់រំដោះ) ដើម្បីលុបចោលការអនុវត្តនោះទេ។

[6] នៅក្នុងកថាខណ្ឌទី ១ គឺជាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វិញនូវអចលនវត្ថុ នៅក្នុងចំណោមការចាត់ចែងជាបណ្ដោះអាសន្នទាក់ទងនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី)។

[7] នៅក្នុងកថាខណ្ឌទី២ គឺជាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដើម្បីរក្សាការពារទាមទារឱ្យប្រគល់អចលនវត្ថុ នៅក្នុងចំណោមការចាត់ចែងជាបណ្ដោះអាសន្នទាក់ទងនឹងវត្ថុដែលជា កម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃក្រមនីតិ វិធីរដ្ឋប្បវេណី)។ ការចាត់ចែងដែលហាមឃាត់ការផ្ទេរការកាន់កាប់មានខ្លឹមសារថាជាការហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ និងបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ព្រមទាំងអាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ (កថាខណ្ឌទី ១ មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋ ប្បវេណី)។ ម្យ៉ាងទៀត ករណីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ក៏ត្រូវបង្គាប់រួមទាំងខ្លឹមសារនេះផងដែរ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយ អាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

៣. ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់កូនបំណុល។[8]

ដីកាសម្រេចនេះអាចអនុវត្តបានភ្លាម។

ចំពោះដីកាសម្រេចនេះ អាចដាក់ពាក្យសុំតវ៉ាយោងតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ពស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២០

**ចៅក្រម**

[8] ទោះបីជាជាមាន ឬ មិនមានពាក្យសុំរបស់ភាគីក៏ដោយ ក៏ត្រូវតែកំណត់អំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី (មាត្រា ៥៣៩, មាត្រា ២១៦, កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ឧបសម្ព័ន្ធ**

# បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

‶ទីតាំងដី″ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

‶លេខឡូត៍″ ០០

‶សមាសភាពនៃដីខាងលើ″ អាគារ (ផ្ទះ)

លេខ៖ 00

ប្រភេទ៖ សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារ៖ ធ្វើពីថ្មឥដ្ឋ

ទំហំអាគារ៖ 00 $m^2$

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ....៤៤៧.... "ព" ដពស

# ដីកាសម្រេចលុបចោលនីតិវិធីអនុវត្តដោយបង្ខំ

យើង [redacted] ជាចៅក្រមតុលាការអនុវត្ត នៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៣៧០ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី។

-បានឃើញ សំណុំរឿងអនុវត្តដោយបង្ខំលេខ ៨៥ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ ០៤ "ព"វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ របស់តុលាការអនុវត្ត នៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ លិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលវត្ថុលេខ ៦១ "ព"ផ.អ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ របស់ក្រឡាបញ្ជីអនុវត្ត នៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ពាក្យសុំសងប្រាក់បង្គ្រប់ និងសុំអោយធនាគារប្រគល់ប័ណ្ណកម្មសិទ្ធ ចុះថ្ងៃ២៦ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ហៅ [redacted]។

**ម្ចាស់បំណុលនៃការអនុវត្ត៖** [redacted]) តំណាងដោយលោក [redacted] មានអាសយដ្ឋាននៅ អាគារលេខ [redacted] មហាវិថី [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

មានមេធាវីតំណាងសោយអាណត្តិលោក [redacted] និងលោក [redacted]។

**កូនបំណុលនៃការអនុវត្ត៖** ឈ្មោះ [redacted] និង ឈ្មោះ [redacted] ហៅ [redacted] មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ផ្លូវជាតិលេ [redacted] ភូមិ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

មានមេធាវីតំណាងដោយអាណត្តិលោក [redacted] និងលោក [redacted]។

**កម្មវត្ថុ៖** លុបចោលការអនុវត្តដោយបង្ខំ ក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ៨៥ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

## សំអាងហេតុ

ផ្អែកតាមសំណុំរឿងអនុវត្តលេខ ៨៥ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ ម្ចាស់បំណុលនៃការអនុវត្តដែលមានឈ្មោះ [redacted] តំណាងឲ្យ [redacted] បានសុំអនុវត្តដោយបង្ខំលើសាលក្រមរដ្ឋប្បវេណីលេខ ១៤០៤ (ខ) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ត្រង់សេចក្ដីសម្រេចចំណុចទី២-១ និងទី៣-១ នៃសាលក្រមសំដៅលើប្រាក់ដើមរបស់ធនាគារ ដែលបានផ្ដល់ទៅឲ្យកូនបំណុលនូវទឹកប្រាក់ចំនួន ៧.៨៥០.៧៤៤,៧៣$ (ប្រាំពីរលានប្រាំបីសែនប្រាំម៉ឺនប្រាំពីររយសែសិបបួន និងចិតសិបបីសេន ដុល្លាអាមេរិក)

តាមលិខិតលេខ ៨០ កមស ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមមេធាវីសន្តិភាព ដែលជាតំណាងដោយអាណត្តិរបស់កូនបំណុលនៃការអនុវត្ត បានបង្ហាញពីឯកសារ នៃការសងបំណុលនូវទឹកប្រាក់ចំនួន ៤.៥០០.០០០ $ (បួនលានប្រាំសែនដុល្លាអាមេរិក) ទៅម្ចាស់បំណុលនៃការអនុវត្ត ដោយភ្ជាប់មកនូវលិខិតប្រគល់ទទួល ចុះថ្ងៃទី០២ ខែ

វិច្ឆិកា ឆ្នាំ២០១៨ ដូច្នេះទឹកប្រាក់ដែលសុំអនុវត្តនៅសល់ចំនួន ៣.៣៥០.៧៤៤,៧៣$ (បីលានបីសែនប្រាំម៉ឺនប្រាំពីររយសែសិបបួន និងចិតសិបបីសេន ដុល្លារអាមេរិក) ដែលត្រូវអនុវត្តបន្ត ហើយកូនបំណុលបានដាក់ប្រាក់សម្រាប់ទូទាត់សងទៅម្ចាស់បំណុលនៃការអនុវត្តជាបន្តបន្ទាប់នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ចំនួន៣០០.០០០$ (សាមសិបម៉ឺនដុល្លារអាមេរិក) ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ចំនួន ១.០០០.០០០$ (មួយលានដុល្លារអាមេរិក) និង នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ចំនួន ២.៧៧១.៥៣៦,៧៤$ (ពីរលានប្រាំពីរសែនប្រាំពីរម៉ឺនមួយពាន់ប្រាំរយសាមសិបប្រាំមួយ និងចិតសិបបួនសេន ដុល្លារអាមេរិក) ជាសរុបទឹកប្រាក់ដែលកូនបំណុលបានដាក់តម្កល់នៅតុលាការអនុវត្តមានចំនួន ៤.០៧១.៥៣៦,៧៤$ (បួនលានប្រាំពីរម៉ឺនមួយពាន់ប្រាំរយសាមសិបប្រាំមួយ និងចិតសិបបួនសេន ដុល្លារអាមេរិក)។

គោលដៅនៃការអនុវត្តគឺដើម្បីសងប្រាក់ទៅម្ចាស់បំណុលឱ្យគ្រប់ចំនួនប៉ុណ្ណោះ បើពិនិត្យទៅលើបំណុលនៅសល់ ដែលម្ចាស់បំណុលបានសុំអនុវត្តនៅក្នុងលិខិតអនុវត្តមានចំនួន៣.៣៥០.៧៤៤,៧៣$(បីលានបីសែនប្រាំម៉ឺនប្រាំពីររយសែសិបបួន និងចិតសិបបីសេនដុល្លារអាមេរិក) ហើយប្រាក់ដែលកូនបំណុលនៃការអនុវត្តបានដាក់ប្រាតិភោគមានចំនួន៤.០៧១.៥៣៦,៧៤$ (បួនលានប្រាំពីរម៉ឺនមួយពាន់ប្រាំរយសាមសិបប្រាំមួយ និងចិតសិបបួនសេនដុល្លារអាមេរិក) ឯណោះ ឃើញថាលើសពីប្រាក់ដែលម្ចាស់បំណុលបានសុំអនុវត្តរហូតដល់ចំនួន៧២០.៧៩២,០១$ (ប្រាំពីរសែនពីរម៉ឺនប្រាំពីររយកៅសិបពីរ និងសូន្យមួយសេនដុល្លារអាមេរិក) ការដាក់ប្រាតិភោគរបស់កូនបំណុល សម្រាប់សងទៅម្ចាស់បំណុលនៃការអនុវត្តមានគ្រប់គ្រាន់ ហេតុនេះពុំមានភាពចាំបាច់ណាមួយត្រូវអនុវត្តលក់ទ្រព្យសម្បត្តិកូនបំណុលបន្តទៀតទេ ដូច្នេះតុលាការគប្បីលុបចោលការអនុវត្តដោយបង្ខំ។[1]

**ហេតុដូច្នេះ សម្រេច**

លុបចោលនីតិវិធីអនុវត្តដោយបង្ខំ លើសំណុំរឿងអនុវត្តដោយបង្ខំលេខ ៨៥ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

ថ្ងៃ...................ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...២១... ខែសីហា ឆ្នាំ២០១៩

**ចៅក្រមអនុវត្ត**

ហ៊ៅ ស៊ីណា

(1) មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច (ច) នៃក្រមនីតិវិធីរដ្ឋប្បវេណី។